Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្ដីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

KH/2007/ED/TLK/45
Phnom Penh, September 2007
Original: English

# ឯកសារជំនួយស្ដីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

## ទស្សនៈទូទៅអំពីឯកសារជំនួយ



ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសារួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

បាងកក : យូណេស្កូបាងកក ២០០៧

សៀវភៅ ៥ ក្បាល

1_ ទស្សនៈទូទៅនៃឯកសារជំនួយ 2_ភាសាប្រើប្រាស់ក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក 3_សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ 4_សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី 5_សៀវភៅសម្រាប់សមាជិកសហគមន៍

ISBN 92-9223-110-3

© UNESCO 2007

បានបោះពុម្ពផ្សាយដោយ

ការិយាល័យអប់រំអង្គការ UNESCO ប្រចាំតំបន់អាស៊ី_ប៉ាស៊ីហ្វិក

អាសយដ្ឋាន: 920 Sukhumvit Road, Prakanong

ទីក្រុងបាងកក ១០១១០.ប្រទេសថៃ

បានបកប្រែនិងកែសម្រួលពីច្បាប់ដើម *(ភាសាអង់គ្លេស)*

ឯកសារនិងរូបភាពទាំងអស់ដែលយកមកប្រើក្នុងការបោះពុម្ពផ្សាយនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុងឬតំបន់ណាមួយឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

## ទស្សនៈទូទៅអំពីឯកសារជំនួយ

# អារម្ភកថា

ឆ្នាំ ២០០៨ គឺជាពេលវេលាដែលយើងកំពុងស្ថិតនៅពាក់កណ្តាលផ្លូវ ឆ្ពោះទៅរកការសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា ក្នុងពេលដែលប្រទេសជាច្រើននៅក្នុងពិភពលោក កំពុងឈានទៅរកការសម្រេចបាននូវគោលដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នាក្នុងកម្រិតផ្សេងៗគ្នា ។ ប្រទេសកម្ពុជាកំពុងខិតខំជម្នះរាល់ការលំបាក ដើម្បីផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយគុណភាពដែលស្របនឹងការប្តេជ្ញាចិត្តរបស់ប្រទេសចំនួន ១៦៤ ក្នុងវេទិកាអប់រំពិភពលោកនាទីក្រុងដាកកាឆ្នាំ ២០០០ ។ ការវាយតម្លៃនៅពាក់កណ្តាលទសវត្សរ៍ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាដែលរៀបចំឡើងដោយអង្គការយូណេស្កូ សហការជាមួយអង្គការយូនីសេហ្វនិងស្ថាប័នអន្តរជាតិមួយចំនួន បានទទួលស្គាល់ថា ការអប់រំពីរភាសា ឬពហុភាសាផ្អែកលើភាសាកំណើត ជាមធ្យោបាយមួយក្នុងការសម្រេចឱ្យបាននូវគោលដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា ព្រោះការអប់រំនេះអាចជួយដល់ការសិក្សារបស់កុមារ ជាពិសេសគឺការសិក្សាកម្រិតដំបូងរបស់កុមារជនជាតិភាគតិច ។

ដោយយល់ឃើញពីសារៈសំខាន់នៃការអប់រំពីរភាសា ឬពហុភាសានិងដោយមានជំនួយផ្នែកបច្ចេកទេសនិងថវិកាពីអង្គការយូណេស្កូ ក្រសួងអប់រំ យុវជន និង កីឡាបានកែសម្រួលឯកសារមួយជាភាសាខ្មែរដែលមានចំណងជើងថា "ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសា" ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងការអនុវត្តការអប់រំពហុភាសា នៅក្នុងប្រទេសកម្ពុជាឱ្យស្របតាមមាត្រាទី ២៤ នៃច្បាប់អប់រំឆ្នាំ ២០០៧ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និង កីឡា អង្គការយូណេស្កូដែលបានខិតខំប្រឹងប្រែងក្នុងការបកប្រែនិងកែសម្រួលឯកសារនេះឡើង ដើម្បីលើកកម្ពស់ការអប់រំពហុភាសានៅកម្ពុជា ។

ខ្ញុំសង្ឃឹមថា ឯកសារជំនួយនេះនឹងរួមចំណែកដល់ការអភិវឌ្ឍការងារអប់រំក្រៅប្រព័ន្ធឱ្យមានការរីកចម្រើនថ្មីៗថែមទៀត ។

អ៊ឹម_សិទ្ធី

## Preface

2008 sees the mid-way of Education for All (EFA). While numerous countries in the world enjoy different level of achievements towards the six goals of EFA, the challenges ahead of us are to provide quality education for all as committed by the 164 countries at the 2000 Dakar World Education Forum. According to the EFA Mid-Decade Assessment organized by UNESCO, in partnership with UNICEF and other international agencies, mother-tongue based bilingual/multilingual education (MLE) has been recognized as one of the ways to help achieve the six EFA goals as it facilitates learning, particularly in the early stages and in literacy.

Seeing the important role mother-tongue based bilingual/multilingual education plays in achieving EFA, the Ministry of Education Youth and Sport (MoEYS) of Cambodia, with the technical and financial assistance from UNESCO, published the Khmer version of the "Advocacy Kit for Promoting Multilingual Education: Including the Excluded" (hereafter referred to as "Kit") with the aim of promoting MLE in Cambodia as stated in Article 24 of the 2007 Education Law.

We would highly commend the Department of Non-Formal Education (DNFE) for its commitment and endeavor since 2007 in the translation, contextualization and dissemination of the Kit in Khmer language. To ensure the relevance of the translated version in Cambodian context, additions and adaptations have also been made where appropriate. Moreover, the DNFE in collaboration with the UNESCO Phnom Penh Office has organized several workshops to further raise the awareness of MLE, in particular in the non-formal education settings, as well as to build the capacity of education policy makers and practitioners to better practice MLE in education policies and implementation

We trust that the Kit is useful for you and we encourage further adaptation by users in their daily practice to make the Kit more complete and relevant.

Teruo Jinnai
UNESCO Representative in Cambodia

# កថាមុខ

តំបន់អាស៊ី_ប៉ាស៊ីហ្វិកជាតំបន់ដែលចម្រុះទៅដោយជនជាតិ វប្បធម៌ និងភាសាផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយស្របពេលជាមួយគ្នានេះ ភាពសម្បូរបែបនោះធ្វើឲ្យការអប់រំកុមារដែលមានប្រភពចេញមកពីសាវតាផ្សេងៗគ្នាក្លាយទៅជាការងារមួយដ៏ចម្បងនិងតម្រូវឲ្យមានការប្រឹងប្រែងអស់ពីលទ្ធភាព។ គោលដៅមួយដ៏សំខាន់ដែលត្រូវបានអនុម័តនៅឯវេទិកាអប់រំពិភពលោកនៅទីក្រុងដាកាឆ្នាំ ២០០០ បានកំណត់ថា : ត្រូវធានាថា នៅឆ្នាំ ២០១៥ កុមារគ្រប់រូប ពិសេសគឺក្មេងស្រីនិងកុមារជនជាតិភាគតិចត្រូវមានភារៈ និងសិទ្ធិទទួលការអប់រំពេញលេញនៅបឋមសិក្សាដោយឥតបង់ថ្លៃនិងប្រកបដោយគុណភាព។ គោលដៅមួយផ្សេងទៀតតម្រូវឲ្យមានការកែលម្អកម្រិតអក្ខរកម្មឲ្យបានប្រសើរឡើង ជាពិសេសក្នុងចំណោមស្ត្រីភេទ។

ការសម្រេចនូវគោលដៅទាំងនេះនិងការបង្កឱកាសអប់រំឲ្យកាន់តែស្មើភាពគ្នាមានន័យថា យើងត្រូវមានការយកចិត្តទុកដាក់ទៅលើអ្នកសិក្សាជនជាតិភាគតិចតាមរយៈការចាត់វិធានការជាវិជ្ជមាន។ ការបង្រៀនដែលមានប្រសិទ្ធភាពគឺអាស្រ័យទៅលើទំនាក់ទំនងច្បាស់លាស់ដែលអាចឲ្យគេយល់បាន ដូច្នេះភាសាសម្រាប់ប្រើក្នុងការបង្រៀនគឺជាផ្នែកដ៏សំខាន់បំផុតនៃដំណើរការរៀនសូត្រ។ ព្រោះតែហេតុផលនេះហើយបានជាការបង្រៀនដែលផ្អែកលើភាសាកំណើតមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឱកាសឲ្យពួកគេទទួលបានសិទ្ធិអប់រំនិងផ្តល់លទ្ធភាពឲ្យពួកគេអាចចូលរួមក្នុងដំណើរការរៀនសូត្រ អាស្រ័យលើសមត្ថភាពរបស់ពួកគេ។ ជាអកុសលនៅតាមបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ ភាពសម្បូរបែបនៃភាសារបស់ជាតិសាសន៍ណាមួយគឺកម្រនឹងត្រូវបានគេប្រើប្រាស់នៅក្នុងប្រព័ន្ធអប់រំរបស់ពួកគេណាស់ ហើយអ្នកសិក្សាមួយចំនួនធំក៏ត្រូវប្រឈមមុខនឹងការប្រើប្រាស់ភាសាបរទេសឬភាសាមួយដែលខុសប្លែកពីភាសាកំណើតនៅក្នុងមេរៀនរបស់ខ្លួន។ កត្តានេះប្រហែលជាអាចកាន់តែធ្ងន់ធ្ងរទៅទៀតក្នុងករណីដែលក្រុមមនុស្សមួយចំនួនស្ថិតក្នុងស្ថានភាពលំបាករួចទៅហើយនោះ ឧទាហរណ៍ដូចជា ក្រុមអនក្ខរជន ជនជាតិភាគតិច និងជនភៀសខ្លួនជាដើម។ ជាការពិតណាស់ ទោះជាមិនទាន់មានការទទួលស្គាល់ជាទូទៅក៏ដោយ ក៏ការសិក្សាមួយបានបង្ហាញថា ការប្រើភាសាណាមួយដែលមិនមែនជាភាសាផ្ទាល់របស់អ្នកសិក្សាអាចបង្កនូវការលំបាកពីរយ៉ាងគឺ ការរៀនភាសាមួយថ្មីនិងការរៀនសូត្រនូវចំណេះដឹងថ្មីៗជាភាសាថ្មីនោះ។

នៅក្នុងប្រទេសមួយចំនួននៅទ្វីបអាស៊ី កម្មវិធីអប់រំពីរភាសាឬពហុភាសាតាមរយៈការអប់រំក្រៅប្រព័ន្ធ កំពុងតែជួយអ្នកសិក្សាជាជនជាតិភាគតិចឲ្យបង្កើនចំណេះអក្ខរកម្មទាំងភាសាកំណើតនិងភាសាជាតិ។ ប៉ុន្តែនៅមានកង្វះខាតការទទួលស្គាល់និងការយល់ដឹងអំពីតួនាទីរបស់ការអប់រំពីរភាសាឬពហុភាសាក្នុងការបង្កើនការចុះឈ្មោះចូលរៀន ការរៀនបន្តរបស់សិស្សនិងសមិទ្ធផលក្នុងការអប់រំក្នុងប្រព័ន្ធ។ ឯកសារជំនួយនេះគាំទ្រការធ្វើឲ្យប្រព័ន្ធអប់រំកាន់តែឆ្លើយតបទៅនឹងភាពសម្បូរបែបនៃវប្បធម៌។ វាផ្តល់នូវការយល់ដឹងយ៉ាងជ្រាលជ្រៅអំពីតម្លៃនៃការអប់រំពហុភាសាតាមរយៈភាសាកំណើតដែលគោរពដល់សិទ្ធិកុមារនិងអ្នកសិក្សាទាំងឡាយ ហើយលើកទឹកចិត្តដល់អ្នកអានឲ្យគិតអំពីសារៈប្រយោជន៍នៃបញ្ហាភាសាព្រមទាំងតាមដានអង្កេតពីបញ្ហាទាំងនោះបន្តទៅទៀត។ ឯកសារនេះត្រូវបានកសាងឡើងដោយផ្អែកលើរបកគំហើញនៃការសិក្សាស្រាវជ្រាវនិងបទពិសោធន៍អស់រយៈកាលជាច្រើនឆ្នាំកន្លងមករបស់មន្ត្រីនិងអង្គការនានាដែលធ្វើការងារផ្នែកអប់រំពហុភាសាតាមរយៈភាសាកំណើត។

ខ្ញុំសង្ឃឹមថា សៀវភៅស្តើងដែលមានក្នុងឯកសារជំនួយនេះនឹងមានអត្ថប្រយោជន៍សម្រាប់ការលើកកម្ពស់និងគាំទ្រការបង្រៀនភាសាកំណើតដែលជាមធ្យោបាយមួយនៃការកែលម្អគុណភាពអប់រំឲ្យប្រសើរឡើង ក៏ដូចជាការជួយសង្គ្រោះដល់ភាសាទាំងឡាយនៃពិភពលោកទាំងមូលដែលកំពុងតែប្រឈមនឹងការបាត់បង់។

នាយកការិយាល័យអប់រំនៃអង្គការ UNESCO ប្រចាំតំបន់អាស៊ី_ប៉ាស៊ីហ្វិក

**Sheldon Shaeffer**

## សេចក្តីថ្លែងអំណរគុណ

ការរៀបចំឯកសារជំនួយនេះគឺជាការងារដែលមានការចូលរួមពីអ្នកឯកទេសផ្នែកអប់រំជាច្រើន អ្នកជំនាញការនិងអ្នកដទៃទៀតដែលមកពីបណ្តាប្រទេសទាំងក្នុងនិងក្រៅតំបន់អាស៊ី_ប៉ាស៊ីហ្វិក។ ឈ្មោះរបស់គេត្រូវបានរាយជូននៅទំព័របន្ទាប់នេះ ហើយការិយាល័យអង្គការ UNESCO ប្រចាំនៅបាងកក សូមថ្លែងអំណរគុណដល់អស់លោកទាំងនេះចំពោះការចូលរួមវិភាគទានរបស់ពួកគេ។

យើងសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រអស់ពីដួងចិត្តចំពោះសមាជិកនៃគណៈកម្មាធិការប្រឹក្សាអប់រំពហុភាសារបស់អង្គការ UNESCO ប្រចាំទីក្រុងបាងកក ដែលបានផ្តល់ការគាំទ្រឥតឈប់ឈរក្នុងការកសាងឯកសារជំនួយនេះឡើង។

យើងសូមសម្តែងការដឹងគុណចំពោះប្រភពឯកសារយោងផ្សេងៗដែលបានយកមកប្រើប្រាស់នៅក្នុងឯកសារជំនួយនេះ ហើយក៏សូមលើកទឹកចិត្តដល់អ្នកអានឲ្យប្រើប្រាស់ឯកសារទាំងនោះផងដែរ។

យើងក៏សូមថ្លែងអំណរគុណដល់សិក្ខាកាមចូលរួមក្នុងសិក្ខាសាលាស្តីពីកម្មវិធីអក្ខរកម្មពីរភាសា ឬភាសាកំណើតសម្រាប់ជនជាតិភាគតិចដែលបានប្រារព្ធឡើងនាខែ ធ្នូ ឆ្នាំ ២០០៥ នៅខេត្តឈាងម៉ៃ ប្រទេសថៃ ដែលពួកគេបានចូលរួមវិភាគទានដ៏មានតម្លៃក្នុងការកែលម្អឯកសារជំនួយនេះឲ្យប្រសើរឡើង។

យើងសូមសម្តែងការដឹងគុណដ៏ស្មោះស្ម័គ្រដល់អស់លោកទាំងអស់ដែលបានចែករំលែករូបថត ព្រមទាំងសមាជិកសហគមន៍ជនជាតិភាគតិចដែលយល់ព្រមឲ្យចែករំលែករូបថតរបស់ខ្លួនជាមួយពួកយើង។

ក្រៅពីមូលនិធិកម្មវិធីរបស់អង្គការ UNESCO នេះទៅ មូលនិធិជប៉ុន Japanese Funds-in-Trust ក៏បានគាំទ្រដល់ការកសាងនិងផ្សព្វផ្សាយឯកសារជំនួយនេះ។ យើងសូមថ្លែងអំណរគុណដល់ជំនួយទាំងនេះ និងសូមទទួលស្គាល់នូវអត្ថប្រយោជន៍ដែលឯកសារនេះផ្តល់ដល់អ្នកសិក្សាទាំងក្នុងនិងក្រៅតំបន់អាស៊ី_ប៉ាស៊ីហ្វិក។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណជាពិសេសចំពោះអ្នកស្រីបណ្ឌិត Dr Susan Malone, មកពីអង្គការ SIL អន្តរជាតិដែលជាអ្នកនិពន្ធឯកសារនេះយ៉ាងសំខាន់ម្នាក់។ លោក Ochirkhuyag Gankhuyag ដែលជាអ្នកជំនួយការកម្មវិធីអង្គការ UNESCO ប្រចាំទីក្រុងបាងកក ដែលបានជួយសម្របសម្រួលដល់គម្រោងនេះ ហើយបានចូលរួមដោះស្រាយការលំបាកទាំងឡាយសំដៅបំពេញបន្ថែមក្នុងគម្រោងនេះឲ្យបានពេញលេញនៅក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ។

ឈ្មោះខាងក្រោមនេះគឺជាអ្នកដែលបានចូលរួមបរិច្ចាគពេលវេលាដ៏មានតម្លៃនិងការយល់ដឹងរបស់ខ្លួនក្នុងការកសាងឯកសារជំនួយនេះ។ ប្រសិនបើយើងមានការភ្លេចភ្លាំងដោយអចេតនាមិនបានរាយនាមអស់លោកណាម្នាក់ សូមមេត្តាទទួលការសុំខមាលទោសនិងការដឹងគុណរបស់យើងចំពោះជំនួយដ៏មានតម្លៃរបស់អស់លោកអ្នក។

Donald Archibald
George Attig
Joel Bacha
Carol Benson
Jean Bernard
Terry Durnnian
Ochirkhuyag Gankhuyag
Abdul Hakeem
Caroline Haddad
Maki Hayashikawa
Vibeke Jensen
Linda King
Kimmo Kosonen
Pamela Mackenzie
Dennis Malone
Susan Malone
Inna Melnikova
Jan Noorlander
Darunee Riewpituk
Karsten van Riezen
R.Sachdeva
Sheldon Shaeffer
Pongsuda Vongsigha
Clive Wing
Catherine Young



# ទស្សនៈទូទៅអំពីឯកសារជំនួយ

ការអប់រំសម្រាប់ទាំងអស់គ្នា (EFA) មានន័យថា ជាការអប់រំមួយប្រកបដោយគុណភាពសម្រាប់ជនគ្រប់រូប។ ចាប់តាំងពីការចាប់ផ្តើមចលនាអប់រំសម្រាប់ទាំងអស់គ្នានេះមក បណ្តាប្រទេសជាច្រើនបានបង្កើននូវកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំរបស់កុមារនិងមនុស្សពេញវ័យ។ ទោះបីជាគេបានធ្វើការងារនេះជាច្រើនក៏ដោយ ក៏នៅមានក្រុមមនុស្សដែលនៅក្រៅសាលានៅឡើយ ពោលគឺក្រុមកុមារីនិងស្ត្រីភេទ និស្សិតក្រីក្រ ជនពិការ អ្នកផ្ទុកមេរោគអេដស៍និងប្រជាជនដែលមានភាសាកំណើតរបស់ខ្លួនខុសប្លែកពីភាសាផ្លូវការឬភាសាជាតិ។

តើគេអាចសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នាបានឬទេ នៅពេលដែលការអប់រំប្រើប្រាស់ភាសាមួយដែលអ្នកសិក្សាមួយចំនួនមិនចេះនិយាយឬមិនយល់? នេះជាបញ្ហាដែលកុមារមកពីក្រុមជនជាតិភាគតិចជាច្រើនជួបប្រទះនៅពេលដែលពួកគេចូលរៀនតាមសាលាក្នុងប្រព័ន្ធ (ភាសាតាមសាលាមានភាពខុសពីភាសាដែលពួកគេនិយាយនៅតាមផ្ទះ)។

នៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក កម្មវិធីអប់រំពីរភាសាឬពហុភាសាដែលត្រូវបានកសាងឡើងសម្រាប់ការអប់រំក្រៅប្រព័ន្ធបានជួយដល់អ្នកសិក្សាជាជនជាតិភាគតិចឲ្យក្លាយជាអក្ខរជនចេះអានចេះសរសេរភាសាកំណើតខ្លួននិងភាសាជាតិ។ ប៉ុន្តែគោលនយោបាយថ្នាក់ជាតិនៅមានកង្វះខាតការទទួលស្គាល់និងការយល់ដឹងអំពីតួនាទីនៃការអប់រំពហុភាសាក្នុងការបង្កើនការចុះឈ្មោះ និងការរៀនបន្តរបស់សិស្ស។ ម្យ៉ាងទៀតគេគួរទទួលស្គាល់ថា អ្នកកសាងគោលនយោបាយ និងអ្នកទទួលបន្ទុកផ្នែកអប់រំត្រូវប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកពាក់ព័ន្ធនឹងការប្រើភាសាសម្រាប់បង្រៀនតាមសាលា នៅពេលដែលកត្តាបច្ចេកទេសនិងកត្តានយោបាយកំពុងប្រកួតប្រជែងគ្នា។ អាស្រ័យហេតុនេះ ការយល់ដឹងឲ្យបានទូលំទូលាយអំពីការផ្តល់ការអប់រំដោយប្រើភាសាកំណើតរបស់សិស្សគឺជាជំហានដំបូងយ៉ាងសំខាន់បំផុតឆ្ពោះទៅរកការសម្រេចបាននូវការអប់រំប្រកបដោយគុណភាពសម្រាប់ជនគ្រប់រូប។

## ១_តើអ្នកណាអាចប្រើឯកសារជំនួយនេះ?

ឯកសារជំនួយនេះត្រូវបានកសាងឡើងសម្រាប់មនុស្សទាំងអស់ដែលចង់ធានាឲ្យបាន"ការអប់រំសម្រាប់ទាំងអស់គ្នា" ពោលគឺផ្តល់ឱកាសដល់ជនគ្រប់រូបទទួលបានការអប់រំជាមូលដ្ឋាន។ ឯកសារជំនួយនេះនឹងមានតម្លៃដ៏ពិសេសចំពោះអ្នកកសាងគោលនយោបាយ អ្នកអប់រំ ព្រមទាំងអ្នកឯកទេសដែលចង់កែលម្អឲ្យប្រសើរឡើងនូវសិទ្ធិទទួលការអប់រំនិងគុណភាពនៃការអប់រំសម្រាប់អ្នកទាំងឡាយដែលមិនត្រូវបានគេរាប់បញ្ចូលដោយសារបញ្ហាភាសា។ ឯកសារជំនួយនេះមានគុណប្រយោជន៍ចំពោះអ្នកដែលនិយាយភាសាជនជាតិភាគតិចដែលចង់កែលម្អស្ថានភាពអប់រំនៅក្នុងសហគមន៍របស់ពួកគេផ្ទាល់។

ឯកសារជំនួយនេះត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំពហុភាសាតាមរយៈភាសាកំណើត។ ឯកសារជំនួយនេះផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីតម្លៃនិងផលប្រយោជន៍ការអប់រំដោយប្រើភាសាកំណើតរបស់អ្នកសិក្សា។ ឯកសារជំនួយនេះក៏ផ្តល់ជាគំនិត របកគំហើញនៃការស្រាវជ្រាវនិងឧទាហរណ៍ជាក់ស្តែងដែលអ្នកអាចប្រើប្រាស់ដើម្បីពិចារណាអំពីស្ថានភាពផ្ទាល់ខ្លួនរបស់លោកអ្នក ហើយស្នើឲ្យចាប់ផ្តើមចាត់វិធានការដើម្បីធ្វើឲ្យប្រព័ន្ធសាលារៀនកាន់តែឆ្លើយតបទៅនឹងភាពសម្បូរបែបនៃភាសា។ សូមបញ្ជាក់ថា ឯកសារជំនួយនេះមិនមែនជាសៀវភៅដែលអាចផ្តល់ចម្លើយចំពោះរាល់បញ្ហាដែលលោកអ្នកជួបប្រទះនោះទេ។ ដើម្បីជួយលោកអ្នកឲ្យអស់លទ្ធភាព នៅដើមសៀវភៅនីមួយៗមានសេចក្តីសង្ខេបមួយទំព័រអំពីខ្លឹមសារក្នុងសៀវភៅនោះ និងឯកសារយោង។

## ២_តើអ្នកអាចប្រើឯកសារជំនួយនេះយ៉ាងដូចម្ដេច?



ឯកសារជំនួយនេះមានសៀវភៅស្ដើងសំខាន់ៗចំនួនបីក្បាល។ សៀវភៅស្ដើងនីមួយៗបានកំណត់អ្នកដែលត្រូវអានរួចជាស្រេចគឺ ៖

១_អ្នកកសាងគោលនយោបាយ

២_អ្នកធ្វើផែនការនិងអ្នកកសាងកម្មវិធីអប់រំ

៣_សមាជិកសហគមន៍។

សូមចងចាំថា ការអប់រំពហុភាសាតម្រូវឲ្យមានការចូលរួមពីមនុស្សគ្រប់រូបនៅគ្រប់កម្រិត។ យើងខ្ញុំជំរុញលោកអ្នកឲ្យប្រើប្រាស់សៀវភៅស្ដើងទាំងបីក្បាលនេះរួមជាមួយនឹងធនធានផ្សេងៗទៀតដែលអ្នកអាចរកបាន នៅពេលដែលលោកអ្នករួមគ្នារៀបចំផែនការអនុវត្តនិងបន្តកម្មវិធីអប់រំពហុភាសារបស់លោកអ្នកឲ្យមាននិរន្តរភាព។

គេអាចប្រើប្រាស់ឯកសារជំនួយនេះតាមរបៀបច្រើនយ៉ាងផ្សេងពីគ្នា។ ប្រសិនបើលោកអ្នកបានចូលរួមកម្មវិធីអប់រំពហុភាសានេះរួចហើយ លោកអ្នកត្រូវប្រើប្រាស់គំនិតទាំងនេះដើម្បីជាជំនួយក្នុងការលើកកម្ពស់ការបង្រៀនជាភាសាកំណើត ហើយពង្រឹងកម្មវិធីរបស់លោកអ្នក។ អ្នកដែលមិនទាន់បានដឹងអំពីការអប់រំពហុភាសា ប៉ុន្តែចង់ផ្ដល់ការអប់រំដល់សិស្សជាជនជាតិភាគតិចអាចប្រើប្រាស់សៀវភៅស្ដើងទាំងនេះដើម្បីកំណត់ឲ្យឃើញនូវចំណុចជាក់លាក់ដែលនាំឲ្យពួកគេធ្វើការអង្កេតនិងពិភាក្សានៅក្នុងបរិបទរបស់ខ្លួន។

## ឯកសារយោង


Alidou, Boly, A Brock-Utne, B., Diallo, Y.S, Heugh, K and Wolff, H. E. 2006 *Optimizing Learning and Education in Africa: The Language Factor. A Stock Taking Research on Mother Tongue and Billingual Education in Sub-Saharan Africa.* Paris, Association for the Development of Education in Africa (ADEA) www.adeanet.org/biennial2006/doc/document/B3_1_MTBLE_en.pdf (Accessd 17 November 2006)

Benson, C. 2005 *Mother Tongue-based Teaching and Education for Girls.* Bangkok, UNESCO http:/unesco.org/images/0014/001420/142079e.pdf (Accessed on 17 November 2006)

Cummins, J. 2000. Bilingual Chidren's Mother Tongue: Why is it Important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed 0n 17 November 2006)

Delpit. L.D. and Kemelfield, G. 1985. *An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province.* ERU Report No. 51 Waigani, Papua New Guinea, University of Papua New Guinea.

Department of Education. 1991. *Education Sector Review.* Waigani, Papua New Guinea, Department of Education.

Dutcher, N. 2004. *Expanding Education/Opportunities in Linguistically Diverse Countries.* Washington D.C., Center of Applied Linguistics. http://www.cal.org/resources/pubs/fordreport_040501.pdf (Accessed on 17 November 2006)

Gharagedaghi, J. 1986. *A Prologue to National Development Planning.* New York, Greewood Press.

Grin, F. Economic Considerations in Language Policy. 2005. Ricento, T. (ed). 2005. *An introduction to Language Policy:* Theory and Method. Oxford, Basil Blackwell.

Jhingran, D.2005. *Language Disadvantage. The Learning Challenge in Primary Education.* New Delhi: A. P.H. Publishing.

Malone, S. 2005. Planning community-based education programs in minority language communities. Resource manual for mother tongue speakers of minority languages engaged in planning and implementing education programs in their own communities.

Shaeffer, S. 2003. (7-9 November) *Language Development and Language Revitalization: An Education Imperative in Asia.* International Conference on Language Development, LanguageRevitalization and Multilingual Education. Bangkok, Thailand. http://www.sil.org/asia/idc/plenary_papers/sheldon_shaeffer.pdf (Accessed on 17 November 2006)

UNESCO. 2000. *The EFA 2000 Assessment: Papua New Guinea Country Report.* http://www2.unesco.org/wef/countryreports/papua_new_guinea/contents.html (Accessed on 17 November 2006)

UNESCO. 2003. *Education in a Multilingual World.* Paris, UNESCO. http://unesdocunesco.org/images/0012/001297/129728e.pdf (Accessed on 17 November 2006)

Vawda, A.Y. and Patrinos, H. A. 1998. *Cost of Producing Education Materials in Local Language.* Washington D.C.: World Bank.

Wako, J. 1997. *The Value of Traditional Knowledge in the 21 st Century.* Waigani Seminar. Waigani, Papua New Guinea, University of Papua New Guinea. http://www.pngbuai.com/600 technology/information/waigani/w97-keynote.html (Accessed on 17 November 2006)

Waters, G., Dondorp, A., Stillings, L., Wemin, J., Keruwa, R., Stefaniw, R. and Thomas, S. 1995. *A survey of Vernacular Education Programming at the provincial level within Papua New Guinea.* Ukarumpa, Papua New Guinea, SIL International.

## គណៈកម្មការរៀបចំ

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| លោក កុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អ្នកស្រី ស៊ុន ឡេ | អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការយូណេស្កូ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក ឡុង សុជាត | មន្ត្រីការិយាល័យក្រោយអក្ខរកម្ម |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| អ្នកស្រី លី ខេង | មន្ត្រីការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នកផ្ទៀងផ្ទាត់ និងកែសម្រួល**

| | |
|---|---|
| លោក មោគ ភឿន | អនុប្រធានការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| លោក តាន់ ជន | ជំនួយការកម្មវិធីអប់រំនៃអង្គការយូណេស្កូ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នករចនាអត្ថបទ**

| | |
|---|---|
| លោក ឈិន វ៉ុត | ប្រធានការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| អ្នកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |

បានទទួលការអនុញ្ញាតឲ្យបោះពុម្ព និង ប្រើប្រាស់ពីក្រសួងអប់រំ យុវជន និង កីឡា
តាមរយៈប្រកាសលេខ ៥១ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

Japanese Funds-in-Trust

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី
# ការលើកកម្ពស់ការអប់រំពហុភាសា

## *រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន*

## ភាសាប្រើក្នុងគោលនយោបាយអប់រំ
## និងការអនុវត្តនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក



ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសារួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

បាងកក : យូណេស្កូបាងកក ២០០៧

សៀវភៅ ៥ ក្បាល

1_ ទស្សនៈទូទៅនៃឯកសារជំនួយ 2_ភាសាប្រើប្រាស់ក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក 3_សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ 4_សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី 5_សៀវភៅសម្រាប់សមាជិកសហគមន៍

ISBN 92-9223-110-3

© UNESCO 2007

បានបោះពុម្ពផ្សាយដោយ

ការិយាល័យអប់រំអង្គការ UNESCO ប្រចាំតំបន់អាស៊ី_ប៉ាស៊ីហ្វិក

អាសយដ្ឋាន: 920 Sukhumvit Road, Prakanong

ទីក្រុងបាងកក ១០១១០.ប្រទេសថៃ

បានបកប្រែនិងកែសម្រួលពីច្បាប់ដើម (ភាសាអង់គ្លេស)

ឯកសារនិងរូបភាពទាំងអស់ដែលយកមកប្រើក្នុងការបោះពុម្ពផ្សាយនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុងឬតំបន់ណាមួយ ឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី
# ការលើកកម្ពស់ការអប់រំពហុភាសា
## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

## ភាសាប្រើក្នុងគោលនយោបាយអប់រំ
## និងការអនុវត្តនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក

# ភាសាប្រើក្នុងគោលនយោបាយអប់រំនិងការអនុវត្តនៅ តំបន់អាស៊ី_ប៉ាស៊ីហ្វិក

## ១_ភាសាប្រើក្នុងគោលនយោបាយអប់រំនិងការអនុវត្តនៅតំបន់អាស៊ីអាគ្នេយ៍

### ប្រទេសប្រ៊ុយណេ (Brunei Darusalam)

នៅប្រទេសប្រ៊ុយណេ គេប៉ាន់ស្មានថាមានភាសាចំនួន ១៧ ដែលគេប្រើប្រាស់។ ភាសាដែលគេសន្មត យកមកប្រើជាផ្លូវការគឺភាសាម៉ាឡេ (ភាសាជ្វា) ប៉ុន្តែភាសាដែលគេប្រើទូលំទូលាយបំផុតគឺភាសាម៉ាឡេ_ប្រ៊ុយណេ។ ភាសាដែលគេប្រើក្នុងការបង្រៀនគឺភាសាអង់គ្លេសនិងម៉ាឡេ។ ចំណែកភាសាតាមតំបន់មិនត្រូវបានគេយក មកប្រើក្នុងការបង្រៀនទេ។

### ប្រទេសកម្ពុជា (Cambodia)

មានភាសាប្រហែល ២០ ភាសាដែលគេប្រើប្រាស់ក្នុងប្រទេសកម្ពុជា។ ជនជាតិខ្មែរគឺជាជនជាតិដែល មានចំនួនច្រើនជាងគេ (ប្រហែល ៩០% នៃប្រជាជនសរុប)។ ភាសាដែលប្រើក្នុងការបង្រៀននៅគ្រប់កម្រិតគឺ ភាសាជាតិ (ខ្មែរ)។ ថ្មីៗនេះភាសាជនជាតិភាគតិចមួយចំនួនត្រូវបានគេយកមកប្រើនៅក្នុងការបង្រៀនតាម គម្រោងសាកល្បងក្នុងតំបន់ខ្ពង់រាបខាងកើត។ គម្រោងនេះបានផ្តល់នូវការអប់រំពីរភាសាទាំងការអប់រំក្នុង ប្រព័ន្ធនិងក្រៅប្រព័ន្ធដល់ជនពេញវ័យនិងកុមារ។ ច្បាប់អប់រំឆ្នាំ ២០០៧ បានផ្តល់សិទ្ធិដល់ក្រុមជនជាតិ ភាគតិចឲ្យទទួលបាននូវការបង្ហាត់បង្រៀនដោយប្រើភាសាកំណើតរបស់គេ។

### ប្រទេសឥណ្ឌូនេស៊ី (Indonesia)

ប្រទេសឥណ្ឌូនេស៊ីដែលមានជាង ៧០០ ភាសាជាប្រទេសមួយដែលមានភាសាសម្បូរបែបច្រើនជាង គេនៅតំបន់អាស៊ី។ ភាសាឥណ្ឌូនេស៊ីគឺជាភាសាផ្លូវការហើយក៏ជាភាសាប្រើក្នុងការបង្រៀននៅគ្រប់កម្រិត សិក្សាដែរ។ ប៉ុន្តែមានប្រជាជននៅត្រឹមតែ ១០% ប៉ុណ្ណោះដែលនិយាយភាសាឥណ្ឌូនេស៊ីជាភាសាកំណើត របស់គេ។ រដ្ឋធម្មនុញ្ញនិងច្បាប់អប់រំបានគាំទ្រការប្រើភាសាកំណើតសិស្សសម្រាប់ការសិក្សានៅថ្នាក់ដំបូង។ ទោះជាយ៉ាងណាក៏ដោយក្នុងការអនុវត្តជាក់ស្តែង ភាសាតាមតំបន់កម្រត្រូវគេយកមកប្រើនៅក្នុងសាលារដ្ឋ ណាស់។ នៅតំបន់មួយចំនួន ភាសាកំណើតសិស្សត្រូវបានគេបង្រៀនជាមុខវិជ្ជាមួយតែប៉ុណ្ណោះ។ ភាសាតាម តំបន់ត្រូវបានប្រើទូលំទូលាយក្នុងការអប់រំក្រៅប្រព័ន្ធ ជាពិសេសក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ។

## ប្រទេសឡាវ (Lao PDR)

នៅប្រទេសឡាវមានភាសាប្រហែល ៨២ ភាសា។ ភាសាប្រើក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សា គឺភាសាឡាវដែលជាភាសាប្រើជាផ្លូវការ។ ប្រជាជនឡាវប្រហែលជាជាងពាក់កណ្ដាលនិយាយភាសាឡាវជាភាសាកំណើត។ នៅពេលបច្ចុប្បន្ននេះ ភាសាតាមតំបន់មិនត្រូវបានប្រើក្នុងការអប់រំឡើយ តែគេប្រើវាយ៉ាងទូលំទូលាយក្នុងការសន្ទនាផ្ទាល់មាត់នៅតាមសាលាក្នុងតំបន់ជនជាតិភាគតិចមួយចំនួន។

## ប្រទេសម៉ាឡេស៊ី (Malaysia)

នៅប្រទេសម៉ាឡេស៊ីមានភាសាប្រហែល ១៤០ ភាសាដែលគេយកមកប្រើ។ ភាសាម៉ាឡេ (ភាសាថ្កា) ជាភាសាផ្លូវការរបស់ជាតិ។ សាលារៀនភាគច្រើនប្រើភាសាម៉ាឡេក្នុងការបង្រៀន។ នៅក្នុងសាលាបឋមសិក្សារដ្ឋមានភាសាជាច្រើនដូចជា ភាសាចិនកុកងឺ ភាសាតាមិល (Tamil) និងភាសាឥណ្ឌាមួយចំនួនទៀតត្រូវបានគេយកមកប្រើក្នុងការបង្រៀន។ ចាប់តាំងពីដើមទសវត្សរ៍ ៩០មក ក្រុមអ្នកស្រុកមួយចំនួននៅភាគខាងកើតនៃប្រទេសបានចាប់ផ្តើមធ្វើកម្មវិធីសិក្សាដោយប្រើភាសានៅតាមតំបន់ ដោយគាត់ដាក់បញ្ចូលភាសាទាំងនោះជាមុខវិជ្ជាសិក្សាមួយ។ ទោះជាយ៉ាងដូច្នេះក្តី កិច្ចខិតខំប្រឹងប្រែងទាំងនេះក៏មិនអាចចាត់ទុកថាជាការអប់រំពីរភាសាបានទេ ពីព្រោះភាសាទាំងនោះមិនត្រូវបានគេប្រើជាផ្លូវការក្នុងការបង្រៀននៅឡើយ។

## ប្រទេសមីយ៉ាន់ម៉ា (Myanma)

នៅប្រទេសមីយ៉ាន់ម៉ា (Myanma) មានភាសាជាង ១០០ ភាសា។ ភាសាប្រើក្នុងការបង្រៀនក្នុងប្រព័ន្ធអប់រំរបស់រដ្ឋគឺភាសាបាម៉ា (Bama) ដែលជាភាសាផ្លូវការ ហើយភាសានៅតាមតំបន់មិនត្រូវបានប្រើនៅក្នុងប្រព័ន្ធអប់រំរបស់រដ្ឋទេ។ ទោះជាដូច្នេះក៏ដោយ ភាសាតាមតំបន់ត្រូវបានប្រើយ៉ាងទូលំទូលាយក្នុងការអប់រំក្រៅប្រព័ន្ធនិងក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ ដោយសង្គមស៊ីវិលនិងសហគមន៍ជនជាតិភាគតិច ជាពិសេសខេត្តនានានៅប៉ែកខាងជើងដែលមានជនជាតិភាគតិចរស់នៅច្រើន។

## ប្រទេសហ្វីលីពីន (Philippines)

នៅប្រទេសហ្វីលីពីនមានភាសា ១៧០ ភាសា។ ភាសាភាគច្រើនមានប្រព័ន្ធសំណេររួចហើយ។ អក្សរសាស្ត្រមួយចំនួនត្រូវបានគេសរសេរជា ១០០ ភាសាក្នុងចំណោមភាសាទាំងនោះ។ ភាសាអង់គ្លេសនិងហ្វីលីពីនជាភាសាផ្លូវការសម្រាប់ការអប់រំនិងអក្ខរកម្មជាតិ។ ភាសាតាមតំបន់ជាច្រើនត្រូវបានយកមកប្រើជាភាសាជំនួយ

ឬភាសាអន្តរកាលសម្រាប់ការបង្រៀននៅថ្នាក់បឋមសិក្សានៃសាលារដ្ឋ។ ទោះជាយ៉ាងដូច្នេះក្តី ភាសាតាមតំបន់ភាគច្រើនត្រូវបានយកមកប្រើក្នុងការសន្ទនាផ្ទាល់មាត់ដើម្បីពន្យល់មេរៀនដល់សិស្ស។ ភាសាតាមតំបន់ត្រូវបានយកមកប្រើយ៉ាងទូលំទូលាយក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធដោយផ្តោតទៅលើអក្ខរកម្មមនុស្សពេញវ័យ។ គម្រោងកម្មវិធីអប់រំបែបនេះ ជាទូទៅត្រូវបានគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គការសហគមន៍។

## ប្រទេសសិង្ហបុរី (Singapore)

ប្រទេសសិង្ហបុរីមានភាសាជាង ២០ ភាសា។ សិង្ហបុរីមានបំណងធ្វើឱ្យសង្គមរបស់គេក្លាយជាសង្គមពហុភាសា។ ប្រជាជន ៣/៤ ជាជនជាតិចិនដែលនិយាយភាសាចិនផ្សេងៗគ្នា។ ភាសាអង់គ្លេសជាភាសាដែលប្រើក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សា ហើយក៏មានភាសាផ្លូវការបីផ្សេងទៀតផងដែរដូចជា ភាសាម៉ាឡេ (Malay) ភាសាចិន (Mandarin Chinese) និងភាសាតាមិល (Tamil) ដែលត្រូវបានគេយកមកបង្រៀនជាភាសាទី ២ ឬហៅថាភាសាកំណើត។ អ្នកនិយាយភាសាផ្សេងទៀតអាចជ្រើសរើសភាសាដោយសេរីចេញពីភាសាទាំងនោះដែលមានក្នុងកម្មវិធីសិក្សា។ ប៉ុន្តែគ្មានបទប្បញ្ញត្តិណាចែងពីការអប់រំដោយឱ្យយកភាសាក្នុងស្រុកមកប្រើបែបនេះទេ គឺដូចស្រឡះពីបណ្តាប្រទេសជាច្រើននៅតំបន់អាស៊ីអាគ្នេយ៍។

## ប្រទេសថៃ (Thailand)

ប្រទេសថៃមានភាសាជាង ៧០ ភាសា។ ភាសាថៃគឺជាភាសាផ្លូវការនិងជាភាសាប្រើក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សា។ នៅតំបន់ខ្លះគេបានបង្រៀនភាសាក្នុងស្រុកតាមកម្មវិធីសិក្សាក្នុងស្រុកនីមួយៗ។ ភាសាក្នុងស្រុកមួយចំនួនបានប្រើក្នុងការងារអប់រំក្រៅប្រព័ន្ធ ជាពិសេសសម្រាប់ថ្នាក់អក្ខរកម្មមនុស្សពេញវ័យដែលត្រូវបានគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ទីភ្នាក់ងាររដ្ឋាភិបាលបានគាំទ្រផងដែរនូវគម្រោងសាកល្បងដែលប្រើភាសាក្នុងស្រុកសម្រាប់ការអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងអប់រំទាំងអស់នោះមិនត្រូវបានគេចាត់ទុកថាជាការអប់រំពីរភាសាដ៏ពិតប្រាកដទេ។ ចាប់តាំងពីឆ្នាំ ២០០៤ គឺមានការកើនឡើងនៃការពិភាក្សាក្នុងក្រសួងអប់រំក៏ដូចជាក្នុងសារព័ត៌មានដើម្បីប្រើប្រាស់ភាសាតាមតំបន់នៅក្នុងការអប់រំ។

### ប្រទេសវៀតណាម (Vietnam)

ប្រទេសវៀតណាមមានភាសាប្រហែលជា ១០០ ភាសា។ ភាសាវៀតណាមគឺជាភាសាជាតិហើយត្រូវបាននិយាយដោយប្រជាជនប្រមាណជា ៩០% នៃប្រជាជនសរុប។ ការអប់រំពីរភាសានិងការប្រើប្រាស់ភាសាតាមតំបន់នៅក្នុងការអប់រំគឺត្រូវបានចែងនៅក្នុងឯកសារគោលនយោបាយជាច្រើន ប៉ុន្តែភាសាវៀតណាមនៅតែជាភាសាតែមួយដែលគេប្រើនៅក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់។ ភាសាតាមតំបន់ត្រូវបានគេប្រើក្នុងការអប់រំនៅតំបន់មួយចំនួន ហើយត្រូវបានគេរៀនជាមុខវិជ្ជាមួយដោយឡែក។ ចាប់តាំងពីឆ្នាំ ២០០៦ មក គេបានចាប់ផ្ដើមគម្រោងអប់រំសាកល្បងដោយប្រើភាសាជនជាតិភាគតិចជាច្រើនគម្រោង។

## ២_ភាសាប្រើក្នុងការអនុវត្តនិងក្នុងគោលនយោបាយអប់រំនៅតំបន់អាស៊ីខាងកើត

### ប្រទេសចិន (China)

ប្រទេសចិនមានភាសាជាង ២០០ ភាសា។ ភាសាចិនកុកងឺ (Mandarin Chinese) ជាភាសាផ្លូវការ។ មានច្បាប់និងគោលនយោបាយជាច្រើនបានគាំទ្រនូវការប្រើភាសាជនជាតិភាគតិចសម្រាប់ការបង្រៀននៅតំបន់ជនជាតិ។ ទោះជាយ៉ាងដូច្នេះក្ដី គោលនយោបាយបែបនេះមិនទាន់បានអនុវត្តគ្រប់ទីកន្លែងទេ (បានអនុវត្តត្រឹមតែ ៥៥ តំបន់ជនជាតិដែលបានកំណត់ទុកប៉ុណ្ណោះ)។ ដោយផ្អែកទៅលើទីតាំងភូមិសាស្ត្រនិងក្រុមជនជាតិភាគតិច គេឃើញមានភាពផ្លាស់ប្ដូរជារឿយៗក្នុងការប្រើភាសាក្នុងស្រុកសម្រាប់ការអប់រំ។ ភាសាក្នុងស្រុកប្រហែលជា ៦ ត្រូវបានគេយកមកប្រើក្នុងការបង្រៀនតាំងពីបឋមសិក្សារហូតដល់មធ្យមសិក្សា។ នៅក្នុងករណីនេះ គេយកភាសាចិនកុកងឺមកបង្រៀនជាភាសាទី២។ កម្មវិធីអប់រំពីរភាសាតាមតំបន់ដែលគេប្រើញឹកញាប់ជាងគេគឺចាប់ផ្ដើមឡើងដោយប្រើភាសាកំណើតរបស់សិស្សដើម្បីឈានទៅរកការសិក្សាភាសាចិនកុកងឺ។ នៅតំបន់ជនជាតិភាគតិចជាច្រើន គេបានយកភាសាក្នុងស្រុកមកបង្រៀនជាមុខវិជ្ជាមួយ។

### ប្រទេសម៉ុងហ្គោលី(Mongolia)

តាមការប៉ាន់ស្មានបានឲ្យដឹងថា មាន ១២ ភាសាក្នុងប្រទេសម៉ុងហ្គោលី។ មានប្រជាជនប្រហែលជា ៩០% ជាជនជាតិម៉ុងហ្គោលដែលនិយាយភាសាផ្លូវការផ្សេងគ្នាដូចជា ភាសាហាល (Halh) និងភាសាខាលកាម៉ុងហ្គោលី (Khalka Mongolian)។ ភាសាម៉ុងហ្គោលីជាភាសាប្រើក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សាទោះបីភាសាអង់គ្លេសកំពុងមានតួនាទីសំខាន់នៅថ្នាក់សាកលវិទ្យាល័យក៏ដោយ។ ភាសាហាលម៉ុងហ្គោលីជា

ភាសាទី ២ ដែលជនជាតិភាគតិចប្រើ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩២ បានគាំទ្រនូវការប្រើភាសាជនជាតិជាភាសាប្រើក្នុងការបង្រៀន។ ទោះជាយ៉ាងដូច្នេះក្តី ការអប់រំពីរភាសានាពេលថ្មីៗនេះមានតែភាសាកាហ្សាក់ (Kazakh) មួយប៉ុណ្ណោះដែលគេយកមកប្រើ។

## ប្រទេសជប៉ុន (Japan)

ប្រទេសជប៉ុនមានភាសាដើម ២ គឺភាសាជប៉ុន (Japanese) និងភាសាអេនូ (AINU) ដែលគេនិយាយ ហើយភាសាដើមនេះរួមមាន ១១ គ្រាមភាសាផ្សេងទៀតហៅថាភាសាជប៉ុន_រីយូគីយូអាន (Japanes-Ryukyuan) ដែលអ្នកខ្លះបានចាត់ទុកថាជាភាសាមានទំនាក់ទំនងយ៉ាងជិតដិតជាមួយគ្រួសារផ្ទាល់ខ្លួនរបស់គេ។ ភាសាជប៉ុនជាភាសាជាតិរបស់ប្រទេសជប៉ុន ហើយត្រូវបាននិយាយដោយប្រជាជនប្រហែល ៩៩%។ នៅក្នុងទសវត្សថ្មីៗនេះ គេសង្កេតឃើញថា មានការកើនឡើងនៃជនបរទេសដែលនិយាយភាសាជប៉ុន។ ចំណែកភាសាប្រើក្នុងការបង្រៀនជាផ្លូវការគឺភាសាជប៉ុន។ ទោះជាយ៉ាងនេះក្តី ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជប៉ុនកាលពីពេលថ្មីៗនេះបានចេញផ្សាយនូវគោលនយោបាយជាច្រើនទាក់ទងនឹងកុមារអន្តោប្រវេសន៍និងកុមារមិនមែនជាជនជាតិជប៉ុន ដើម្បីកែលម្អការបង្រៀនភាសាជប៉ុនជាភាសាទី ២ នៅតាមសាលា ផ្តល់ការបង្រៀនដោយប្រើភាសាកំណើតរបស់សិស្សតាមរយៈការបង្រៀនជាក្រុមឬវិធីសាស្ត្រដទៃទៀត ប្រើប្រាស់បទពិសោធន៍របស់កុមារមិនមែនជនជាតិជប៉ុនឬកុមារជាតិជប៉ុនដែលធ្វើមាតុភូមិនិវត្តន៍ដើម្បីពង្រីងការស្វែងយល់វប្បធម៌រវាងនិស្សិតជប៉ុននិងនិស្សិតបរទេស។

## ៣_ភាសាប្រើក្នុងគោលនយោបាយនិងក្នុងការអនុវត្តនៅតំបន់អាស៊ីខាងត្បូងនិងខាងលិច

## ប្រទេសអាហ្គានីស្ថាន (Afghanistan)

ប្រទេសអាហ្គានីស្ថានមានភាសាប្រហែល ៣០ ភាសា ក្នុងនោះមានភាសាចំនួន ៨ ដែលគេនិយាយយ៉ាងទូលំទូលាយ រួមមានភាសាប៉ាស្តូ (Pashto) ភាសាដារី (Dari) ភាសាអ៊ូប៊ិច (Uzbec) ភាសាធើកម៉េន (Turkmen) ភាសាប៉ាស្ហេ (Pashae) ភាសានូរីស្តានី (Nooristani) ភាសាប៉ាឡូស៊ី (Balochi) និងភាសាស៊ីណានី (Shighnani)។ ភាសាប៉ាស្តូនិងភាសាដារីជាភាសាជាតិនិងភាសាផ្លូវការរបស់ប្រទេសអាហ្គានីស្ថាន ហើយគេបានប្រើវាជាភាសាក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សា។ រដ្ឋធម្មនុញ្ញគាំទ្រភាសាកំណើតជាភាសាប្រើក្នុងការបង្រៀនសម្រាប់ការអប់រំមូលដ្ឋាន។ ក្រសួងអប់រំមានផែនការប្រើភាសាជនជាតិសម្រាប់ការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធព្រមទាំងឲ្យមានការបង្រៀនភាសាជនជាតិមួយចំនួនជាមុខវិជ្ជាមួយ។

## ប្រទេសបង់ហ្គាដេស (Bangladesh)

ប្រទេសបង់ហ្គាដេសមានភាសាប្រហែល ៤០ ភាសា។ ភាសាបង់ហ្គា (Bangla) ជាភាសាជាតិនិង ជាភាសាផ្លូវការរបស់ប្រទេសបង់ហ្គាដេស ហើយក៏ជាភាសាប្រើក្នុងការបង្រៀននៅគ្រប់កម្រិតសិក្សាផងដែរ។ ក្នុងចំណោមប្រជាជនជាង ១៤០ លាននាក់ មានប្រជាជន ៩៨% និយាយភាសាបង់ហ្គា។ ភាសាអង់គ្លេសក៏ជាភាសាយកមកបង្រៀននៅសាកលវិទ្យាល័យផងដែរ។ ចំណែកភាសាបង់ហ្គាត្រូវគេយកមកប្រើក្នុងការបង្រៀននៅសាលារដ្ឋព្រមទាំងថ្នាក់អក្ខរកម្មនិងសាលាឯកជនផ្សេងៗទៀត។ ប៉ុន្តែគ្មានបទប្បញ្ញត្តិចែងឲ្យប្រើភាសាកុលសម្ព័ន្ធនៅក្នុងសាលាទាំងនេះទេ។ គេបានប្រើភាសារបស់ក្រុមជនជាតិភាគតិចជាភាសាជំនួយឬជាភាសាអន្តរកាលសម្រាប់ទំនាក់ទំនងផ្ទាល់មាត់ ដើម្បីធ្វើការពន្យល់បកស្រាយនូវកម្មវិធីសិក្សា។ ហេតុដូច្នេះក្រុមជនជាតិភាគតិចជាច្រើនកំពុងតែប្រឈមមុខនឹងការបាត់បង់មរតកវប្បធម៌ និងភាសាសាស្ត្ររបស់ពួកគេ ហើយទន្ទឹមនឹងនេះ ក៏មានកង្វះខាតការអប់រំជាភាសាដែលពួកគេប្រើ។

## ប្រទេសប៊ូតង់ (Bhutan)

នៅប្រទេសប៊ូតង់មានភាសា ១៨ ភាសា។ ភាសាដ្សុងខា (Dzongkha) ជាភាសាជាតិ ហើយគេដឹងថាវាជានិមិត្តសញ្ញាមួយដែលតំណាងឲ្យអត្តសញ្ញាណរបស់ព្រះរាជាណាចក្រប៊ូតង់។ ក្នុងប្រព័ន្ធសិក្សារដ្ឋ គេប្រើភាសាអង់គ្លេសជាចំបងក្នុងការបង្រៀន ក្រៅពីនេះក៏មានប្រើភាសាដ្សុងខាក្នុងថ្នាក់រៀនមួយចំនួនដែរ។ ការអប់រំក្រៅប្រព័ន្ធបានដំណើរការទូទាំងប្រទេសប៊ូតង់ដោយប្រើភាសាដ្សុងខា។ រដ្ឋាភិបាលបានឲ្យធ្វើការស្រាវជ្រាវពិពណ៌នានូវភាសាសាស្ត្រមួយចំនួនដែលជាភាសាជនជាតិភាគតិច ប៉ុន្តែការខិតខំប្រឹងប្រែងអភិវឌ្ឍភាសា ភាគច្រើនគឺយកចិត្តទុកដាក់ទៅលើតែភាសាដ្សុងខាទេវិញ។

## ប្រទេសឥណ្ឌា (India)

នៅប្រទេសឥណ្ឌាមានការខ្វែងគំនិតគ្នាឥតឈប់ឈរទាក់ទងទៅនឹងចំនួនភាសានិងគ្រាមភាសាដែលមាននៅក្នុងប្រទេស។ ក្នុងបញ្ជីជំរឿនឆ្នាំ ១៩៦១ គេឃើញមានភាសា ១៦៥២ ភាសា ដោយឡែកក្នុងបញ្ជីជំរឿនឆ្នាំ ១៩៩១ វិញ មានត្រឹមតែ ១១៤ ភាសាប៉ុណ្ណោះ។ ការសិក្សាបែបវិទ្យាសាស្ត្រទៅលើពូជសាសន៍បានចុះបញ្ជីថាមានប្រហែល ៤៣០ ភាសា។ ពេលថ្មីៗនេះមាន ២២ ភាសាបានចុះបញ្ជីក្នុងកិច្ចប្រជុំលើកទី ៨ នៃរដ្ឋធម្មនុញ្ញ ហើយភាសាហ៊ិនឌី (Hindi) បានចុះបញ្ជីជាភាសាផ្លូវការនិងភាសាអង់គ្លេស(English) ជាភាសាផ្លូវការបន្ទាប់ ឬទី ២។

មានមាត្រាជាច្រើននៅក្នុងរដ្ឋធម្មនុញ្ញឥណ្ឌាដែលចែងអំពីភាសា ឧទាហរណ៍ខ្លឹមសារនៅមាត្រា ៣៥០A ចែងថា "គ្រប់រដ្ឋនិងគ្រប់អាជ្ញាធរមូលដ្ឋានត្រូវខិតខំផ្តល់សម្ភារៈគ្រប់គ្រាន់សម្រាប់ការបង្រៀនដោយប្រើភាសាកំណើតនៅដំណាក់កាលសិក្សាដំបូងសម្រាប់កុមារជនជាតិភាគតិច"។

នៅក្នុងឆ្នាំ ១៩៥៧ ក្រុមប្រឹក្សាអប់រំថ្នាក់កណ្តាលបានស្នើឲ្យមាន "រូបមន្តបីភាសា" ដ៏ស្មុគស្មាញមួយ ហើយក្នុងឆ្នាំ ១៩៦១ គណៈរដ្ឋមន្ត្រីបានយល់ព្រមទាំងស្រុងចំពោះសំណើនេះ។ សំណើនេះគ្របដណ្តប់ទៅលើការបង្រៀនបីភាសានៅកម្រិតសិក្សាផ្សេងៗ។ ក្រៅពីរដ្ឋអូរីសា (Orissa) និងរដ្ឋម៉ាហារ៉ាស្ត្រា (Maharashtra) រដ្ឋជាច្រើនទៀតមិនបានអនុវត្តរូបមន្តនេះទេ។

នៅក្នុងគម្រោងកម្មវិធីសិក្សាថ្នាក់ជាតិដែលចេញផ្សាយដោយ NCERT រាល់ ៥ ឆ្នាំម្តងបាននិយាយថា ភាសាកំណើតគប្បីប្រើក្នុងការបង្រៀននៅគ្រប់ដំណាក់កាលសិក្សា (NCERT ២០០០ ទំព័រ ៧៦)។ ប៉ុន្តែគម្រោងនេះគ្រាន់តែជាការណែនាំប៉ុណ្ណោះមិនមែនជាច្បាប់ទេ។

ជាទូទៅ ការអប់រំធ្វើឡើងដោយការប្រើភាសាក្នុងស្រុក ភាសាតំបន់ឬភាសាផ្លូវការ (តាមកិច្ចប្រជុំរដ្ឋធម្មនុញ្ញលើកទី៨)។ ប៉ុន្តែគេយល់ថា ការអប់រំដែលមានកិត្យានុភាពល្បីល្បាញគឺជាការអប់រំដែលប្រើភាសាអង់គ្លេសក្នុងការបង្រៀន។ ហេតុដូច្នេះហើយបានជាកិច្ចពិភាក្សាផ្នែកនយោបាយភាគច្រើនបានផ្តោតតែទៅលើការប្រើប្រាស់ភាសាឥណ្ឌា និងភាសាអង់គ្លេស ជាងការប្រើភាសាកំណើត។ រដ្ឋខ្លះដែលមានប្រជាជនកុលសម្ព័ន្ធច្រើនបានធ្វើការសាកល្បងប្រើភាសាកុលសម្ព័ន្ធក្នុងការអប់រំ។ កិច្ចការនេះបានទទួលជោគជ័យសមហេតុសមផលនៅក្នុងរដ្ឋអាសាម (Assam) និងរដ្ឋណាហ្គាឡាន (Nagalan)។ ការសាកល្បងនៅក្នុងរដ្ឋរ៉ាយ៉ាស្ថង់ (Rajasthan) រដ្ឋអូរីសា (Orissa) និងរដ្ឋអង់ដ្រាប្រាដេស (Andra Pradesh) បានជួបបញ្ហាជាច្រើនក្នុងដំណាក់កាលអនុវត្តន៍ តែទោះជាយ៉ាងណាក្តី នាពេលបច្ចុប្បន្ននេះរដ្ឋទាំងនេះកំពុងតែបន្តធ្វើការសាកល្បងថ្មីៗទៀត។

## ប្រទេសនេប៉ាល់ (Nepal)

នៅប្រទេសនេប៉ាល់មានភាសាប្រហែល ៩០ ភាសា។ ភាសាប្រើក្នុងការបង្រៀននៅក្នុងសាលារដ្ឋគឺភាសានេប៉ាល់ (Nepal) ហើយក៏ជាភាសាផ្លូវការផងដែរ។ សាលាឯកជនជាច្រើនបានផ្តល់ការអប់រំជាភាសាអង់គ្លេស។ រដ្ឋធម្មនុញ្ញនេប៉ាល់បានចែងឲ្យមានការប្រើភាសាកំណើតនៅក្នុងដំណាក់កាលសិក្សាដំបូង ប៉ុន្តែការអនុវត្តជាក់ស្តែងមានតែបន្តិចបន្តួចប៉ុណ្ណោះ។ ដោយសារមានជំនួយឧបត្ថម្ភពីបរទេស មជ្ឈមណ្ឌលផលិតកម្មវិធីនិងសៀវភៅសិក្សាបានរៀបចំសៀវភៅសម្រាប់អ្នកសិក្សាដំបូងមួយចំនួនដែលសរសេរជាភាសា

ជនជាតិ ៩ ភាសាផ្សេងៗគ្នា។ ប៉ុន្តែមានការលំបាកណាស់ក្នុងការដឹងឲ្យប្រាកដថា សៀវភៅទាំងនោះត្រូវបានគេប្រើទូលំទូលាយប៉ុណ្ណា។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានចាប់ផ្តើមធ្វើថ្នាក់ពិសោធន៍ ដោយប្រើភាសាកំណើតនៅក្នុងការអប់រំក្រៅប្រព័ន្ធ។

ការយល់ដឹងនូវសារៈសំខាន់នៃការអប់រំដែលមានមូលដ្ឋានប្រើភាសាកំណើតកំពុងតែរីកចម្រើន ប៉ុន្តែវាមានភាពចលាចលផ្នែកនយោបាយនាពេលបច្ចុប្បន្ននេះដែលធ្វើឲ្យមានការលំបាកក្នុងការអនុវត្ត។

## ប្រទេសប៉ាគីស្ថាន (Pakistan)

ប៉ាគីស្ថានជាប្រទេសមានភាសាច្រើន រួមមានភាសាចម្បង ៦ ភាសា និងភាសាជនជាតិភាគតិចជាង ៥៧ ភាសាទៀត។ ភាសាកំណើតដែលជាភាសាចម្បងនោះ រួមមានភាសាពុនយ៉ាប៊ី ៤៤% (Punjabi) ភាសាប៉ាស្តូ ១៥% (Pashto) ភាសាស៊ីនឌី ១៤% (Sindhi) ភាសាស៊ីរ៉ៃគី ១១% (Siraiki) ភាសាអ៊ូឌូ ៨% (Urdu) ភាសាបាឡូជី ៤% (Balochi) និងភាសាជនជាតិ ៥%។

ភាសាអ៊ូឌូជាភាសាជាតិហើយភាសាអង់គ្លេសជាភាសាផ្លូវការ។ គេប្រើភាសាអ៊ូឌូយ៉ាងទូលំទូលាយជាភាសាទី ២ នៅតាមទីក្រុងនានានៃប្រទេសប៉ាគីស្ថាន ពីព្រោះវាជាភាសាប្រើក្នុងការបង្រៀននៅសាលារដ្ឋនិងសាលាសាសនា។ ហើយភាសានេះក៏បានប្រើផងដែរក្នុងការបង្រៀនគ្រប់មុខវិជ្ជានៅមហាវិទ្យាល័យនិងសាកលវិទ្យាល័យលើកលែងតែមុខវិជ្ជាបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។ ភាសាអ៊ូឌូក៏ជាភាសាប្រើនៅក្នុងវិស័យពាណិជ្ជកម្ម និងការកំសាន្ត ដូច្នេះហើយវាជាភាសាមានប្រយោជន៍សម្រាប់ការងារច្រើនជាងភាសាផ្សេងៗទៀតដែលប្រើនៅប្រទេសប៉ាគីស្ថាន។ ភាសាមួយផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការងារដែរនោះគឺភាសាស៊ីនឌី ដែលជាភាសាប្រើនៅក្នុងការអប់រំកម្រិតមធ្យមនិងវិស័យផ្លូវការខ្លះទៀត។ ភាសាប៉ាស្តូក៏ត្រូវបានប្រើក្នុងការបង្រៀនក្នុងសាលាមួយចំនួនរហូតដល់ថ្នាក់ទី ៥ ប៉ុន្តែមិនត្រូវបានប្រើក្នុងវិស័យផ្សេងៗទៀតទេ។ មានប្រជាជនប៉ាគីស្ថានប្រហែលត្រឹមតែ ២% ប៉ុណ្ណោះដែលមានសមត្ថភាពនិយាយភាសាអង់គ្លេសបាន។ ទោះបីជាមានប្រជាជនពី ១៥% ទៅ ១៨% បន្ថែមទៀតដែលអាចនិយាយភាសាអង់គ្លេសបានតិចតួចក៏ដោយ ក៏វានៅតែជាភាសារបស់ក្រុមវរជនដូចជា រដ្ឋាភិបាល ការិយាធិបតេយ្យជាន់ខ្ពស់ ក្រុមមន្ត្រីកងទ័ព ការអប់រំកម្រិតមធ្យម និងឧត្តម ការស្រាវជ្រាវនិងពាណិជ្ជកម្មជាដើម។ ភាសាអង់គ្លេសមានប្រយោជន៍ច្រើនសម្រាប់ជនអន្តោប្រវេសន៍ និងជនផ្លាស់ប្តូរទីកន្លែងញឹកញាប់។ ដូច្នេះហើយបានជាមានតម្រូវការមួយយ៉ាងខ្លាំងនូវវគ្គសិក្សាភាសាអង់គ្លេសដែលពីដើមមានតែចំពោះវរជននៅសាលាភាសាអង់គ្លេសថ្នាក់មធ្យម ឬសាលានានាដែលគ្រប់គ្រងដោយកងកម្លាំងប្រដាប់អាវុធ (មហាវិទ្យាល័យហ្វឹកហាត់ទាហាន) គោលនយោបាយដែល

កំណត់ឲ្យប្រើភាសាអង់គ្លេសនិងភាសាអ៊ូឌូជាភាសាផ្លូវការបានដាក់សម្ពាធយ៉ាងខ្លាំងទៅលើភាសាផ្សេងៗទៀត រហូតដល់មានភាសាតូចតាចមួយចំនួនបានប្រឈមមុខនឹងការបាត់បង់។

## ៤_ភាសាប្រើក្នុងគោលនយោបាយអប់រំនិងអនុវត្តក្នុងតំបន់អាស៊ីកណ្តាល

### ប្រទេសកាហ្សាក់ស្ថាន (Kazakhstan)

ក្នុងប្រទេសកាហ្សាក់ស្ថានមានប្រជាជន ៤៨% ជាជនជាតិកាហ្សាក់ស្ថាននិង ៣៤% ជាជនជាតិរុស្ស៊ី ក្រៅពីនេះមាន ១២០ សញ្ជាតិថែមទៀតដែលក្នុងនោះមានប្រជាជនអ៊ុយក្រែនជាង ៨០០,០០០នាក់ ប្រជាជនអាល្លឺម៉ង់ ៥០០,០០០នាក់ ប្រជាជនអ៊ូប៊ិក្ស (Uzbeks) ៤០០,០០០នាក់ និងប្រជាជនតាតាស (Tatars) ជាង ៣០០,០០០នាក់។ ភាសាកាហ្សាក់ (Kazakh) ជាភាសាជាតិ ហើយភាសារុស្ស៊ីជាភាសាផ្លូវការ។ មានសាលាមធ្យមសិក្សាចំណេះទូទៅ ៣៦៤៧ កន្លែងត្រូវជា ៤៥% បានប្រើភាសាកាហ្សាក់ក្នុងការបង្រៀន។ សាលា ២១២២ កន្លែងប្រើភាសារុស្ស៊ីត្រូវជា ២៦% និងសាលា ២០៦៩ កន្លែងប្រើទាំងភាសាកាហ្សាក់ទាំងភាសារុស្ស៊ីត្រូវជា ២៥%។ មានសាលាមធ្យមសិក្សា ៤% ជាសាលាថ្នាក់ជាតិបានប្រើភាសាអ៊ុយក្រែន ភាសាអ៊ុយហ្គួរ (Uighur) ភាសាតាហ្ស៊ីក (Tajik) និងភាសាអ៊ុយប៊ែក (Uzbec) ជាភាសាប្រើក្នុងការបង្រៀន។



### ប្រទេសគៀស៊ីស្ថាន (Kyrgyzstan)

ភាសាគៀហ្ស៊ីស (Kyrgyz) និងភាសារុស្ស៊ីជាភាសាផ្លូវការនៅក្នុងប្រទេសគៀស៊ីស្ថាន។ ក្នុងឆ្នាំ ២០០១ ច្បាប់ប្រទេសគៀស៊ីស្ថានបានចេញប្រកាសឲ្យប្រើភាសារុស្ស៊ីជាភាសាផ្លូវការហើយមានឋានៈតាមផ្លូវការស្មើនឹងភាសាគៀហ្ស៊ីស ។ ប្រជាជន ៥២% ជាជនជាតិគៀហ្ស៊ីស ១,៨% ជាជនជាតិរុស្ស៊ី (Russian) ១,៣% ជាជនជាតិអ៊ុយប៊ែក ៣% ជាជនជាតិអ៊ុយក្រែន ២% ជាជនជាតិអាល្លឺម៉ង់និង ១២% ជាជនជាតិផ្សេងទៀត។ នៅតាមសាលាមានប្រើភាសាគៀហ្ស៊ីស ៦៦% ភាសារុស្ស៊ី ៧% ភាសាអ៊ុយប៊ែក ៧% និងការប្រើភាសារុស្ស៊ីជាមួយភាសាគៀហ្ស៊ីសមាន ២០% ក្នុងការបង្រៀន។

### ប្រទេសតាហ្ស៊ីគីស្ថាន (Tajikistan)

ភាសាតាហ្ស៊ីក (Tajik) ជាភាសាជាតិរបស់ប្រទេសតាហ្ស៊ីគីស្ថាន (Tajikistan) ហើយភាសារុស្ស៊ីជាភាសាដែលបានប្រើសម្រាប់ទំនាក់ទំនងរវាងជនជាតិភាគតិច។ ក្រុមជនជាតិភាគតិចទាំងអស់មានសិទ្ធិនិយាយ

ភាសាកំណើតរបស់ខ្លួន។ ភាសាតាហ្សីកនិងភាសារុស្ស៊ីជាភាសាប្រើក្នុងសារព័ត៌មានយ៉ាងទូលំទូលាយ។ សាលារៀនភាគច្រើនប្រើភាសាតាហ្សីកនិងភាសារុស្ស៊ីក្នុងការបង្រៀន។ ទោះជាយ៉ាងណាក្តីនៅមានសាលាសម្រាប់ជនជាតិភាគតិចមួយចំនួនមានប្រើភាសាអ៊ូប៊ិក្ស ភាសាកាហ្សាក់ ភាសាទើកម៉េន និងភាសាផ្សេងៗទៀត។ មានសិស្សមធ្យមសិក្សា ៧៣% បានទទួលការអប់រំជាភាសាតាហ្សីក ២៤% ជាភាសាអ៊ូប៊ិក្ស ហើយ ២% ជាភាសារុស្ស៊ីនិងសិស្សដទៃទៀតបានទទួលការអប់រំនៅតាមសាលាដោយប្រើភាសាគៀហ្សីស ភាសាកាហ្សាក់ និងភាសាទើកម៉េន ។

## ប្រទេសអ៊ូបេគីស្ថាន (Uzbekistan)

ប្រទេសអ៊ូបេគីស្ថាន (Uzbekistan) ជាប្រទេសមានជនជាតិភាគតិចច្រើននិងជាប្រទេសដែលប្រើភាសាច្រើនជាង ១០០ ភាសា។ បទប្បញ្ញត្តិរដ្ឋធម្មនុញ្ញប្រទេសអ៊ូបេគីស្ថានបានធានាឲ្យមានភាពស្មើគ្នាខាងផ្លូវច្បាប់ សិទ្ធិសេរីភាពនិងឱកាសដោយមិនគិតភេទ ពូជសាសន៍ ជនជាតិ ភាសា សាសនា វណ្ណៈសង្គម ជំនឿ ឋានៈសង្គមឬឋានៈបុគ្គល (មាត្រា ១៨)។ ការផ្តល់ការអប់រំដល់ក្មេងៗជនជាតិភាគតិចគឺជាបញ្ហាគោលនយោបាយដ៏សំខាន់មួយរហូតមកដល់ពេលនេះ។ រដ្ឋាភិបាលបានរក្សានូវការប្តេជ្ញាចិត្តខាងនយោបាយរបស់ខ្លួនក្នុងការផ្តល់ការអប់រំមូលដ្ឋានដោយប្រើភាសាជាតិ ៧ ភាសា ដែលរួមមានទាំងភាសាអ៊ូប៊ិក្សផង។ នាពេលបច្ចុប្បន្ន សាលាជាង ១០% ក្នុងប្រទេសអ៊ូបេគីស្ថានផ្តល់ការបង្រៀនជាភាសាជនជាតិភាគតិចភាសារុស្ស៊ី ភាសាកាហ្សាក់ ភាសាតាហ្សីក ភាសាការាក់កាល់ប៉ាក់ (Karakalpak) ភាសាទើកម៉េន និងភាសាគៀហ្សីសមានសិស្សចុះឈ្មោះចូលរៀនទាំងអស់ប្រហែល ១៥% ក្នុងការអប់រំជាមូលដ្ឋាន។

# ៥_ភាសាប្រើក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់ប៉ាស៊ីហ្វិក

## ប្រទេសប៉ាពួញូហ្គីណេ (Papua New Guinea)

ប្រទេសប៉ាពួញូហ្គីណេមានភាសាប្រហែលជា ៨៥០ ភាសាហើយការអប់រំនៅមត្តេយ្យសិក្សាគឺធ្វើឡើងដោយប្រើភាសាចំនួន ៣៥០ ទៅ ៤០០ ភាសា។ ប្រទេសនេះជាប្រទេសដែលប្រើប្រាស់ភាសាតាមតំបន់យ៉ាងទូលំទូលាយជាងគេក្នុងពិភពលោក។ ពីដើមឡើយគេប្រើភាសាអង់គ្លេសក្នុងការបង្រៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ប៉ុន្តែក្រោយមកប្រព័ន្ធអប់រំនោះត្រូវបានកែទម្រង់ដោយផ្អែកលើបទពិសោធន៍ជាវិជ្ជមាននៃការប្រើប្រាស់ភាសាក្នុងស្រុកនៅក្នុងការអប់រំក្រៅប្រព័ន្ធ។ នៅក្នុងប្រព័ន្ធអប់រំថ្មីនេះ ការអប់រំ ៣ ឆ្នាំដំបូងត្រូវធ្វើឡើងជាភាសាកំណើតរបស់សិស្ស។ ចំណែកភាសាអង់គ្លេសត្រូវបានគេបង្រៀននៅថ្នាក់ក្រោយមកទៀត។ សាលាបឋមសិក្សាជាច្រើនដែលប្រើភាសាតាមតំបន់គឺដំណើរការដោយសហគមន៍តាមតំបន់នោះ។ ជោគជ័យនៃការប្រើភាសាតាមតំបន់ក្នុងការអប់រំ គឺបណ្តាលមកពីការចូលរួមយ៉ាងសកម្មរបស់សហគមន៍ វិមជ្ឈការខ្លឹមសារបង្រៀនទាក់ទងទៅនឹងសហគមន៍ ការចំណាយមានប្រសិទ្ធភាពនិងការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលនានា។

# ឯកសារយោង


Alidou, Boly, A Brock-Utne, B., Diallo, Y.S, Heugh, K and Wolff, H. E. 2006 *Optimizing Learning and Education in Africa: The Language Factor. A Stock Taking Research on Mother Tongue and Billingual Education in Sub-Saharan Africa.* Paris, Association for the Development of Education in Africa (ADEA) www.adeanet.org/biennial2006/doc/document/B3_1_MTBLE_en.pdf (Accessd 17 November 2006)

Benson, C. 2005 *Mother Tongue-based Teaching and Education for Girls.* Bangkok, UNESCO http:/unesco.org/images/0014/001420/142079e.pdf (Accessed on 17 November 2006)

Cummins, J. 2000. Bilingual Chidren's Mother Tongue: Why is it Important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed 0n 17 November 2006)

Delpit. L.D. and Kemelfield, G. 1985. *An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province.* ERU Report No. 51 Waigani, Papua New Guinea, University of Papua New Guinea.

Department of Education. 1991. *Education Sector Review.* Waigani, Papua New Guinea, Department of Education.

Dutcher, N. 2004. *Expanding Education/Opportunities in Linguistically Diverse Countries.* Washington D.C., Center of Applied Linguistics. http://www.cal.org/resources/pubs/fordreport_040501.pdf (Accessed on 17 November 2006)

Gharagedaghi, J. 1986. *A Prologue to National Development Planning.* New York, Greewood Press.

Grin, F. Economic Considerations in Language Policy. 2005. Ricento, T. (ed). 2005. *An introduction to Language Policy:* Theory and Method. Oxford, Basil Blackwell.





Jhingran, D.2005. *Language Disadvantage. The Learning Challenge in Primary Education.* New Delhi: A. P.H. Publishing.

Malone, S. 2005. Planning community-based education programs in minority language communities. Resource manual for mother tongue speakers of minority languages engaged in planning and implementing education programs in their own communities.

Shaeffer, S. 2003. (7-9 November) *Language Development and Language Revitalization: An Education Imperative in Asia.* International Conference on Language Development, LanguageRevitalization and Multilingual Education. Bangkok, Thailand. http://www.sil.org/asia/idc/plenary_papers/sheldon_shaeffer.pdf (Accessed on 17 November 2006)

UNESCO. 2000. *The EFA 2000 Assessment: Papua New Guinea Country Report.* http://www2.unesco.org/wef/countryreports/papua_new_guinea/contents.html (Accessed on 17 November 2006)

UNESCO. 2003. *Education in a Multilingual World.* Paris, UNESCO. http://unesdocunesco.org/images/0012/001297/129728e.pdf (Accessed on 17 November 2006)
Vawda, A.Y. and Patrinos, H. A. 1998. *Cost of Producing Education Materials in Local Language.* Washington D.C.: World Bank.

Wako, J. 1997. *The Value of Traditional Knowledge in the 21 st Century.* Waigani Seminar. Waigani, Papua New Guinea, University of Papua New Guinea. http://www.pngbuai.com/600 technology/information/waigani/w97-keynote.html (Accessed on 17 November 2006)

Waters, G., Dondorp, A., Stillings, L., Wemin, J., Keruwa, R., Stefaniw, R. and Thomas, S. 1995. *A survey of Vernacular Education Programming at the provincial level within Papua New Guinea.* Ukarumpa, Papua New Guinea, SIL International.

## ឯកសារយោង


Alidou, Boly, A Brock-Utne, B., Diallo, Y.S, Heugh, K and Wolff, H. E. 2006 *Optimizing Learning and Education in Africa: The Language Factor. A Stock Taking Research on Mother Tongue and Billingual Education in Sub-Saharan Africa.* Paris, Association for the Development of Education in Africa (ADEA) www.adeanet.org/biennial2006/doc/document/B3_1_MTBLE_en.pdf (Accessd 17 November 2006)

Benson, C. 2005 *Mother Tongue-based Teaching and Education for Girls.* Bangkok, UNESCO http:/unesco.org/images/0014/001420/142079e.pdf (Accessed on 17 November 2006)

Cummins, J. 2000. Bilingual Chidren's Mother Tongue: Why is it Important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed 0n 17 November 2006)

Delpit. L.D. and Kemelfield, G. 1985. *An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province.* ERU Report No. 51 Waigani, Papua New Guinea, University of Papua New Guinea.

Department of Education. 1991. *Education Sector Review.* Waigani, Papua New Guinea, Department of Education.

Dutcher, N. 2004. *Expanding Education/Opportunities in Linguistically Diverse Countries.* Washington D.C., Center of Applied Linguistics. http://www.cal.org/resources/pubs/fordreport_040501.pdf (Accessed on 17 November 2006)

Gharagedaghi, J. 1986. *A Prologue to National Development Planning.* New York, Greewood Press.

Grin, F. Economic Considerations in Language Policy. 2005. Ricento, T. (ed). 2005. *An introduction to Language Policy:* Theory and Method. Oxford, Basil Blackwell.

Jhingran, D.2005. *Language Disadvantage. The Learning Challenge in Primary Education.* New Delhi: A. P.H. Publishing.

Malone, S. 2005. Planning community-based education programs in minority language communities. Resource manual for mother tongue speakers of minority languages engaged in planning and implementing education programs in their own communities.

Shaeffer, S. 2003. (7-9 November) *Language Development and Language Revitalization: An Education Imperative in Asia.* International Conference on Language Development, LanguageRevitalization and Multilingual Education. Bangkok, Thailand. http://www.sil.org/asia/idc/plenary_papers/sheldon_shaeffer.pdf (Accessed on 17 November 2006)

UNESCO. 2000. *The EFA 2000 Assessment: Papua New Guinea Country Report.* http://www2.unesco.org/wef/countryreports/papua_new_guinea/contents.html (Accessed on 17 November 2006)

UNESCO. 2003. *Education in a Multilingual World.* Paris, UNESCO. http://unesdocunesco.org/images/0012/001297/129728e.pdf (Accessed on 17 November 2006)

Vawda, A.Y. and Patrinos, H. A. 1998. *Cost of Producing Education Materials in Local Language.* Washington D.C.: World Bank.

Wako, J. 1997. *The Value of Traditional Knowledge in the 21 st Century.* Waigani Seminar. Waigani, Papua New Guinea, University of Papua New Guinea. http://www.pngbuai.com/600 technology/information/waigani/w97-keynote.html (Accessed on 17 November 2006)

Waters, G., Dondorp, A., Stillings, L., Wemin, J., Keruwa, R., Stefaniw, R. and Thomas, S. 1995. *A survey of Vernacular Education Programming at the provincial level within Papua New Guinea.* Ukarumpa, Papua New Guinea, SIL International.




*Source:* www.ethnologue.com

## គណៈកម្មការរៀបចំ

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| លោក កុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អ្នកស្រី ស៊ុន ឡេ | អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការយូណេស្កូ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក ឡុង សុជាត | មន្ត្រីការិយាល័យក្រោយអក្ខរកម្ម |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| អ្នកស្រី លី ខេង | មន្ត្រីការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នកផ្ទៀងផ្ទាត់ និងកែសម្រួល**

| | |
|---|---|
| លោក មោគ គឿន | អនុប្រធានការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| លោក តាន់ ដន | ជំនួយការកម្មវិធីអប់រំនៃអង្គការយូណេស្កូ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នករចនាអត្ថបទ**

| | |
|---|---|
| លោក ឈិន វ៉ិត | ប្រធានការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| អ្នកស្រី ទី វ៉ាដា | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |


បានទទួលការអនុញ្ញាតឲ្យបោះពុម្ព និង ប្រើប្រាស់ពីក្រសួងអប់រំ យុវជន និង កីឡា
តាមរយៈប្រកាសលេខ ៥១ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។


Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

Japanese Funds-in-Trust

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

## សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ



ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសារួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន


បាងកក : យូណេស្កូបាងកក ២០០៧

សៀវភៅ ៥ ក្បាល

1_ ទស្សនៈទូទៅនៃឯកសារជំនួយ 2_ភាសាប្រើប្រាស់ក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក 3_សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ 4_សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី 5_សៀវភៅសម្រាប់សមាជិកសហគមន៍

ISBN 92-9223-110-3



© UNESCO 2007



បានបោះពុម្ពផ្សាយដោយ

ការិយាល័យអប់រំអង្គការ UNESCO ប្រចាំតំបន់អាស៊ី_ប៉ាស៊ីហ្វិក

អាសយដ្ឋាន: 920 Sukhumvit Road, Prakanong

ទីក្រុងបាងកក ១០១១០.ប្រទេសថៃ

បានបកប្រែនិងកែសម្រួលពីច្បាប់ដើម *(ភាសាអង់គ្លេស)*



ឯកសារនិងរូបភាពទាំងអស់ដែលយកមកប្រើក្នុងការបោះពុម្ពផ្សាយនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុងឬតំបន់ណាមួយឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី
# ការលើកកម្ពស់ការអប់រំពហុភាសា
## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន
## សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ

# សៀវភៅសម្រាប់អ្នកសាងគោលនយោបាយ



## សេចក្តីផ្តើម

ចាប់តាំងពីអង្គការ UNESCO បានប្រារព្ធកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ ១៩៩០ មក រដ្ឋាភិបាលជាច្រើនបានបង្កើនកិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំរបស់ក្មេងៗ និងមនុស្សពេញវ័យនៅក្នុងប្រទេសរបស់ខ្លួន។ ទោះបីតម្រូវការទាំងនេះ ត្រូវបានបំពេញខ្លះរួចក៏ដោយ ក៏នៅមានកង្វះការយកចិត្តទុកដាក់ឲ្យបានពេញលេញទៅលើស្ត្រី កុមារី ប្រជាជនក្រីក្រ មនុស្សដែលមានតម្រូវការពិសេស ដូចជាអ្នកផ្ទុកមេរោគអេដស៍ អ្នកនិយាយភាសាដែលគេមិនសូវចាប់អារម្មណ៍ ឬនិយាយភាសាជនជាតិភាគតិចជាដើម ។

អ្នកសិក្សាទាំងឡាយដែលមិនចេះភាសាផ្លូវការ គឺចាញ់ប្រៀបគេណាស់នៅពេលពួកគេចូលរៀន។

*ការពិតមួយដែលមិនទាន់ត្រូវបានគេទទួលស្គាល់ជាទូទៅនៅឡើយគឺ ការសិក្សាដោយប្រើភាសាមួយដែលមិនមែនជាភាសាកំណើតរបស់សិស្សមិនគ្រាន់តែផ្តល់នូវការលំបាកទ្វេគុណក្នុងការរៀនភាសាថ្មីប៉ុណ្ណោះទេ ថែមទាំងជាការលំបាកក្នុងការរៀនយកចំណេះដឹងថ្មីមួយដែលមាននៅក្នុងភាសាថ្មីនោះទៀត។ បញ្ហាប្រឈមមុខនេះកាន់តែធ្ងន់ធ្ងរឡើងៗចំពោះក្រុមមុខសញ្ញាខ្លះដែលស្ថិតនៅក្នុងស្ថានភាពលំបាករួចទៅហើយ ដូចជាអ្នកមិនចេះអក្សរ ជនជាតិភាគតិច និងជនភៀសខ្លួនជាដើម។*[១]"

វិធីល្អបំផុតដើម្បីចៀសវាងការលំបាកទាំងនេះគឺត្រូវប្រើ : "ការអប់រំពហុភាសាដោយផ្អែកលើភាសាកំណើត"។ ក្នុងកម្មវិធីអប់រំពហុភាសា សិស្សប្រើភាសាកំណើតសម្រាប់រៀននៅថ្នាក់ដំបូង និងរៀនភាសាផ្លូវការជាមុខវិជ្ជាមួយដែរ។ នៅពេលដែលសិស្សបង្កើនសមត្ថភាពក្នុងការនិយាយ អាន និងសរសេរភាសាជាតិ គ្រូទាំងឡាយចាប់ផ្តើមប្រើប្រាស់ភាសានេះ *(ភាសាជាតិ)* សម្រាប់បង្រៀនមុខវិជ្ជាផ្សេងៗ។ កម្មវិធីអប់រំពហុភាសាដែលល្អបំផុត គឺលើកទឹកចិត្តអ្នកសិក្សាឲ្យប្រើភាសាទាំងពីរសម្រាប់ទំនាក់ទំនង និងសម្រាប់រៀននៅបឋមសិក្សា។

ការទទួលស្គាល់របស់អង្គការ UNESCO អំពីទំនាក់ទំនងចាំបាច់រវាងភាសា និងការអប់រំ ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងគោលការណ៍ទាំង ៣ ក្នុងការគាំទ្រការអប់រំពហុភាសា ៖

1- UNESCO. 2003. Education in a Multilingual World. Paris, UNESCO.

១_ អង្គការ UNESCO គាំទ្រការបង្រៀនភាសាកំណើតជាមធ្យោបាយមួយសម្រាប់បង្កើនគុណភាពអប់រំ ចំណេះដឹង និងបទពិសោធន៍របស់គ្រូនិងសិស្ស ។

២_ អង្គការ UNESCO គាំទ្រការអប់រំពហុភាសានិងពីរភាសានៅគ្រប់កម្រិតអប់រំជាមធ្យោបាយធ្វើឲ្យមានសមភាពសង្គម និងសមភាពយេនឌ័រ ហើយជាកត្តាចាំបាច់សម្រាប់សង្គមដែលមានភាសាផ្សេងគ្នា ។

៣_ អង្គការ UNESCO គាំទ្រ និងចាត់ទុកភាសាជាសមាសភាគពិសេសនៃការអប់រំអន្តរវប្បធម៌ ក្នុងគោលបំណងជំរុញឲ្យមានការយល់ដឹងរវាងក្រុមមនុស្សខុសគ្នា និងធានាឲ្យបាននូវការគោរពសិទ្ធិគ្នាទៅវិញទៅមក។[២]

ផ្នែកផ្សេងៗទៀតនៃសៀវភៅនេះផ្តល់នូវព័ត៌មានបន្ថែមអំពីកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត។ សំណួរដែលគេសួរញឹកញាប់អំពីការអប់រំពហុភាសាត្រូវបានដាក់ជាចំណងជើងសម្រាប់ផ្នែកផ្សេងៗគ្នា។ ចម្លើយនៃសំណួរទាំងនេះមានបញ្ចូលនូវសេចក្តីដកស្រង់ពីអ្នកអប់រំ បុគ្គលិករដ្ឋាភិបាល អ្នកស្រាវជ្រាវ និងប្រជាជនជាច្រើនមកពីសហគមន៍ភាសាជនជាតិភាគតិចជុំវិញពិភពលោក ។



2. UNESCO. 2003 Education in a Multilingual World. Paris, UNESCO

# សំណួរ និងចម្លើយ

## ការអប់រំនិងភាសានៅក្នុងសហគមន៍ដែលនិយាយភាសាជនជាតិភាគតិច

*សំណួរទី១. តើស្ថានភាពអប់រំសម្រាប់សមាជិកសហគមន៍ដែលនិយាយភាសាជនជាតិភាគតិច ឬសហគមន៍ដែលនិយាយភាសាមិនសូវមានឥទ្ធិពលមានលក្ខណៈដូចម្តេច?*

សមាជិកជាច្រើនរបស់សហគមន៍ដែលនិយាយភាសាជនជាតិភាគតិច ឬសហគមន៍ដែលនិយាយភាសាមិនសូវមានឥទ្ធិពល ជាពិសេសអ្នកដែលកំពុងរស់នៅតាមតំបន់ដាច់ស្រយាលប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំង នៅពេលពួកគេព្យាយាមទទួលយកនូវការអប់រំប្រកបដោយគុណភាព។

- អ្នកខ្លះមិនដែលបានចូលរៀនទាល់តែសោះ អ្នកខ្លះទៀតបានចូលរៀនដែរ ប៉ុន្តែមិនមានគ្រូដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវឡើយ ។
- ទោះជាសាលាមានគ្រូគ្រប់ចំនួនក៏ដោយ ក៏គ្រូជាច្រើនប្រើភាសាមួយដែលអ្នកសិក្សាមិនអាចយល់បាន ។
- មេរៀននិងសៀវភៅសិក្សាផ្តោតលើវប្បធម៌ និងភាសារបស់ក្រុមនិយាយភាសាផ្លូវការ។ ក្នុងករណីនេះប្រសិនបើអ្នកសិក្សាមិនដែលយល់ពីវប្បធម៌នោះទេ ពួកគេនឹងមានការលំបាកណាស់ក្នុងការស្វែងយល់ពីគំនិតទាំងឡាយដែលពួកគេកំពុងសិក្សា។
- គ្រូដែលមកពីសង្គមប្រើភាសាផ្លូវការប្រហែលគិតថាសិស្សរៀនមិនងាយចេះ។ ពួកគេអាចនិងមិនយល់ ឬអាចមើលស្រាលលើវប្បធម៌និងភាសាដែលជាកេរដំណែលរបស់អ្នករៀនថែមទៀតផង។

សម្រាប់អ្នកសិក្សាទាំងនេះ ជារឿយៗសាលារៀនជាកន្លែងដែលគេមិនធ្លាប់ស្គាល់ បង្រៀនមេរៀនប្លែកៗដោយប្រើភាសាដែលគេមិនចេះ។ ដូចជាករណីត្រូវបានរៀបរាប់ដោយអ្នកអប់រំម្នាក់ដែលបានទស្សនាថ្នាក់រៀនមួយនៅសហគមន៍ដែលនិយាយភាសាជនជាតិភាគតិចនៅក្នុងប្រទេសឥណ្ឌា ដោយប្រើភាសាហិណ្ឌូជាភាសាសម្រាប់ការបង្រៀន ៖

*“ក្មេងៗហាក់ដូចជាមិនចាប់អារម្មណ៍លើការពន្យល់របស់គ្រូទាល់តែសោះ។ ពួកគេសម្លឹងមើលគ្រូភ្លឹះៗ ហើយពេលខ្លះសម្លឹងមើលអក្សរលើក្តារខៀន។ ជាក់ស្តែងជាងនេះទៅទៀត ពួកគេមិនអាចយល់ពីអ្វីដែលគ្រូកំពុងនិយាយ សូម្បីតែគ្រូបន្តពន្យល់ដោយលម្អិតក្នុងសម្លេងខ្លាំងៗក៏ដោយ ។”*

*ក្រោយមក ដោយធុញទ្រាន់ក្នុងការនិយាយហើយយល់ថាពួកក្មេងៗពិតជាមិនយល់អ្វីទាំងអស់នោះ គ្រូក៏ប្រាប់ឲ្យពួកគេចម្លងអក្សរនៅលើក្ដារខៀនទាំងអស់។ គ្រូបាននិយាយថា "សិស្សរបស់គាត់ពូកែកត់អក្សរពីក្ដារខៀនណាស់ ដល់ពេលឡើងថ្នាក់ទី ៥ ពួកគេអាចចម្លង និងទន្ទេញចម្លើយបានទាំងអស់។ ប៉ុន្តែមានតែសិស្សពីរនាក់ប៉ុណ្ណោះក្នុងចំណោមសិស្សថ្នាក់ទី ៥ អាចនិយាយភាសាហិណ្ឌូបាន"។*[៣]

ការបង្ខំពួកក្មេងៗឬមនុស្សពេញវ័យឲ្យចូលសាលាដែលប្រើភាសាមួយដែលពួកគេមិនចេះនិយាយនិងមិនយល់នោះមិនអាចជួយពួកគេឲ្យអភិវឌ្ឍសក្ដានុពលរបស់ខ្លួនឲ្យទៅជាសមាជិកមានប្រយោជន៍ក្នុងសង្គមឡើយ។ នៅពេលដែលមេរៀនច្លុះបញ្ចាំងតែពិភពខាងក្រៅសហគមន៍របស់ពួកគេហើយបំភ្លេចចោលនូវអ្វីៗដែលពួកគេដឹងនិងមានបទពិសោធន៍នោះបញ្ជាក់ថា ភាសា វប្បធម៌ និងបទពិសោធន៍ផ្ទាល់របស់ពួកគេមិនមានតម្លៃឡើយ។ នេះគឺជាវិធីនៃការរៀនសូត្រដែលបណ្ដាលឲ្យក្មេងៗបាត់បង់សេចក្ដីគោរពចំពោះសហគមន៍ឪពុកម្ដាយពួកគេនិងខ្លួនគេផ្ទាល់។



3. Jhingran, D. 2005 *Language Disadvantage. The learning challenge in primary Education.* New Delhi, A. P.A Publishing.

## សំណួរទី២. តើការអប់រំពហុភាសាផ្អែកលើភាសាកំណើត អាចដោះស្រាយបញ្ហាដូចដែលបានរៀបរាប់នៅ សំណួរទី ១ យ៉ាងដូចម្ដេចខ្លះ?

កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតជួយធ្វើឲ្យសិស្សចាប់ផ្ដើមការសិក្សារបស់ពួកគេដោយប្រើភាសាដែលគេចេះច្បាស់បំផុត។ ខណៈដែលគេប្រើភាសាកំណើតសម្រាប់ការសិក្សា ពួកគេអាចឈានទៅរៀនភាសាផ្លូវការហើយពួកគេក៏ចាប់ផ្ដើមរៀនពីទំនាក់ទំនងដោយប្រើភាសាថ្មីនេះ។ នៅពេលជាមួយគ្នានោះ គ្រូអាចជួយសិស្សឲ្យបង្កើនវាក្យស័ព្ទ (ជាភាសាថ្មីនោះ)[៤] ដើម្បីឲ្យគេអាចយល់និងនិយាយអំពីគំនិតអរូបីជាភាសាថ្មីថែមទៀត[៥]។ ក្នុងកម្មវិធីដែលល្អបំផុតគឺសិស្សបន្តអភិវឌ្ឍសមត្ថភាពទំនាក់ទំនងនិងរៀនដោយប្រើភាសាទាំងពីររហូតដល់ពួកគេរៀនចប់សាលាបឋមសិក្សា ។

"ជំហាន" ខាងក្រោមជួយពន្យល់អំពីដំណើរការរៀនភាសាក្នុងកម្មវិធីអប់រំពហុភាសាដែលល្អ :

បន្តអភិវឌ្ឍន៍ភាសាដើមកំណើតនិងភាសាទី ២ ដោយប្រើក្នុងការនិយាយផ្ទាល់មាត់និងដោយសរសេរ។ ប្រើភាសាទាំងពីរក្នុងការរៀននិងបង្រៀន

**ណែនាំបង្ហាញការអាននិងសរសេរជាភាសាទី ២[៥]**
បន្តអភិវឌ្ឍន៍ភាសាដើមកំណើត ផ្អែកនិយាផ្ទាល់មាត់និងសរសេរនិងភាសាទី ២ ផ្អែកនិយាយផ្ទាល់មាត់។ ចាប់ផ្ដើមប្រើប្រាស់ភាសាទី ២ ក្នុងការរៀននិងបង្រៀនដោយយកភាសាទី ១ ជាជំនួយ។

**ណែនាំបង្ហាញភាសាទី ២ ផ្អែកផ្ទាល់មាត់**
បន្តអភិវឌ្ឍន៍ភាសាដើមកំណើត ផ្អែកនិយាយផ្ទាល់មាត់និងសរសេរ
ប្រើភាសាកំណើតសម្រាប់ការរៀននិងបង្រៀន

**ណែនាំបង្ហាញការអាននិងសរសេរជាភាសាដើមកំណើត**
បន្តអភិវឌ្ឍន៍ភាសាដើមកំណើត ផ្អែកនិយាយផ្ទាល់មាត់
ប្រើភាសាកំណើតសម្រាប់ការរៀននិងបង្រៀន

**ពង្រឹងសមត្ថភាព និងទំនុកចិត្តជាភាសាដើមកំណើត**
(សម្រាប់កុមារដែលទើបចាប់ផ្ដើមចូលរៀន)
ប្រើភាសាកំណើតសម្រាប់ការរៀននិងបង្រៀន

4. This process is based on the educational principle that concepts in learned in one language are easily transferred to another language once the learners have developed the necessary vocabulary in the new language. (See Cummins, J. 2000. *Bilingual Chidren's Mother Tongue: Why is it important for Education?*)

5. Some researchers find that the L2 can be introduced early, as long as teachers continue to use the children's home languages as one of the of instruction throughout primary school.

*នៅពេលដែលក្មេងៗបន្តអភិវឌ្ឍសមត្ថភាពរបស់ពួកគេដោយប្រើពីរភាសា ឬច្រើនភាសានៅបឋមសិក្សា ពួកគេអាចបង្កើនចំណេះដឹងភាសាជ្រៅជ្រះ និងរបៀបប្រើប្រាស់វាឲ្យមានប្រសិទ្ធភាព។ ពួកគេមានការអនុវត្តបន្ថែម ដើម្បីចេះភាសាឲ្យបានជ្រៅជ្រះ។ ជាពិសេសនៅពេលដែលពួកគេចេះភាសាទាំងពីរ ពួកគេអាចប្រៀបធៀបនិងវិភាគអំពីវិធីរៀនសូត្រប្លែកៗគ្នាចំពោះភាសាទាំងពីរ។*[៦]

លក្ខណៈពិសេសនិងសំខាន់បំផុតនៃដំណើរការរៀនសូត្រនេះគឺ :

- ការអប់រំត្រូវចាប់ផ្ដើមជាមួយនឹងការប្រើអ្វីដែលសិស្សដឹង ពង្រឹងបន្ថែមលើភាសាវប្បធម៌ ចំណេះដឹងនិងបទពិសោធន៍របស់ពួកគេ នៅពេលដែលពួកគេចាប់ផ្ដើមចូលសាលារៀន
- អ្នកសិក្សាបង្កើនទំនុកចិត្តលើខ្លួនឯងបន្តិចម្ដងៗក្នុងការប្រើប្រាស់ភាសាថ្មី *(ភាសាផ្លូវការ)* មុនពេលដែលភាសានោះក្លាយទៅជាភាសាតែមួយសម្រាប់បង្រៀនមុខវិជ្ជាសិក្សា
- អ្នកសិក្សាទទួលបាននូវសមត្ថភាពប្រកបដោយគុណភាពកម្រិតខ្ពស់ក្នុងមុខវិជ្ជានីមួយៗ ពីព្រោះគ្រូបង្រៀនប្រើភាសាកំណើត ទន្ទឹមនឹងភាសាផ្លូវការដើម្បីជួយឲ្យពួកគេយល់អំពីខ្លឹមសារមេរៀន។





6. Cummins. J. 2000 *Bilingual Children's Mother Tongue: Why is it important for Education?* http://www.iteachilearn.com/cummins/mother.htm (Accessed on 17 November 2006)

## សំណួរទី ៣. តើការអប់រំពហុភាសាផ្អែកលើភាសាកំណើតមានទំនាក់ទំនងអ្វីខ្លះនិងភាពរីកចម្រើន ?

កម្មវិធីអប់រំដែលមិនបានរាប់បញ្ចូលប្រជាជនមួយចំនួនធ្វើឲ្យពួកគេទាំងនោះពិបាកទទួលយកតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍសហគមន៍ជាតិ ពីព្រោះការអប់រំរបៀបនេះ *“....ធ្វើឲ្យសិស្សទទួលបានតិចតួចនូវចំណេះដឹង ជំនាញនិងអត្តចរិតចាំបាច់ដើម្បីឲ្យពួកគេចូលរួមក្នុងការអភិវឌ្ឍសហគមន៍ឬការអភិវឌ្ឍជាតិ។”*[៧]

ការអប់រំសម្រាប់ការអភិវឌ្ឍទាមទារពិនិត្យឲ្យច្បាស់ថា អ្នកសិក្សាទាំងអស់ ទោះជាពួកគេនិយាយភាសាអ្វីក៏ដោយ ក៏ពួកគេអាចបង្កើនសក្តានុពលពេញលេញ និងអាចស្វែងរកសុខុមាលភាពសម្រាប់ខ្លួនក៏ដូចជាសម្រាប់សហគមន៍និងជាតិរបស់ពួកគេ ។

*“យើងជឿថា គោលដៅសំខាន់មួយរបស់ជាតិ គឺការជំរុញនិងលើកទឹកចិត្តដល់ការអភិវឌ្ឍនៃសមាជិកទាំងអស់របស់ខ្លួន....ការអភិវឌ្ឍជាតិគឺមិនមែនជាអ្វីដែលរដ្ឋាភិបាលអនុវត្តនោះទេ ប៉ុន្តែគឺជាការផ្តល់នូវសិទ្ធិនិងឱកាសឲ្យអ្នកថ្នាក់ក្រោមអនុវត្ត។”*[៨]

គ្រប់វប្បធម៌ទាំងអស់សុទ្ធតែមានយុទ្ធសាស្ត្រដើម្បីឲ្យមានការរស់នៅល្អបំផុតក្នុងសហគមន៍របស់គេ។ ហើយភាសាទាំងអស់សុទ្ធតែអាចបង្ហាញឲ្យឃើញនូវចំណេះដឹងនិងគតិបណ្ឌិតរបស់អ្នកនិយាយ។ ជាតិនឹងបានផលចំណេញនៅពេលដែលប្រជាជនមានប្រវត្តិ និងវប្បធម៌ផ្សេងៗគ្នា និយាយភាសាខុសគ្នានិងមានទស្សនៈខុសគ្នា មានការផ្លាស់ប្តូរគំនិតទៅវិញទៅមកនិងការកសាងផែនការមួយជាមួយគ្នាសម្រាប់អនាគតរួមគ្នា។ គោលបំណងយូរអង្វែងមួយរបស់កម្មវិធីពហុភាសានៅក្នុងសហគមន៍ប្រើភាសាជនជាតិភាគតិចគឺធ្វើឲ្យសមាជិករបស់ពួកគេមានចំណេះដឹង ជំនាញ និងកាន់តែមានទំនុកចិត្តដើម្បីចូលរួមជួយសហគមន៍និងការអភិវឌ្ឍប្រទេសជាតិ៖

*“ធនធានជាតិដ៏អស្ចារ្យជាងគេ គឺភាពសម្បូរបែបនៃវប្បធម៌ក្នុងប្រទេសយើង។ ភាពសម្បូរបែបមានន័យថា មានទស្សនៈច្រើន មានគំនិតច្នៃប្រឌិតច្រើននិងមានសមត្ថភាពកាន់តែល្អ ដើម្បីដោះស្រាយបញ្ហានឹងធ្វើការផ្លាស់ប្តូរ...។ ទីណាដែលគ្មានភាពសម្បូរបែបទេនោះ...ទីនោះសង្គមជាតិនឹងធ្លាក់ចុះខ្សោយនិងបែកបាក់។”*[៩]



7. Department of Education. 1991 *Education Sector Review.* Waigani, Papua New Guinea, Department of Education. The five million people of PNG speak over 800 distinct language Until 1993, English was the language of the formal education system. Recognizing the negative of English-only education the PNG government revised its primary education system in 1995. By 2005, mother tongue-based MLE programs had been established in over 400 of Papua Nrw Guinea's 800+ languages.

8. Gharagedaghi, J. 1986 *A prologue to National Development planning.* New York Greenwood Press.

9. Dr. John Waiko, Minister of Education PNG. 2001.

ការគាំទ្ររបស់រដ្ឋាភិបាលចំពោះកម្មវិធីអប់រំពហុភាសាបង្ហាញដល់ប្រជាពលរដ្ឋទាំងអស់ថា ភាសាជនជាតិភាគតិច និងអ្នកនិយាយភាសាទាំងនោះត្រូវបានឲ្យតម្លៃ។ កម្មវិធីអប់រំពហុភាសាគឺជា "ស្ពាន" ដ៏ល្អមួយរវាងភាសាកំណើតនិងភាសាផ្លូវការហើយអាចជួយពួកគេឲ្យបង្កើតនូវឯកភាពជាតិមួយដោយគ្មានការបង្ខិតបង្ខំឲ្យប្រជាជនបោះបង់កេរដំណែលវប្បធម៌និងភាសាសាស្ត្ររបស់ពួកគេ។ បទពិសោធន៍ទាំងឡាយជុំវិញពិភពលោកបានបង្ហាញថា ការប្រានចោលកេរដំណែល វប្បធម៌ និងភាសារបស់ប្រជាជនគឺជាបុព្វហេតុមួយនៃការបែកបាក់និងភាពចម្រូងចម្រាស់។ ការអប់រំពហុភាសានាំមកនូវឯកភាពជាតិតាមរយៈការធ្វើឲ្យមានភាពផ្សេងៗគ្នាជាជាងការយកអ្វីជំនួសភាពផ្សេងគ្នា។

### សំណួរទី ៤. តើការអប់រំពហុភាសាផ្អែកលើភាសាកំណើតនិងសមភាពយេនឌ័រមានទំនាក់ទំនងគ្នាដូចម្តេចខ្លះ ?

នៅឆ្នាំ ១៩៩៣ អ្នកស្រាវជ្រាវភាសាឈ្មោះក័រសុន(CorSon) បានរកឃើញថា មានមនុស្សបីក្រុមដែលត្រូវបានរងនូវអំពើអយុត្តិធម៌យ៉ាងខ្លាំងក្នុងគោលនយោបាយភាសានិងផែនការអប់រំ ពោលគឺក្រុមស្ត្រី កុមារី ក្រុមអ្នកក្រីក្រនិងក្រុមដែលមិនមានភាសាប្រើក្នុងរចនាសម្ព័ន្ធផ្លូវការ។ ភាពអយុត្តិធម៌នេះគឺមានច្រើនបំផុតចំពោះអ្នកដែលមានស្ថានភាពទាំងបីព្រមគ្នា។ ការស្រាវជ្រាវពីយេនឌ័របានបង្ហាញថា.....ដរាបណាកុមារីនិងស្ត្រីធ្វើការក្នុងផ្សារឬពេងចក្រនានា ពួកគេទំនងជាមិនបាននិយាយនិងស្តាប់ភាសាផ្លូវការទេ ពីព្រោះជីវិតរបស់ពួកគេមានព្រំដែនត្រឹមតែនៅក្នុងផ្ទះដែលជាកន្លែងដែលគេនិយាយភាសាកំណើត។ នេះមានន័យថា កុមារីមិនមានឱកាសច្រើនដូចក្មេងប្រុសទេ ដើម្បីយល់ដឹងអំពីការបង្រៀននៅតាមសាលា។ គួរឲ្យស្តាយភាពខុសគ្នានេះមិនត្រូវបានគេសង្កេតឃើញ ពីព្រោះក្មេងស្រីត្រូវបានគេផ្តល់ឱកាសបន្តិចបន្តួចក្នុងការបញ្ចេញមតិនិងត្រូវបានគេគិតថា បំពេញតួនាទីមិនល្អដូចក្មេងប្រុស។ ថ្វីបើមានការយល់ដឹងជាសកលកាន់តែច្រើនឡើងអំពីតម្រូវការក្នុងការសម្រេចឲ្យបានសមភាពយេនឌ័រក្នុងការអប់រំក៏ដោយ ក៏ក្មេងស្រីនៅតែមានគម្លាតឆ្ងាយជាងក្មេងប្រុស ពីព្រោះពួកគេត្រូវបានបដិសេធមិនឲ្យចូលរៀន ជាពិសេសគឺក្មេងស្រី ដែលមកពីសហគមន៍ជនជាតិភាគតិច។

ការអប់រំពហុភាសាផ្តល់ឱកាសច្រើនសម្រាប់ក្មេងស្រីទទួលយកការអប់រំល្អមួយ ។ ការអប់រំពហុភាសាផ្អែកលើភាសាកំណើតផ្តល់នូវប្រយោជន៍ជាក់លាក់សម្រាប់ស្ត្រីមកពីសហគមន៍ប្រើភាសាជនជាតិភាគតិច ៖

- ឪពុកម្តាយមានទំនុកចិត្តខ្លាំងក្នុងការបញ្ជូនកូនស្រីទៅសាលាដែលបង្រៀនជាភាសាកំណើត ហើយជនជាតិភាគតិចមានវប្បធម៌ដែលគេធ្លាប់ស្គាល់។ ឪពុកម្តាយក៏អាចដឹងព័ត៌មានអំពីការចុះឈ្មោះចូលរៀន និងដំណើរការសិក្សាជាភាសារបស់ពួកគេ។ ក្មេងស្រីប្រហែលជាត្រូវបានលើកទឹកចិត្តឲ្យបន្តការសិក្សា ប្រសិនបើភាសារបស់ពួកគេត្រូវបានបន្តប្រើជាមួយនឹងភាសាជាតិ ។




- កម្មវិធីអប់រំពហុភាសាជំរុញឲ្យមានទំនាក់ទំនងកាន់តែល្អរវាងឪពុកម្តាយសិស្សនិងគ្រូបង្រៀន ហើយអាចឲ្យពួកគេចូលរួមកាន់តែសកម្មក្នុងសកម្មភាពសាលា។ បញ្ហានេះបញ្ជាក់ច្បាស់ថា សាលាឆ្លើយតបទៅនឹងតម្លៃនិងតម្រូវការរបស់សហគមន៍។
- លោកគ្រូដែលមកពីសហគមន៍ភាសានិងវប្បធម៌ ដូចកូនសិស្សរបស់គាត់មិនអាចកេងយកផលប្រយោជន៍ពីសិស្សស្រីបានទេ ពីព្រោះពួកគេស្ថិតក្រោមសម្ពាធសង្គម។ គ្រូដែលមានទំនាក់ទំនងជាមួយនឹងគ្រួសារសិស្សទទួលបាននូវការទុកចិត្តកាន់តែខ្លាំងនិងស្ថិតក្រោមសម្ពាធសង្គមកាន់តែធ្ងន់ធ្ងរហើយអាចកាត់បន្ថយនូវឱកាសដែលពួកគេអាចរំលោភបំពានលើក្មេងស្រីបាន។
- ដោយហេតុថា ក្មេងស្រីអាចមានទំនាក់ទំនងដោយសេរីដូចក្មេងប្រុសក្នុងការប្រើភាសាកំណើតរបស់ខ្លួន ពួកគេអាចបង្ហាញនៅក្នុងថ្នាក់រៀនថា ពួកគេអាចរៀនពូកែដូចក្មេងប្រុស។ គ្រូក៏អាចយល់ថាខ្លួនគួរផ្តល់ឱកាសឲ្យក្មេងស្រីដូចក្មេងប្រុសដែរ ។
- ការផ្តល់ឱកាសឲ្យគ្រូបង្រៀនក្នុងសហគមន៍ដោយមានការបណ្តុះបណ្តាលបន្ថែមសម្រាប់ពួកគាត់ អាចលើកទឹកចិត្តស្ត្រីឲ្យក្លាយជាគ្រូបង្រៀន។ ឱកាសនេះផ្តល់ឲ្យសិស្សស្រីនូវមុខងារបន្ថែម ព្រមទាំងផ្តល់ឱកាសឲ្យស្ត្រីចេះរកប្រាក់ចំណូលបានច្រើនផងដែរ។[១០]

10. Benson, C. 2005 *Mother Tongue-based Teaching and Education for Girls.* Bangkok, UNESCO http://unesdoc.unecso.org/imagers/001/001420/142079e.pdf (Accessed on 17 November 2006)

## សំណួរទី ៥. ចំពោះការចំណាយថវិកា តើកម្មវិធីអប់រំពហុភាសាត្រូវចំណាយថវិកាច្រើនដើម្បីប្រតិបត្តិ និង ថែរក្សាឲ្យមាននិរន្តរភាពឬ ?

អ្នកខ្លះប្រឆាំងនឹងកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ពីព្រោះគេគិតថា ត្រូវចំណាយថវិកាច្រើនណាស់សម្រាប់ប្រតិបត្តិនិងរក្សានិរន្តរភាព។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានៅក្នុងវិស័យសេដ្ឋកិច្ចដោយវិភាគពីការចំណាយថវិកាទៅលើនយោបាយសាធារណៈទាក់ទងនឹងភាសាបានឲ្យដឹងថា កម្មវិធីអប់រំពហុភាសាត្រូវចំណាយថវិកាសមល្មម ជាពិសេសវាបានផ្តល់នូវប្រយោជន៍យូរអង្វែងនៅក្នុងអនាគត ៖

*"ចំណាយបន្ថែមដោយសារការប្តូរពីប្រព័ន្ធអប់រំភាសាតែមួយទៅជាប្រព័ន្ធអប់រំពីរភាសាមានចំនួនតិចជាងការគិតទុកជាមុន។ នៅទីណាដែលមានការវាយតម្លៃត្រូវបានធ្វើឡើង គេបានឲ្យដឹងថា ការចំណាយស្ថិតនៅក្នុងរង្វង់ ៣_៤% ប៉ុណ្ណោះ ពីព្រោះថា ទោះបីប្រព័ន្ធអប់រំនៅតែបន្តប្រើមួយភាសាក៏ដោយ ក៏ក្មេងគួរតែត្រូវបានគេបញ្ជូនឲ្យទៅរៀនដដែល។ ហេតុដូចនេះ ការចំណាយថវិកាបន្ថែមគឺមានចំនួនបន្តិចបន្តួចប៉ុណ្ណោះ។"*[១១]

ដូច្នេះជាជាងការចោទសួរអំពីការចំណាយក្នុងការអប់រំពហុភាសា យើងគួរសួរថា ៖ តើយើងត្រូវចំណាយប៉ុន្មានទៅលើប្រព័ន្ធអប់រំមួយដែលបរាជ័យចំពោះអ្នកសិក្សាដែលមិនចេះនិយាយភាសាជាតិ?

១០

ប្រសិនបើយើងប្រៀបធៀបការចំណាយលើការបង្កើតកម្មវិធីអប់រំពហុភាសាជាមួយនឹងការខាតបង់ផ្នែកសេដ្ឋកិច្ច_សង្គម ដែលបណ្តាលមកពីការអប់រំបរាជ័យឬការអប់រំមិនគ្រប់គ្រាន់សម្រាប់អ្នកសិក្សាជនជាតិភាគតិច គេឃើញច្បាស់ថា ការអប់រំពហុភាសាគឺជាការធ្វើវិនិយោគរយៈពេលវែងប្រកបដោយគតិបណ្ឌិត ដែលបានបង្ហាញនៅក្នុងការសិក្សារបស់ធនាគារពិភពលោកដូចខាងក្រោម ៖

*ការសិក្សាមួយដោយប្រើប្រាស់ទិន្នន័យរបស់ក្រសួងអប់រំប្រទេសហ្គាតេម៉ាឡាដោយប្រៀបធៀបអត្រាត្រួតថ្នាក់និងអត្រាបោះបង់ការសិក្សារបស់សិស្សជនជាតិម៉ៃយ៉ានពីរក្រុម (ក្រុមទី១ ប្រើកម្មវិធីអប់រំពហុភាសានិងក្រុមមួយទៀតប្រើកម្មវិធីអប់រំមួយភាសា)។ ការសិក្សានោះបានឲ្យដឹងថា "ការប្តូរប្រព័ន្ធអប់រំមួយភាសាមកប្រើពីរភាសាបានជួយកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលចំនួន ៥ លានដុល្លាអាមេរិក ដោយសារតែអត្រាត្រួតថ្នាក់របស់សិស្សបានធ្លាក់ចុះ។"*[១២]

ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសា

11. Grin, F. Economic Considerations in languages Policy 2005 Ricento, T. (ed). *2005 An introduction to language Policy: Theory and Method.* Oxford, Basil Blackwell.
12. Dutcher, N. 2004 *Expanding Education Opportunities in Linguistically Diverse Countries.* Washington D.C, Center of Applied Linguistics.http://www.cal.prg/resources/pubs/fordreport_040501.pdf (Accessd on 17 November 2006)

## សំណួរទី ៦. តើលក្ខណៈពិសេសរបស់កម្មវិធីអប់រំពហុភាសាដែលល្អនិងមាននិរន្តរភាពមានអ្វីខ្លះ?

កម្មវិធីអប់រំពហុភាសាតម្រូវឲ្យមានគំនិតច្នៃប្រឌិតនិងកិច្ចសហការក្នុងចំណោមបុគ្គលម្នាក់ៗ អង្គការនានា ក្រសួងនានានិងអ្នកចូលរួមទាំងអស់ក្នុងកម្មវិធី។ ដ្យាក្រាមខាងក្រោមបង្ហាញពី "សមាសភាគចាំបាច់" របស់កម្មវិធីដែលទទួលបានជោគជ័យ។[១៣]




ថ្វីបើអ្នកបង្កើតគោលនយោបាយមិនបានចូលរួមក្នុងការប្រតិបត្តិផ្ទាល់នៃកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ក៏ការគាំទ្រដ៏សកម្មរបស់ពួកគេគឺចាំបាច់សម្រាប់ជ័យជំនះរយៈពេលយូររបស់កម្មវិធី។ ការចូលរួមមួយក្នុងចំណោមការចូលរួមសំខាន់ៗបំផុតរបស់ពួកគេគឺការបង្កើតបរិយាកាសនយោបាយគាំទ្រកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតដ៏ល្អមួយ។ សព្វថ្ងៃនេះមានការទទួលស្គាល់ពីអន្តរជាតិច្រើនជាងពេលមុនថា គោលនយោបាយអប់រំនិងភាសាគឺចាំបាច់សម្រាប់ផ្តល់នូវដំណើរការសិក្សាប្រកបដោយគុណភាពល្អប្រសើរសម្រាប់ទាំងអស់គ្នាដោយរាប់បញ្ចូលអ្នកដែលនិយាយភាសាមិនមានឥទ្ធិពលផង។[១៤]

13. Adapted from Malone, S. 2005. Planning community-based education programs in minority language communities. Resource manual for mother tongue speakers of minoriry languages engaged in planning and implementing education programs in their own communities.

14. Alidou, H, Boly, A, Brock-Utne,B., Diallo,Y.S., Heugh, K, and Wolff, E. 2006 Optimizing Learning and Education in Africa: The language Factor. A Stock-Taking Research on Mother Tongue and Bilingual Education in Sub-Saharan Africa Paris, Association for the Development of Education in Africa (ADEA).
www.adeanet.org/biennial-2006/doc/document/B3_1_MTBLE_en.pdf (Accessed 17 Nocember 2006)

ទន្ទឹមនឹងការបង្កើតបរិយាកាសនយោបាយគាំទ្រ គោលនយោបាយសំខាន់បំផុតគឺជាគោលនយោបាយណាដែលចាត់ទុកការអប់រំពហុភាសាជាផ្នែកមួយនៃប្រព័ន្ធអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ហើយត្រូវមានសេចក្តីណែនាំច្បាស់លាស់សម្រាប់ការអនុវត្តនិងគាំទ្រផងដែរ។ សេចក្តីសម្រេចនៃគោលនយោបាយសំខាន់ៗរួមមាន ៖

- ការថ្លែងបញ្ជាក់ឲ្យច្បាស់ថា ថ្នាក់ណាខ្លះនៅឯសាលាបឋមសិក្សា ដែលត្រូវបញ្ចូលក្នុងកម្មវិធី។
- បង្កើតកម្មវិធីនៅក្នុងស្ថាប័នអប់រំដោយកសាងរចនាសម្ព័ន្ធសមស្របនៅក្នុងទីភ្នាក់ងាររដ្ឋាភិបាល ដើម្បីទទួលខុសត្រូវក្នុងការអនុវត្តនិងការគាំទ្រ ។
- បង្កើតប្រភពថវិកាសម្រាប់កម្មវិធីអប់រំពហុភាសា។

អ្នកកសាងគោលនយោបាយក៏អាចរួមចំណែកធ្វើឲ្យកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតទទួលបានជោគជ័យដោយជំរុញឲ្យចម្រើនឡើងនូវបរិយាកាសនៃកិច្ចសហប្រតិបត្តិការក្នុងចំណោមភ្នាក់ងារគាំទ្រនានាដូចជា រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សាកលវិទ្យាល័យនានានិងស្ថាប័នផ្សេងៗទៀតដោយធ្វើការជាមួយសហគមន៍តាមតំបន់ដើម្បីអភិវឌ្ឍនិងញុំាងឲ្យកម្មវិធីមាននិរន្តរភាព។

សកម្មភាពដែលចាំបាច់មួយទៀតគឺការផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់ការកសាងផែនការ ការអនុវត្តនិងការគាំទ្រកម្មវិធីអប់រំពហុភាសានៅថ្នាក់ជាតិ ថ្នាក់ខេត្តនិងថ្នាក់ឃុំ/សង្កាត់ឲ្យមាននិរន្តរភាព។

## សំណួរទី ៧. តើកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតអាចត្រូវបានបង្កើតឡើងដោយជោគជ័យ និង មាននិរន្តរភាពឬទេ?

ដោយមានការលើកទឹកចិត្តនិងការគាំទ្រពីអង្គការយូណេស្កូ (UNESCO) និងយូនីសេហ្វ (UNICEF) ភ្នាក់ងារទ្វេភាគីនិងពហុភាគី កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតត្រូវបានគេពង្រីកពាសពេញពិភពលោក។ នៅក្នុងតំបន់អាស៊ី_ប៉ាស៊ីហ្វិក កម្មវិធីត្រូវបានអនុវត្តឬកំពុងធ្វើផែនការនៅតាមបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសប៉ាពូញ៉ូហ្គីណេ ចិន ថៃ កម្ពុជា បង់ក្លាដេស ឥណ្ឌានិងកោះសូឡូម៉ុង។ យើងសង្ឃឹមថា កម្មវិធីទាំងនេះនឹងបំភ្លឺផ្លូវសម្រាប់អ្នកផ្សេងៗទៀត ដែលទទួលស្គាល់តម្រូវការកម្មវិធីអប់រំពហុភាសា ប៉ុន្តែមិនទាន់បានចាត់វិធានការណ៍ដើម្បីធានាថា ជនគ្រប់រូបនឹងទទួលបានការអប់រំសម្រាប់ទាំងអស់_គ្នាពិតប្រាកដនោះឡើយ។





## គោលការណ៍សំខាន់ៗរបស់អង្គការ UNESCO ស្ដីពីភាសានិងការអប់រំ

### គោលការណ៍ទី១

អង្គការ UNESCO គាំទ្រការបង្រៀនភាសាកំណើតជាមធ្យោបាយមួយសម្រាប់លើកស្ទួយគុណភាពអប់រំ បង្កើនចំណេះដឹងនិងបទពិសោធន៍របស់អ្នកសិក្សានិងគ្រូបង្រៀន។

១_ភាសាកំណើតគឺចាំបាច់ណាស់ក្នុងការបង្រៀនដំបូងនិងការបង្រៀនអក្ខរកម្ម ហើយគប្បីបន្តអនុវត្តរហូតដល់ថ្នាក់ខ្ពស់តាមដែលអាចធ្វើទៅបាន។

២_ចំណេះដឹងអក្ខរកម្មអាចនឹងបន្តបាន ប្រសិនបើមានការផ្គត់ផ្គង់គ្រប់គ្រាន់នូវសម្ភារអានសម្រាប់មនុស្សវ័យជំទង់និងមនុស្សពេញវ័យក៏ដូចជាសម្រាប់កុមារនៅតាមសាលាផងដែរ ។

៣_ផែនការអប់រំ (ទាំងអស់) គួរបញ្ចូលនៅក្នុងដំណាក់កាលនីមួយៗនូវការបណ្ដុះបណ្ដាលនិងហ្វឹក-ហាត់បន្ថែម ដើម្បីឲ្យគ្រូមានសមត្ថភាពពេញលេញព្រមទាំងមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីឲ្យពួកគាត់ស្គាល់ពីវប្បធម៌ របៀបរស់នៅរបស់ប្រជាជននិងអាចបង្រៀនដោយប្រើភាសាកំណើតរបស់សិស្សបាន ។



### គោលការណ៍ទី២

អង្គការ UNESCO គាំទ្រការអប់រំពីរភាសាឬពហុភាសានៅគ្រប់កម្រិតទាំងអស់នៃការអប់រំទុកដូចជាមធ្យោបាយមួយក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងសមភាពសង្គម ហើយក៏ជាធាតុបង្កដ៏សំខាន់នៃសង្គមដែលមានភាសាសម្បូរបែប ។

១_ទំនាក់ទំនង ការសម្ដែងនិងសមត្ថភាពក្នុងការស្ដាប់ ការសន្ទនាគួរត្រូវបានពង្រឹងដំបូងបង្អស់ដោយប្រើភាសាកំណើត បន្ទាប់មកដោយប្រើភាសាផ្លូវការឬភាសាជាតិនៅក្នុងប្រទេសក៏ដូចជាការប្រើភាសាបរទេសមួយឬច្រើន ។

២_គោលនយោបាយជាតិត្រូវតែរៀបចំឡើងឲ្យបានជាក់លាក់រឹងមាំ ដើម្បីលើកកម្ពស់ការបង្រៀនតាមប្រព័ន្ធបច្ចេកវិទ្យានិងដើម្បីសម្រួលការកសាងសម្ភារដែលគេអាចយកទៅប្រើប្រាស់ដោយសេរីក្នុងការអប់រំភាសានៅក្នុងទ្រង់ទ្រាយអេឡិចត្រូនិច ដើម្បីបង្កើនសមត្ថភាពនិងជំនាញរបស់មនុស្សនៅក្នុងតំបន់។

## គោលការណ៍ទី៣

អង្គការ UNESCO គាំទ្រនិងចាត់ទុកភាសាដូចជាសមាសភាគចាំបាច់នៃការអប់រំអន្តរវប្បធម៌ ក្នុងគោលបំណងជំរុញឲ្យមានការយល់ដឹងរវាងក្រុមប្រជាជនខុសៗគ្នា និងធ្វើឲ្យមានការគោរពសិទ្ធិគ្នាទៅវិញទៅមក។

១_វិធានការផ្សេងៗគួរត្រូវបានគេប្រើដើម្បីលុបបំបាត់ការរើសអើងក្នុងការអប់រំនៅគ្រប់កម្រិតដូចជា ការរើសអើងផ្អែកយេនឌ័រ ពូជសាសន៍ ភាសា សាសនា សញ្ជាតិ អាយុ ពិការភាពឬកត្តាដទៃទៀត។

២_សិទ្ធិទទួលការអប់រំត្រូវតែមានចំពោះជនជាតិភាគតិចក៏ដូចជាប្រជាជនអន្តោប្រវេសន្តោគ្រាម ហើយត្រូវបានគេគោរពយ៉ាងពេញលេញតាមរយៈ ៖

_ការប្រតិបត្តិសិទ្ធិដើម្បីរៀនសូត្រ ដោយប្រើភាសាកំណើតនិងប្រើប្រាស់ពេញលេញនូវវិធីសាស្ត្របង្រៀនឲ្យស្របតាមវប្បធម៌របស់ពួកគេ។

_ការបង្រៀនត្រូវធ្វើឡើងតាមរយៈភាសាកំណើតនិងភាសាជាតិឬភាសាផ្លូវការផង....ដូច្នេះ ជនជាតិភាគតិចនិងប្រជាជនអន្តោប្រវេសន្តោគ្រាមនឹងមានឱកាសដើម្បីចូលរួមក្នុងសហគមន៍។

៣_ការអប់រំគួរលើកកម្ពស់ការយល់ដឹងអំពីតម្លៃជាវិជ្ជមាននៃភាពសម្បូរបែបនៃវប្បធម៌និងភាសាសាស្ត្រ តាមរយៈ ៖

_កម្មវិធីត្រូវមានការដាក់បញ្ចូលជាវិជ្ជមាននិងពិតប្រាកដនូវប្រវត្តិ វប្បធម៌ ភាសានិងអត្តសញ្ញាណជនជាតិភាគតិចឬជនអន្តោប្រវេសន្តោគ្រាម ។

_សមាសភាគវប្បធម៌នៃភាសាសម្រាប់បង្រៀននិងរៀនគួរត្រូវបានពង្រឹងក្នុងគោលបំណងបង្កើនការយល់ដឹងជ្រាលជ្រៅអំពីវប្បធម៌ផ្សេងៗគ្នា។ ភាសាមិនមែនគ្រាន់តែជាលំហាត់យ៉ាងសាមញ្ញប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏ជាឱកាសដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពីរបៀបរស់នៅ អក្សរសាស្ត្រ និងទំនៀមទម្លាប់ផ្សេងៗគ្នា ។

# ឯកសារយោង


Alidou, Boly, A Brock-Utne, B., Diallo, Y.S, Heugh, K and Wolff, H. E. 2006 *Optimizing Learning and Education in Africa: The Language Factor. A Stock Taking Research on Mother Tongue and Billingual Education in Sub-Saharan Africa.* Paris, Association for the Development of Education in Africa (ADEA) www.adeanet.org/biennial2006/doc/document/B3_1_MTBLE_en.pdf (Accessd 17 November 2006)

Benson, C. 2005 *Mother Tongue-based Teaching and Education for Girls.* Bangkok, UNESCO http:/unesco.org/images/0014/001420/142079e.pdf (Accessed on 17 November 2006)

Cummins, J. 2000. Bilingual Chidren's Mother Tongue: Why is it Important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed 0n 17 November 2006)

Delpit. L.D. and Kemelfield, G. 1985. *An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province.* ERU Report No. 51 Waigani, Papua New Guinea, University of Papua New Guinea.

Department of Education. 1991. *Education Sector Review.* Waigani, Papua New Guinea, Department of Education.

Dutcher, N. 2004. *Expanding Education/Opportunities in Linguistically Diverse Countries.* Washington D.C., Center of Applied Linguistics. http://www.cal.org/resources/pubs/fordreport_040501.pdf (Accessed on 17 November 2006)

Gharagedaghi, J. 1986. *A Prologue to National Development Planning.* New York, Greewood Press.

Grin, F. Economic Considerations in Language Policy. 2005. Ricento, T. (ed). 2005. *An introduction to Language Policy:* Theory and Method. Oxford, Basil Blackwell.

Jhingran, D.2005. *Language Disadvantage. The Learning Challenge in Primary Education.* New Delhi: A. P.H. Publishing.

Malone, S. 2005. Planning community-based education programs in minority language communities. Resource manual for mother tongue speakers of minority languages engaged in planning and implementing education programs in their own communities.

Shaeffer, S. 2003. (7-9 November) *Language Development and Language Revitalization: An Education Imperative in Asia.* International Conference on Language Development, LanguageRevitalization and Multilingual Education. Bangkok, Thailand. http://www.sil.org/asia/idc/plenary_papers/sheldon_shaeffer.pdf (Accessed on 17 November 2006)

UNESCO. 2000. *The EFA 2000 Assessment: Papua New Guinea Country Report.* http://www2.unesco.org/wef/countryreports/papua_new_guinea/contents.html (Accessed on 17 November 2006)

UNESCO. 2003. *Education in a Multilingual World.* Paris, UNESCO. http://unesdocunesco.org/images/0012/001297/129728e.pdf (Accessed on 17 November 2006)

Vawda, A.Y. and Patrinos, H. A. 1998. *Cost of Producing Education Materials in Local Language.* Washington D.C.: World Bank.

Wako, J. 1997. *The Value of Traditional Knowledge in the 21 st Century.* Waigani Seminar. Waigani, Papua New Guinea, University of Papua New Guinea. http://www.pngbuai.com/600 technology/information/waigani/w97-keynote.html (Accessed on 17 November 2006)

Waters, G., Dondorp, A., Stillings, L., Wemin, J., Keruwa, R., Stefaniw, R. and Thomas, S. 1995. *A survey of Vernacular Education Programming at the provincial level within Papua New Guinea.* Ukarumpa, Papua New Guinea, SIL International.

## គណៈកម្មការរៀបចំ

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| លោក កុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អ្នកស្រី ស៊ុន ឡេ | អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការយូណេស្កូ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក ឡុង សុផាត | មន្ត្រីការិយាល័យក្រោយអក្ខរកម្ម |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| អ្នកស្រី លី ខេង | មន្ត្រីការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នកផ្ទៀងផ្ទាត់ និងកែសម្រួល**

| | |
|---|---|
| លោក មោគ គឿន | អនុប្រធានការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| លោក តាន់ ដន | ជំនួយការកម្មវិធីអប់រំនៃអង្គការយូណេស្កូ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នករចនាអត្ថបទ**

| | |
|---|---|
| លោក ឈិន វុិត | ប្រធានការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| អ្នកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |


បានទទួលការអនុញ្ញាតឱ្យបោះពុម្ព និង ប្រើប្រាស់ពីក្រសួងអប់រំ យុវជន និង កីឡា
តាមរយៈប្រកាសលេខ ៥១ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។


Japanese Funds-in-Trust

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## *រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន*

## សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី



ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសារួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

បាងកក : យូណេស្កូបាងកក ២០០៧
សៀវភៅ ៥ ក្បាល
1- ទស្សនៈទូទៅនៃឯកសារជំនួយ 2-ភាសាប្រើប្រាស់ក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក 3-សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ 4-សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី 5-សៀវភៅសម្រាប់សមាជិកសហគមន៍

ISBN 92-9223-110-3

© UNESCO 2007

បានបោះពុម្ពផ្សាយដោយ
ការិយាល័យអប់រំអង្គការ UNESCO ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក
អាសយដ្ឋាន: 920 Sukhumvit Road, Prakanong
ទីក្រុងបាងកក ១០១១០.ប្រទេសថៃ

បានបកប្រែនិងកែសម្រួលពីច្បាប់ដើម *(ភាសាអង់គ្លេស)*

ឯកសារនិងរូបភាពទាំងអស់ដែលយកមកប្រើក្នុងការបោះពុម្ពផ្សាយនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុងឬតំបន់ណាមួយ ឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ។

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## *រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន*

## សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី

# សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី

## សេចក្តីផ្តើម

*កុមារនៅក្រៅសាលាចំនួន ៥០% នៅលើពិភពលោករស់នៅតាមសហគមន៍ ដែលគេកម្រនឹងយកភាសាអប់រំទៅប្រើប្រាស់នៅតាមផ្ទះណាស់។ បញ្ហានេះគឺជាឧបសគ្គមួយយ៉ាងធំក្នុងការសម្រេចឲ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា ពោលគឺវាឆ្លុះបង្ហាញឲ្យឃើញនូវការអនុវត្តដែលមិនផ្តល់ផលប្រយោជន៍ ហើយដែលនាំឲ្យមានអត្រាចូលរៀនសូត្រមានកម្រិតទាប អត្រាធ្លាក់ថ្នាក់ និងអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់។[១]*

សៀវភៅស្តើងនេះនិយាយអំពីកម្មវិធីអប់រំ ដែលឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់អ្នកដែលនិយាយភាសាភាគតិច (ភាសាដែលគេមិនសូវប្រើប្រាស់) ពោលគឺអ្នកដែលគេបានពណ៌នាខាងលើ។ សៀវភៅស្តើងនេះប្រើប្រាស់សំណួរនិងចម្លើយដើម្បីពិភាក្សាអំពីប្រធានបទទូទៅដូចខាងក្រោមនេះ ៖

- ស្ថានភាពអប់រំសម្រាប់អ្នកដែលមិននិយាយភាសាផ្លូវការនៅតាមសាលា។
- និយមន័យ និងគោលបំណងនៃកម្មវិធី "អប់រំពហុភាសាផ្អែកលើភាសាកំណើត"។
- ដំណើរការកសាងមូលដ្ឋានគ្រឹះអប់រំដ៏រឹងមាំមួយជាភាសាកំណើតរបស់សិស្ស និងការកសាងស្ពានដ៏ល្អមួយឆ្ពោះទៅរកភាសាដែលគេប្រើនៅតាមសាលាជាផ្លូវការ។
- ការរៀបចំផែនការ និងការអនុវត្តកម្មវិធីអប់រំពហុភាសាដ៏មានប្រសិទ្ធភាព។

## សំណួរ និងចម្លើយ

### ភាសានិងការអប់រំនៅតាមសហគមន៍ដែលប្រើភាសាជនជាតិភាគតិច

*សំណួរទី ១ : តើការអប់រំសម្រាប់ប្រជាជនដែលមិនចេះនិយាយភាសាផ្លូវការរបស់សាលាមានស្ថានភាពយ៉ាងណា?*

អ្នកដែលមានភាសាកំណើតខុសពីភាសាដែលគេប្រើនៅសាលា អាចនឹងជួបការលំបាកមួយចំនួនក្នុងការសិក្សារបស់គេដូចជា ៖

1 World Bank. 2005. Education Notes. In Their Own Language: Education for All. Washington D.C World BanK. http://siteresources.worldbank.org/EDUCATION/Resources/Education-Notes/EdNotes_Lang_of_instruct.pdf (Accessed on 17 November 2006)



- ការរៀនភាសាមួយថ្មី និងការរៀនសូត្រអំពីចំណេះដឹងថ្មីៗជាភាសាថ្មីនោះ ។
- គ្រូភាគច្រើនមិននិយាយភាសាដូចសិស្សរបស់ខ្លួនឡើយ។
- សម្ភារៈបង្រៀននិងសៀវភៅសិក្សា(បើមាន) គឺប្រើប្រាស់ភាសាដែលសិស្សមិនយល់។ មេរៀនទាំងឡាយមិនទាក់ទងទៅនឹងចំណេះដឹង និងបទពិសោធន៍របស់សិស្សខ្លួនឡើយ ហើយមានការស្តែងឲ្យឃើញថា មានតែវប្បធម៌ និងភាសាផ្លូវការប៉ុណ្ណោះដែលគេនិយមប្រើជាងគេ និងមានសារៈសំខាន់ទៀតផង។
- ដោយហេតុថា សិស្សមិនចេះភាសាដែលប្រើតាមសាលា និងមិនយល់ពីខ្លឹមសារមេរៀន ពួកគេរៀនសូត្រពុំទទួលបានលទ្ធផលល្អទេ។ សិស្សទាំងនេះរៀនត្រួតថ្នាក់ និងចាប់ផ្តើមបាត់បង់ទឹកចិត្តបន្តិចម្តងៗ ហើយក៏នាំគ្នាចាកចោលសាលារៀនតែម្តងទៅ។

## *សំណួរទី ២ :   តើការអប់រំពហុភាសាផ្អែកលើភាសាកំណើតគឺជាអ្វី? ហើយវាអាចជួយដល់សិស្សឲ្យទទួលបានលទ្ធផលប្រសើរឡើងក្នុងការសិក្សាយ៉ាងដូចម្តេច?*

កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ចាប់ផ្តើមដោយប្រើភាសាដំបូងរបស់សិស្សដើម្បីជួយឲ្យពួកគេមានភាពស្ទាត់ជំនាញនិងមានទំនុកចិត្តក្នុងការប្រើប្រាស់ភាសាដែលប្រើតាមសាលាជាផ្លូវការ (និងភាសាបន្ថែមតាមតែគេត្រូវការ) ហើយលើកទឹកចិត្តពួកគេឲ្យប្រើប្រាស់ទាំងភាសាខ្លួនឯង ទាំងភាសាផ្លូវការដើម្បីសម្រេចឲ្យបានការអប់រំមួយប្រកបដោយគុណភាព។

កម្មវិធីអប់រំពហុភាសាដែលមានប្រសិទ្ធភាពជួយដោះស្រាយបញ្ហាអប់រំជាច្រើនដែលសិស្សជនជាតិភាគតិចបានជួបប្រទះក្នុងសាលារៀនដែលប្រើភាសាជាតិ។ ឧទាហរណ៍ ៖

***បញ្ហាក្នុងសាលារដ្ឋ :*** ខណៈដែលសិស្សចាប់ផ្តើមការសិក្សារបស់ខ្លួន ពួកគេរំពឹងទុកថា នឹងធ្វើការប្រាស្រ័យទាក់ទងគ្នាដោយប្រើភាសាដែលគេប្រើតាមសាលា ទោះបីជាពួកគេទាំងនោះមិនធ្លាប់បានប្រើភាសានេះពីមុនមកក៏ដោយ។

- ***ដំណោះស្រាយក្នុងការអប់រំពហុភាសា :*** សិស្សចាប់ផ្តើមសិក្សាដោយប្រើប្រាស់ភាសាកំណើតរបស់ខ្លួន តែប្រសិនបើមានសិស្សច្រើនក្រុមដែលនិយាយភាសាខុសគ្នានៅរៀនក្នុងថ្នាក់តែមួយនោះ គេអាចប្រើភាសាតំបន់បាន។

  ***បញ្ហាក្នុងសាលារដ្ឋ :*** សិស្សត្រូវសិក្សានូវគំនិតអរូបីជាច្រើន ដោយប្រើភាសាថ្មីមុនពេលដែលពួកគេចេះវាក្យស័ព្ទឲ្យបានច្រើនដើម្បីយល់នឹងអនុវត្តបាននូវគំនិតទាំងនោះ។

- ***ដំណោះស្រាយក្នុងការអប់រំពហុភាសា :*** នៅថ្នាក់ដំបូង គ្រូប្រើប្រាស់ភាសាដែលសិស្សចេះដើម្បីបង្រៀនអំពីគំនិតថ្មីៗ។ ទន្ទឹមនិងនេះសិស្សក៏ចាប់ផ្តើមរៀនភាសាថ្មី ជាដំបូងគឺរៀនបែបសន្ទនាផ្ទាល់មាត់ លុះក្រោយមកទើបរៀនអាននិងសរសេរ។

នៅពេលដែលសិស្សទទួលបានភាពស្ទាត់ជំនាញផ្នែកភាសាថ្មីហើយ គ្រូក៏ចាប់ផ្តើមប្រើភាសានោះសម្រាប់បង្រៀន។ ប៉ុន្តែគ្រូនៅតែបន្តប្រើប្រាស់ភាសាកំណើតដើម្បីបង្ហាញគំនិតថ្មីៗ រំលឹកឡើងវិញនូវអ្វីៗដែលសិស្សបានរៀនព្រមទាំងពន្យល់បន្ថែមបញ្ហាផ្សេងៗដែលពួកគេមិនទាន់យល់ ។

ក្នុងខណៈដែលសិស្សយល់ពីគំនិតក្នុងភាសាកំណើតរបស់ខ្លួនហើយនោះ ពួកគេក៏មិនចាំបាច់រៀនម្តងទៀតជាភាសាទី ២ ដែរ។ សិស្សគ្រាន់តែរៀនវាក្យស័ព្ទភាសាទី ២ ដើម្បីបង្ហាញនូវអ្វីដែលខ្លួនបានចេះដឹងនៅ

ក្នុងភាសានោះតែប៉ុណ្ណោះ។ ប្រការនេះជាមូលហេតុដែលគ្រូផ្នែកអប់រំពហុភាសាជាច្រើននាក់អះអាងថា *"ពេលនេះជាលើកទីមួយហើយដែលសិស្សរបស់យើងបានយល់នូវគំនិតទាំងនេះ"*។

កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ដែលត្រូវបានគ្រោងឡើងដោយការយកចិត្តទុកដាក់នោះ អាចអប់រំនិងបណ្តុះបណ្តាលឲ្យសិស្ស ៖

- *និយាយបានច្រើនភាសា* គឺថាពួកគេអាចប្រើប្រាស់ភាសាចាប់ពីចំនួនពីរឡើងទៅក្នុងការទំនាក់ទំនងប្រចាំថ្ងៃរបស់ខ្លួន និងក្នុងការរៀនសូត្រនៅសាលា។
- *មានចំណេះអក្ខរកម្មច្រើនផ្នែក* ពោលគឺពួកគេចេះអាន សរសេរជាភាសាទាំងអស់ដែលគេរៀនប្រកបដោយសមត្ថភាពខ្ពស់ ។
- *មានវប្បធម៌ចម្រុះ* ពោលគឺពួកគេមានភាពសុខស្រួលក្នុងការរស់នៅ និងធ្វើការងារជាមួយមនុស្សដែលមកពីសហគមន៍ខាងក្រៅហើយអាចថែរក្សានូវក្តីស្រឡាញ់ និងការគោរពចំពោះវប្បធម៌និងសហគមន៍របស់ខ្លួនផ្ទាល់។

## *សំណួរទី៣ : តើកុមារត្រូវឆ្លងកាត់ដំណាក់កាលអ្វីខ្លះដើម្បីឆ្លងពីភាសាកំណើតរបស់គេឆ្ពោះទៅរកភាសាផ្លូវការនៅសាលារៀន?*

ដំណើរការនិងជំហាននៃការអប់រំផ្នែកភាសាអាចប្រែប្រួលតាមតំបន់ អាស្រ័យលើថា តើគ្រូបានទទួលការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈរបស់ខ្លួននិងទទួលបានសម្ភារៈនិងឯកសារដែលមានគុណភាពខ្ពស់សរសេរជាភាសាកំណើតរបស់សិស្សនិងភាសាផ្លូវការ។ ទោះបីយ៉ាងណាក៏ដោយ បទពិសោធន៍នានាបានបង្ហាញថា នៅពេលដែលគ្រូបង្រៀនខ្វះការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ ខ្វះសម្ភារៈនិងឯកសារបង្រៀននិងពេលសិស្សមានការយល់ដឹងបន្តិចបន្តួចចំពោះភាសាថ្មី ប្រការដែលល្អបំផុតគឺគ្រូត្រូវបង្រៀនយឺតៗ ដើម្បីឲ្យសិស្សទទួលយកបាន។

គោលការណ៍ដ៏ចម្បងមួយនៃការអប់រំពហុភាសាផ្អែកលើភាសាកំណើតគឺសិស្សរៀនបានល្អប្រសើរជាទីបំផុតនៅពេលពួកគេប្រើប្រាស់នូវអ្វីដែលខ្លួនបានដឹងរួចហើយ (ចំណេះដឹងនិងបទពិសោធន៍របស់ខ្លួនតាមរយៈភាសាកំណើត)។ អាស្រ័យហេតុនេះ កម្មវិធីអប់រំពហុភាសាផ្តោតលើការយកចិត្តទុកដាក់ជួយសិស្សទាំងឡាយឲ្យកសាងមូលដ្ឋានគ្រឹះអប់រំតាមរយៈភាសាកំណើតរបស់ខ្លួន រួចសាងស្ពានមួយដ៏ល្អរឹងមាំដើម្បីឆ្លងទៅរកភាសាថ្មី។

***ការចាប់ផ្តើមដោយភាសាកំណើត :*** ក្នុងកម្មវិធីអប់រំពហុភាសាដែលល្អ សិស្សចាប់ផ្តើមកសាងមូលដ្ឋានគ្រឹះអប់រំដ៏រឹងមាំមួយនៅពេលដែលពួកគេចាប់ផ្តើមរៀនសូត្រដោយប្រើភាសាកំណើតរបស់ខ្លួន ពោលគឺភាសាដែលពួកគេនិយាយនិងយល់បានល្អជាងគេ។ មេរៀនទាំងឡាយបង្ហាញនូវប្រធានបទថ្មីៗដោយផ្សារភ្ជាប់ប្រធានបទទាំងនេះទៅនឹងចំណេះដឹងនិងបទពិសោធន៍របស់សិស្សផ្ទាល់។ ការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា មូលដ្ឋានគ្រឹះនៅក្នុងភាសាកំណើតនេះ គឺជាគន្លឹះសំខាន់ដើម្បីជួយដល់សិស្សឲ្យរៀនភាសាថ្មីបន្ថែមប្រកបដោយភាពជោគជ័យ។

*“កម្រិតនៃការអភិវឌ្ឍភាសាកំណើតរបស់កុមារគឺឆ្លុះបញ្ចាំងអំពីការអភិវឌ្ឍភាសាទី ២ របស់ពួកគេ: ...កុមារទាំងឡាយ...ដែលមានមូលដ្ឋានគ្រឹះរឹងមាំក្នុងភាសាកំណើតរបស់ខ្លួន គឺអាចអភិវឌ្ឍនូវសមត្ថភាពអក្ខរកម្មបានកាន់តែល្អថែមទៀតនៅក្នុងភាសាដែលប្រើប្រាស់តាមសាលា។”*[២]



***កសាងស្ពានឆ្ពោះទៅរកភាសាថ្មី :*** ដោយបានកសាងមូលដ្ឋានគ្រឹះអប់រំតាមរយៈភាសាកំណើតរបស់ខ្លួនរួចមក សិស្សទាំងឡាយក៏ចាប់ផ្តើមរៀនសូត្រភាសាថ្មី ជាដំបូងគឺរៀននិយាយ ក្រោយមកទើបរៀនសរសេរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេមិនគួរឈប់ប្រើប្រាស់ភាសាកំណើតរបស់ខ្លួនឡើយ ទោះបីខ្លួនទទួលបានសមត្ថភាពមូលដ្ឋាននៅក្នុងភាសាថ្មីនេះក៏ដោយ។ ពួកគេត្រូវបន្តប្រើប្រាស់ភាសាទាំងពីរនេះសម្រាប់ការរៀនសូត្រយ៉ាងហោចណាស់ឲ្យចប់បឋមសិក្សាដែរ ៖

2 Cummins, J. 2000. Bilinggual Children’s Mother Tongue: Why is it Important for Education? http://www.iteachilearn.com/cummins/mother.htm(Accessed on 17 November 2006)

*“នៅពេលកុមារបន្តអភិវឌ្ឍសមត្ថភាពរបស់ខ្លួនដោយប្រើភាសាពីរ (ឬច្រើនជាងនេះ) ក្នុងថ្នាំដែលខ្លួនរៀននៅបឋមសិក្សានោះ ពួកគេទទួលបានការយល់ដឹងអំពីភាសាកាន់តែជ្រាលជ្រៅថែមទៀត និងដឹងពីរបៀបប្រើប្រាស់វាឲ្យមានប្រសិទ្ធភាព។ ពួកគេមានការហ្វឹកហាត់កាន់តែច្រើនក្នុងការប្រើប្រាស់ភាសាជាពិសេសគឺនៅពេលដែលខ្លួនអភិវឌ្ឍចំណេះអក្ខរកម្មទាំងពីរភាសាហើយអាចធ្វើការប្រៀបធៀបនិងរកចំណុចខុសគ្នានៃភាសាទាំងពីរ។”*[៣]

យើងអាចកំណត់ដំណាក់កាលជាទូទៅចំនួន ៤ សម្រាប់ការអប់រំភាសា ដោយចាប់ផ្តើមពីភាសាកំណើតរបស់សិស្សរួចបន្ថែមភាសាថ្មី ជាដំបូងដោយផ្ទាល់មាត់ លុះក្រោយមកជាទម្រង់សរសេរ។ (ដំណាក់កាលបន្ថែមអាចនឹងត្រូវការសម្រាប់ភាសាថ្មីនីមួយៗដែលត្រូវបានគេបញ្ចូលបន្ថែម)។ ដំណាក់កាលនីមួយៗប្រើប្រាស់នូវដំណាក់កាលណាដែលកើតមុនធ្វើជាមូលដ្ឋាន ហើយគ្រូត្រូវពង្រឹងនូវអ្វីដែលកុមារបានរៀនសូត្ររួចហើយ។




ដំណាក់កាលនៃការអប់រំភាសានៅកម្រិតបឋមសិក្សា[៥]

3 Cummins, 2000

4 L1 = the children's first/home/heritage language, the language they know best
L2 = the children' second language/official/national language

5 Adapted from S.Malone, 2005b. Planning Community-based Education Programmes in Minority Language Communities. Resource manual for mother tongue speakers of minority languages engaged in planning and implementing education programmes in their own communities.

### *សំណួរទី ៤ : តើមានអ្វីខ្លះដែលពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតប្រកបដោយប្រសិទ្ធភាព ?*

ការសិក្សាអំពីកម្មវិធីអប់រំពហុភាសាទូទាំងពិភពលោកបានបង្ហាញឲ្យដឹងថា កម្មវិធីដែលប្រកបដោយជោគជ័យបំផុត និងមាននិរន្តរភាពនោះ គឺមានលក្ខណៈរួមជាច្រើនដូចជា ៖

១. សហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិច ចែករំលែកនូវការទទួលខុសត្រូវចំពោះការធ្វើផែនការ ការអនុវត្ត ការវាយតម្លៃ និងការរក្សានូវកម្មវិធីរបស់ខ្លួន។

២. ទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សាកលវិទ្យាល័យ ព្រមទាំងភ្នាក់ងារដែលមានការចាប់អារម្មណ៍ដទៃទៀតធ្វើការរួមគ្នាក្នុងការគាំទ្រកម្មវិធីនេះ។

៣. ថវិកាគ្រប់គ្រាន់ត្រូវបានគេផ្តល់ឲ្យសម្រាប់សមាសភាគនៃកម្មវិធីទាំងអស់ ជាពិសេស គឺការបណ្តុះបណ្តាល ការកសាងឯកសារ និងការផ្តល់កំរៃជូនលោកគ្រូអ្នកគ្រូនៅតាមមូលដ្ឋាន។

៤. សិស្ស មាតាបិតាសិស្ស និងសហគមន៍របស់ពួកគេទទួលស្គាល់នូវគុណប្រយោជន៍នៃកម្មវិធីដែលជួយឲ្យពួកគេសម្រេចបាននូវគោលដៅអប់រំសម្រាប់ទាំងអស់គ្នា។



ដំណើរការអនុវត្ត និងការរក្សានិរន្តរភាពនៃកម្មវិធីទាំងនេះ ជាទូទៅរួមមានសកម្មភាពជាច្រើន ដូចខាងក្រោម :




អ្នកអនុវត្តកម្មវិធីប្រហែលជាមិនបានទទួលខុសត្រូវលើរាល់សកម្មភាពទាំងអស់ ដែលមានរាយក្នុងដ្យាក្រាមខាងលើនោះទេ។ ឧទាហរណ៍ ពួកគេប្រហែលជាមិនអាចចូលរួមក្នុងការកសាងគោលនយោបាយដែលផ្តល់ការគាំទ្រ ឬរកថវិកាសម្រាប់កម្មវិធីអប់រំពហុភាសាទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេនឹងចូលរួមនៅក្នុងសកម្មភាពដទៃទៀតជាច្រើន។ ផ្នែកខាងក្រោមនេះផ្តល់នូវការរៀបរាប់សង្ខេបជាទូទៅអំពីសកម្មភាពទាំងនោះ ៖

***១. ការប្រមូលព័ត៌មានដើម្បីធ្វើផែនការ :*** កម្មវិធីដែលជោគជ័យចាប់ផ្តើមជាមួយនឹងការធ្វើផែនការបានល្អ ហើយផែនការល្អទាមទារឲ្យមានព័ត៌មានល្អ។ ការឆ្លើយតបនឹងសំណួរខាងក្រោមនេះ នឹងជួយផ្តល់ព័ត៌មានមួយចំនួន ដែលចាំបាច់សម្រាប់ធ្វើផែនការកម្មវិធីអប់រំពហុភាសាឲ្យមានប្រសិទ្ធភាព ៖

- តើប្រជាជននៅក្នុងសហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចយល់យ៉ាងណាចំពោះស្ថានភាពអប់រំបច្ចុប្បន្នរបស់ពួកគាត់? តើពួគគាត់ឲ្យកូនទៅរៀនដើម្បីអ្វី? *(តើបញ្ហាឬតម្រូវការអ្វីខ្លះដែលពួកគាត់មាន?)*
- តើសហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចមួយណា ដែលត្រៀមរួចរាល់ក្នុងការចាប់ផ្តើមកម្មវិធីអប់រំពហុភាសា? *(តើពួកគេតាំងចិត្តអភិវឌ្ឍន៍ភាសារបស់ខ្លួន ដើម្បីសម្រេចគោលបំណងអប់រំឬទេ? តើពួកគេអាចរកបានគ្រូនិងអ្នកសរសេរសៀវភៅឬទេ? តើពួកគេមានទីកន្លែងដើម្បីដំណើរការថ្នាក់រៀនឬទេ? តើពួកគេត្រៀមខ្លួនចូលរួមទទួលខុសត្រូវចំពោះការអនុវត្តនិងការថែរក្សាកម្មវិធីរបស់ខ្លួនឲ្យនៅគង់វង្សដែរឬទេ?)*

- តើស្ថានភាពនៃភាសាតាមមូលដ្ឋានមានលក្ខណៈដូចម្ដេច? *(តើវាមានទម្រង់បែបបទសរសេរ ដែលអ្នកនិយាយភាសាកំណើត អ្នកអប់រំ ព្រមទាំងមន្ត្រីរដ្ឋាភិបាលអាចទទួលយកបានឬទេ?)*
- តើគេអាចប្រមូលបានធនធានអ្វីខ្លះ? *(តើការបណ្ដុះបណ្ដាលធ្វើឡើងនៅកន្លែងណា? នរណាជាអ្នកបណ្ដុះបណ្ដាល? តើនរណាមើលការខុសត្រូវថ្នាក់រៀន? តើនរណានឹងជួយអភិវឌ្ឍកម្មវិធីអប់រំពហុភាសានេះ? តើនរណានឹងកសាងឯកសារសម្រាប់អានជាភាសារបស់សិស្ស?)*
- តើកត្តាអ្វីខ្លះដែលជាឧបសគ្គចំពោះការអនុវត្តនិងនិរន្តរភាពនៃកម្មវិធីនេះ ហើយតើមានដំណោះស្រាយអ្វីខ្លះដែលអាចឆ្លើយតបទៅនឹងបញ្ហាទាំងនេះ? *(តើមធ្យោបាយធ្វើដំណើរនឹងក្លាយជាបញ្ហាសម្រាប់ការបណ្ដុះបណ្ដាល ការត្រួតពិនិត្យ គ្រប់គ្រងនិងផ្ដល់ឯកសារដែរឬទេ? ប្រសិនបើដូចនោះមែន តើមានសម្ភារៈជួយសម្រាប់ការបណ្ដុះបណ្ដាលនៅមូលដ្ឋានដែរឬទេ? តើគេអាចតម្លើងតួនាទីដល់ “នាយក”ឲ្យមើលការខុសត្រូវលោកគ្រូ អ្នកគ្រូផ្សេងទៀតដែលនៅក្នុងទីជិតខាងរបស់ខ្លួនឬទេ?)*
- តើស្ថានភាពភាសានិងការអប់រំបច្ចុប្បន្ននេះមានលក្ខណៈយ៉ាងដូចម្ដេច បើយោងទៅតាមរបាយការណ៍ដែលអាចរកបាននិងឯកសារដទៃផ្សេងទៀត? *(តើកុមារមកពីសហគមន៍ភាសានីមួយៗមានប៉ុន្មានភាគរយដែលបានចូលរៀន? តើកុមារដែលចូលរៀននោះមានប៉ុន្មានភាគរយបានបញ្ចប់ថ្នាក់ទី ៦? បញ្ចប់ថ្នាក់ទី ១០ ? តើមានមនុស្សពេញវ័យប៉ុន្មានភាគរយដែលចេះអានអក្សរបោះពុម្ពបាន?)*

### ឧទាហរណ៍ពីប្រទេសហ្វីលីពីន

### ការស្រាវជ្រាវដំបូងនៃកម្មវិធីអប់រំក្រៅប្រព័ន្ធមនុស្សពេញវ័យ[៦]

កាវិយាល័យអប់រំក្រៅប្រព័ន្ធប្រទេសហ្វីលីពីន បានផ្ដួចផ្ដើមប្រើភាសាទីមួយក្នុងកម្មវិធីអប់រំពីរភាសាជាលើកដំបូងនៅសហគមន៍ដែលប្រើភាសាច្រើន ក៏ប៉ុន្តែដោយសារតែកង្វះខាតធនធានដូចជាឯកសារសិក្សានិងអ្នកសម្របសម្រួលដែលទទួលបានការបណ្ដុះបណ្ដាលនោះ កម្មវិធីមិនត្រូវបានគេអនុវត្តតាមការគ្រោងទុកទាំងអស់ឡើយ។ កម្មវិធីមួយដែលមាននិរន្តរភាពនោះគឺ “កម្មវិធីអប់រំប្រជាជនម្ចាស់ស្រុក” នៃសហគមន៍ប្រើភាសា ម៉ាក់បីគីន (Magbikin) នៅក្នុងតំបន់ម៉ូរ៉ុង (Morong) នៅបាតាអាន (Bataan)។ គម្រោងស្រាវជ្រាវសកម្មភាពនេះមានពីរដំណាក់កាល ៖ ដំណាក់កាលទីមួយគឺ ផ្ដោតលើការកំណត់ឲ្យឃើញនូវតម្រូវការសិក្សា និងការកសាងកម្មវិធីព្រមទាំងឯកសារសិក្សាតាមមូលដ្ឋាន។ ដំណាក់កាលទីពីរគឺចាប់ផ្ដើមផលិតឯកសារសិក្សា កសាងសមត្ថភាព និងរៀបចំវគ្គសិក្សាជាក្រុម។ របាយការណ៍នៃកម្មវិធីនេះបញ្ជាក់ឲ្យឃើញនូវយុទ្ធសាស្ត្រស្រាវជ្រាវជាច្រើនដែលអ្នកសម្របសម្រួលកម្មវិធីធ្លាប់បានរៀនសូត្រពីសហគមន៍ស្ដីពីគោលដៅ និងតម្រូវការរបស់ពួកគេ ៖

6 Valles, M.C. 2005. Action Research on the Development of an Indigenous Peoples Education Programme for the Magbkin Tribe in Morong, Battan, Philippines. UNESCO,*First Language First: Community-based Literacy Programmes for Minority Language Contexts in Asia.* Bangkok, UNESCO, pp. 181-195.

- វគ្គណែនាំផ្សព្វផ្សាយគម្រោង ដែលផ្តោតទៅលើគោលបំណង និងដំណើរការសម្រាប់ប្រមូលព័ត៌មានតាមរយៈការស្រាវជ្រាវសកម្មភាព។
- វគ្គសន្ទនាក្នុងសហគមន៍ដើម្បីកសាងទំនាក់ទំនងដ៏ល្អជាមួយមេដឹកនាំសហគមន៍ និងសមាជិកផ្សេងៗទៀតរបស់សហគមន៍
- ការពិភាក្សាតាមក្រុមស្តីពីប្រធានបទជាក់លាក់ ដើម្បីបង្កើនព័ត៌មានអំពីសហគមន៍
- ការចុះសួរសុខទុក្ខតាមផ្ទះនិងកិច្ចសម្ភាសន៍ជាមួយសមាជិកសំខាន់ៗរបស់សហគមន៍ដើម្បីធ្វើឲ្យមានសុពលភាពនិងបំពេញបន្ថែមនូវព័ត៌មានដែលប្រមូលបានតាមរយៈការពិភាក្សាតាមក្រុម។

តម្រូវការនិងបញ្ហាទាំងឡាយដែលបានរកឃើញតាមរយៈវគ្គនេះត្រូវបានបែងចែកជាក្រុម និងជាអាទិភាព អាស្រ័យទៅតាមទិន្នន័យដែលបានមកពីសមាជិកសហគមន៍។ អ្នកសម្របសម្រួលកម្មវិធីប្រើប្រាស់របកគំហើញទាំងនេះដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសហគមន៍ សម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធ។

***២_លើកកម្ពស់ការយល់ដឹងនិងប្រមូលផែគ្គ :*** មនុស្សទាំងឡាយត្រូវការព័ត៌មានអំពីគោលបំណង និងផលប្រយោជន៍នៃការអប់រំពហុភាសា ប្រសិនបើខ្លួនត្រូវគាំទ្រដល់កម្មវិធីអប់រំពហុភាសានេះ។ ការលើកកម្ពស់ការយល់ដឹង និងសកម្មភាពប្រមូលផ្តុំគួរតែផ្តល់នូវព័ត៌មានដែលជំរុញទឹកចិត្តប្រជាជនឲ្យធ្វើការរួមគ្នាក្នុងការធ្វើផែនការអនុវត្តនិងគាំទ្រកម្មវិធីរបស់ខ្លួន។ សកម្មភាពនេះអាចនឹងកើតឡើងនៅថ្នាក់សហគមន៍ ថ្នាក់ស្រុក ឬថ្នាក់ជាតិ។

***ការលើកកម្ពស់ការយល់ដឹងនិងការប្រមូលធនធានក្នុងសហគមន៍ :*** ប្រជាជនដែលមកពីសហគមន៍ប្រើភាសាជនជាតិភាគតិច ដែលបានជួបប្រទះភាពរើសអើងនិងការមិនអើពើជាច្រើនឆ្នាំហើយនោះប្រហែលអាចមានអារម្មណ៍ថា ភាសានិងវប្បធម៌របស់ខ្លួនគ្មានតម្លៃទេ។ ជារឿយៗពួកគេតែងមានជំនឿថារឿងល្អបំផុតដែលពួកគេអាចធ្វើបានសម្រាប់កូនចៅរបស់ខ្លួននោះគឺ ត្រូវជំរុញឲ្យកូនចៅទៅចូលប្រឡូកក្នុង "ភាសាដែលមានឥទ្ធិពល" ឲ្យបានឆាប់រហ័សតាមតែអាចធ្វើបាន។ ពួកគេបារម្ភថា ប្រសិនបើពួកគេប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀននោះ កូនចៅរបស់ពួកគេនឹងមានឱកាសកាន់តែតិចដើម្បីរៀនភាសាផ្លូវការ ឬភាសាដែលគេនិយមប្រើច្រើន។

ដើម្បីជម្នះរាល់ការយល់ឃើញទាំងនេះ ការលើកកម្ពស់ការយល់ដឹងគប្បីផ្តោតទៅលើតម្លៃផ្នែកអប់រំផង និងតម្លៃផ្នែកវប្បធម៌នៃការអប់រំពហុភាសាផង។ សកម្មភាពទាំងនេះអាចរាប់បញ្ចូលទាំងការជជែកពិភាក្សាផ្សេងៗក្នុងសហគមន៍ ដោយបង្ហាញសម្ភារៈសិក្សាជាភាសាកំណើតរបស់ពួកគេ ការសម្តែងល្ខោន ឬចាកកំប្លែងខ្លីៗ ការទៅទស្សនាថ្នាក់រៀនពហុភាសានៅក្នុងសហគមន៍មួយទៀត ឬការបញ្ចាំងខ្សែវីដេអូអំពីថ្នាក់រៀនពហុភាសា។

## ឧទាហរណ៍ពីប្រទេសហ្វីលីពីន
## ការលើកកម្ពស់ការយល់ដឹងនៅថ្នាក់សហគមន៍
## សម្រាប់កម្មវិធីបឋមសិក្សា[៧]

មន្ត្រីអប់រំនៅប្រទេសហ្វីលីពីនបានទៅសួរសុខទុក្ខដល់សហគមន៍មូលដ្ឋាន ដើម្បីពិភាក្សាជាមួយមាតាបិតាសិស្សអំពីកម្មវិធីអប់រំពហុភាសាដែលបានកសាងឡើងនៅតាមសាលារបស់ពួកគេ។ មាតាបិតា-សិស្សខ្លះនៅតែមិនទាន់យល់ទាំងស្រុងអំពីគោលបំណងរបស់កម្មវិធី ហើយបារម្ភថា កូនចៅរបស់ខ្លួនមិនអាចរៀនភាសាហ្វីលីពីន និងអង់គ្លេស(ភាសាផ្លូវការរបស់ប្រទេសហ្វីលីពីន)បានល្អទេ។ អ្នកទស្សនកិច្ចបានពន្យល់ប្រាប់មាតាបិតាសិស្សថា កម្មវិធីអប់រំពហុភាសាមានគោលដៅជួយដល់កូនចៅរបស់ពួកគាត់ឱ្យកសាងនូវមូលដ្ឋានគ្រឹះអប់រំយ៉ាងរឹងមាំមួយក្នុងភាសាកំណើតរបស់ខ្លួន ព្រមទាំងស្ពានមួយដ៏ល្អឈានទៅរកភាសាផ្លូវការ។ អ្នកទស្សនកិច្ចទាំងនេះបានយកចិត្តទុកដាក់ឆ្លើយសំណួររបស់មាតាបិតាសិស្ស និងបានផ្តល់នូវឧទាហរណ៍ដែលបានពីកន្លែងដទៃផ្សេងៗទៀតនៅក្នុងប្រទេស។ ក្រោយពីបញ្ចប់ការប្រជុំនេះរួចមក មាតាបិតាសិស្សក៏បានជម្រាបទៅអ្នកទស្សនកិច្ចថា "យើងឯកភាពរក្សាកម្មវិធីនេះ ប៉ុន្តែលោកអ្នកត្រូវត្រឡប់ទៅវិញប្រាប់ប្រជាជននៅក្នុងក្រុងម៉ានីល (Manila) ឱ្យដឹងច្បាស់ថា ពួកគេត្រូវជួយកូនចៅរបស់យើងឱ្យកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ និងស្ពានមួយយ៉ាងល្អ។"

***ការលើកកម្ពស់ការយល់ដឹងនិងការប្រមូលធនធាននៅថ្នាក់ស្រុកនិងថ្នាក់ខេត្ត :*** ប្រសិនបើមន្ត្រីថ្នាក់មូលដ្ឋាន ថ្នាក់ស្រុក និងថ្នាក់ខេត្តនៅក្នុងប្រព័ន្ធអប់រំមិនយល់អំពីហេតុផលក្នុងការប្រើប្រាស់ភាសាមិនផ្លូវការនៅតាមសាលាបឋមសិក្សានោះ ពួកគេនឹងមានការលំបាកក្នុងការគាំទ្រដល់ការអប់រំពហុភាសា។ មន្ត្រីអប់រំត្រូវការព័ត៌មានអំពីហេតុផល គោលបំណង និងគុណប្រយោជន៍នៃការអប់រំពហុភាសា និងការធានាឱ្យបានថា កម្មវិធីអប់រំពហុភាសាពិតជាមានតម្លៃ និងត្រូវបានគេអនុវត្តនិងគាំទ្រ។

សកម្មភាពប្រមូលធនធានអាចរាប់បញ្ចូល :

- ការពិភាក្សាតាមក្រុម (ជាមួយនឹងសមាជិកសហគមន៍ជនជាតិភាគតិច) អំពីបញ្ហាអប់រំដែលសិស្សមាន ពោលគឺសិស្សដែលមិននិយាយភាសាផ្លូវការដែលប្រើនៅសាលា។
- ទស្សនកិច្ចទៅថ្នាក់រៀនពហុភាសា ឬការបញ្ចាំងវីដេអូអំពីថ្នាក់រៀនដែលបន្ទាប់មកមានការពិភាក្សាអំពីអ្វីដែលពួកគេបានសង្កេតឬទស្សនា។
- ការចូលរួមក្នុងការស្រាវជ្រាវលើកដំបូង និងវគ្គបណ្តុះបណ្តាលឬការអភិវឌ្ឍកម្មវិធីសិក្សា។
- ការលើកទឹកចិត្តឱ្យគិតពិចារណានូវគំនិតថ្មីៗអំពីវិធីអភិវឌ្ឍកម្មវិធីឱ្យទទួលបានជោគជ័យ។

7 From author's personal communication. 2001. Philippines.

### ឧទាហរណ៍ពីប្រទេសប៉ាពួញូហ្គីណេ (Papua New Guinea)
### ការលើកកម្ពស់ការយល់ដឹងសម្រាប់ការអប់រំមុនបឋមសិក្សា
### (មត្តេយ្យសិក្សា) នៅថ្នាក់ខេត្ត[៨]

នៅពេលដែលសមាជិកសហគមន៍ភាសាកូជេល (Kaugel) បានផ្តួចផ្តើមធ្វើកម្មវិធីអប់រំភាសាកំណើតនៅមត្តេយ្យសិក្សា រឿងមួយដែលពួកគេបានធ្វើមុនគេ គឺការកសាងនូវភាសារបស់ខ្លួន និងសមាគមសិក្សាធិការដែលត្រូវបានចុះបញ្ជីជាមួយនឹងរដ្ឋាភិបាលជាអង្គការមិនមែនរដ្ឋាភិបាលមួយ។ អ្នកសម្របសម្រួលកម្មវិធីដែលជាអតីតគ្រូបង្រៀនបានយល់ថា ប្រសិនបើចង់រក្សានិរន្តរភាពនៃកម្មវិធីនៅតាមមូលដ្ឋាននោះ ត្រូវតែមានការទទួលស្គាល់និងឯកភាពដោយមន្ត្រីការិយាល័យអប់រំខេត្ត។ អ្នកសម្របសម្រួលបានទៅទស្សនកិច្ចការិយាល័យនៅទីរួមខេត្តដោយនាំយកទៅជាមួយនូវគំរូឯកសារអានជាភាសាកូជេល ដែលត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីនេះ។ អ្នកសម្របសម្រួលបានអញ្ជើញមន្ត្រីអប់រំថ្នាក់ខេត្តឱ្យទៅទស្សនកិច្ចវគ្គបណ្តុះបណ្តាលនិងថ្នាក់រៀន ហើយពួកគាត់ក៏បានផ្សវបាយការណ៍ជាប្រចាំអំពីកម្មវិធីនេះទៅឱ្យការិយាល័យអប់រំ។ លើសពីនេះទៅទៀត អ្នកសម្របសម្រួលភាសាកូជេល មានបំណងជួយមន្ត្រីអប់រំថ្នាក់ខេត្តក្នុងការបណ្តុះបណ្តាលប្រជាជនដែលមកពីក្រុមភាសាដទៃទៀត ដែលចង់ផ្តួចផ្តើមធ្វើកម្មវិធីមត្តេយ្យ-សិក្សានេះ។ ទំនាក់ទំនងរវាងកម្មវិធីភាសាកូជេល និងការិយាល័យអប់រំខេត្តបានផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមកគឺថា គ្រូបណ្តុះបណ្តាលភាសាកូជេលបានជួយបណ្តុះបណ្តាលដល់គ្រូបង្រៀនថ្នាក់ខេត្ត ហើយការិយាល័យអប់រំខេត្តជួយផ្តល់ជាបន្ទប់រៀនដល់កម្មវិធីភាសាកូជេលវិញ។ កម្មវិធីភាសាកូជេលនេះបានចាប់ផ្តើមនៅឆ្នាំ ១៩៨៤ ហើយត្រូវបានរក្សាឱ្យមាននិរន្តរភាពប្រកបដោយជោគជ័យអស់រយៈពេលជាង ២០ ឆ្នាំ។ នៅពេលបច្ចុប្បន្ននេះ ការអប់រំដំបូងនៃភាសាកូជេលគឺជាផ្នែកមួយនៃប្រព័ន្ធអប់រំក្នុងប្រព័ន្ធរបស់ប្រទេសប៉ាពួញូហ្គីណេ។

***លើកកម្ពស់ការយល់ដឹងនិងការប្រមូលធនធាននៅថ្នាក់ជាតិ :*** ការរៀបចំធ្វើទស្សនកិច្ចទៅមើលកម្មវិធីទាំងឡាយដែលទទួលបានជោគជ័យមិនថាក្នុងឬក្រៅប្រទេស គឺជាសកម្មភាពលើកកម្ពស់ការយល់ដឹងមួយដ៏ល្អឥតខ្ចោះសម្រាប់អ្នកកសាងគោលនយោបាយ និងមន្ត្រីថ្នាក់ជាតិដទៃទៀត។ យុទ្ធសាស្ត្រមួយផ្សេងទៀតនោះ គឺត្រូវទទួលធ្វើជាម្ចាស់ក្នុងសន្និសិទថ្នាក់ជាតិ ឬថ្នាក់តំបន់ ឬក្នុងសិក្ខាសាលាដែលផ្តោតទៅលើការអប់រំពហុភាសា។

8 From author's personal experirnce working with the Kaugel language programme from 1982 to 1987.

## ឧទាហរណ៍ពីប្រទេសឥណ្ឌា

## លើកកម្ពស់ការយល់ដឹងអំពីការអប់រំពហុភាសានៅថ្នាក់ជាតិ[៩]

នៅឆ្នាំ ២០០៥ "សិក្ខាសាលាស្តីពីការអប់រំពហុភាសាដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការងារអប់រំក្រុមកុលសម្ព័ន្ធ" ត្រូវបានធ្វើឡើងនៅតំបន់ម៉ៃស៊័រ (Mysore) ប្រទេសឥណ្ឌា។ សិក្ខាសាលាដែលមានរយៈពេលបីថ្ងៃនេះ ត្រូវបានទទួលការឧបត្ថម្ភគាំទ្រពីអង្គការយូណេស្កូ (UNESCO), យូនីសេហ្វ (UNICEF) ក្រុមប្រឹក្សាជាតិស្តីពីការងារអប់រំ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវព្រមទាំងវិទ្យាស្ថានភាសារបស់ប្រទេសឥណ្ឌា។

គោលបំណងនៃសិក្ខាសាលានេះ គឺត្រូវប្រមូលផ្តុំសមាជិកសហគមន៍ប្រើភាសាជនជាតិភាគតិច អ្នកអនុវត្តកម្មវិធី បញ្ញាវ័ន្ត និងអ្នកកសាងគោលនយោបាយឱ្យរួមគ្នាដើម្បីពិភាក្សាអំពីបញ្ហាពាក់ព័ន្ធទៅនឹងតម្រូវការអប់រំរបស់អ្នកដែលនិយាយភាសាភាគតិច។ អ្នករៀបចំផែនការសិក្ខាសាលាបានសង្ឃឹមថា សិក្ខាកាមនឹងរៀនសូត្រពីគ្នា ទៅវិញទៅមក ក្នុងខណៈដែល ពួកគេពិភាក្សា គ្នាអំពី គម្រោងកម្មវិធីអប់រំដែលសមស្រប ទៅនឹងតម្រូវការអប់រំរបស់សហគមន៍នៃភាសាហើយឱ្យតម្លៃភាសានិងវប្បធម៌របស់សិស្ស។

ចាប់តាំងពីគេកសាងគោលនយោបាយថ្នាក់ជាតិនៅប្រទេសឥណ្ឌាមក សិក្ខាសាលាត្រូវបានរៀបចំឡើងជាពិសេសដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមមន្ត្រីរដ្ឋាភិបាលនៅថ្នាក់នោះ។ គេក៏បានអញ្ជើញអ្នកនិយាយភាសាជនជាតិភាគតិច សមាជិកអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រកម្មវិធីអប់រំពហុភាសាព្រមទាំងបញ្ញាវ័ន្តថ្នាក់ជាតិនិងមន្ត្រីរដ្ឋាភិបាលមួយចំនួនឱ្យចូលរួមក្នុងសិក្ខាសាលានេះ។ គោលបំណងគឺចង់ឱ្យមានតុល្យភាពរវាងអ្នកធ្វើការងារនៅថ្នាក់មូលដ្ឋាន បញ្ញាវ័ន្ត និងអ្នកកសាងគោលនយោបាយ។

នៅពេលបញ្ចប់សិក្ខាសាលា សិក្ខាកាមបានកំណត់នូវចំណុច ៤ យ៉ាងដែលជាសមាសភាគដ៏សំខាន់នៃកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតនៅក្នុងប្រទេសឥណ្ឌាដូចជា :

- ការចូលរួមពីសហគមន៍តាំងពីដំបូង (រួមទាំងការសម្រេចចិត្តអំពីការបង្កើតអក្ខរាវិរុទ្ធ)។
- កម្មវិធីសិក្សាត្រូវទាក់ទងទៅនិងបរិបទមូលដ្ឋាន។
- អ្នកនិយាយភាសាកំណើតដែលចេញពីសហគមន៍ផ្ទាល់របស់កុមារត្រូវយកមកធ្វើជាគ្រូបង្រៀន។
- ត្រូវមានឯកសារអានផ្សេងៗជាភាសាកំណើតរបស់កុមារ។

9 From author's experirnce.

***៣_ការអភិវឌ្ឍអក្ខរាវិរុទ្ធ (ប្រព័ន្ធសំណេរ) សម្រាប់ភាសាដែលមិនទាន់មានប្រព័ន្ធសំណេរ :*** ការអភិវឌ្ឍអក្ខរាវិរុទ្ធ ឬប្រព័ន្ធសម្រាប់សរសេរភាសាមួយដ៏ជាក់លាក់ គឺទាក់ទងទៅនឹងការជ្រើសរើសសម្រាំង និងការសាកល្បងនិមិត្តសញ្ញា/អក្សរ និងក្បួនប្រកប (អក្សរពុម្ពធំ សញ្ញាវណ្ណយុត្តិ....។ល។) ដែលជាតំណាងឲ្យផ្នែកសំខាន់ៗនៃភាសា។ ការអភិវឌ្ឍអក្ខរាវិរុទ្ធមានគោលដៅពីរ :

១)_អ្នកនិយាយភាសានោះនឹងឯកភាពទៅលើអក្ខរាវិរុទ្ធ ហើយតែងតែប្រើវាជានិច្ចកាល។

២)_អក្ខរាវិរុទ្ធនឹងត្រូវទទួលយកពីសំណាក់ភ្នាក់ងាររដ្ឋាភិបាលដែលមានការពាក់ព័ន្ធ។

ដំណើរការអភិវឌ្ឍអក្ខរាវិរុទ្ធជាធម្មតារួមមានសកម្មភាពដូចខាងក្រោម :

១. *ការស្រាវជ្រាវអំពីភាសា :* ប្រមូលព័ត៌មានស្តីពីភាសា ពោលគឺ ចំនួនអ្នកនិយាយ តំបន់ភូមិសាស្ត្រដែលគេនិយាយភាសានោះ ចំនួនគ្រាមភាសា និងកម្រិតនៃភាពស្រដៀងគ្នា ឬខុសគ្នារវាងភាសា អត្តចរិតរបស់ប្រជាជនដែលមានមកលើភាសាខ្លួន ព្រមទាំងវិស័យនានាដូចជា : ផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ សាសនា វប្បធម៌ដែលគេប្រើភាសានោះ។

២. *ការវិភាគភាសា :* ការកំណត់ឲ្យឃើញនូវផ្នែកទាំងឡាយនៃភាសាដែលតម្រូវឲ្យមានអក្សរ ឬសញ្ញាផ្សេងៗជាតំណាង។

៣. *អក្ខរាវិរុទ្ធសាកល្បង :* រៀបចំធ្វើសិក្ខាសាលាអំពីអក្ខរាវិរុទ្ធដោយអ្នកនិយាយភាសាកំណើត និងមានការជួយជ្រោមជ្រែងពីសំណាក់ភាសាវិទូ។ ដើម្បីកំណត់រកឲ្យឃើញនូវអក្សរ និងនិមិត្តសញ្ញាដែលតំណាងឲ្យភាសារបស់ខ្លួន ព្រមទាំងបង្កើតអក្ខរាវិរុទ្ធបណ្តោះអាសន្ន ។

៤. *ការសាកល្បង :* ធ្វើការសាកល្បងផ្នែកអក្ខរាវិរុទ្ធជាផ្លូវការ (តាមរយៈការអង្កេតលើការប្រើប្រាស់ភាសាសរសេររបស់ប្រជាជន និងកត់សម្គាល់អំពីបញ្ហា) និងក្រៅផ្លូវការ (ដោយការលើកទឹកចិត្តប្រជាជនឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន) ដើម្បីប្រើប្រាស់អក្ខរាវិរុទ្ធនេះឲ្យបានច្រើននិងតាមរយៈការស្នើសុំនូវមតិកែលំអផ្សេងៗរបស់ពួកគេ។

៥. *ការពិនិត្យឡើងវិញ :* កំណត់ឲ្យឃើញនូវអក្សរ និងនិមិត្តសញ្ញាផ្សេងៗទៀតដែលអាចប្រើប្រាស់បាន ប្រសិនបើអក្សរដែលបានបង្កើតឡើងនោះមានបញ្ហា ។

៦. *ការឯកភាព :* រៀបចំធ្វើសិក្ខាសាលាស្តីពីអក្ខរាវិរុទ្ធជាលើកទី ២ ដើម្បីបង្ហាញនូវអក្ខរាវិរុទ្ធដែលត្រូវបានគេពិនិត្យឡើងវិញដល់អ្នកនិយាយភាសាកំណើតដើម្បីសុំការឯកភាពពីពួកគេ។ សុំការឯកភាពពីសំណាក់ភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធផងដែរ។

ជាគោលការណ៍ ការអភិវឌ្ឍប្រព័ន្ធសំណេរសម្រាប់ភាសាដែលមិនទាន់មានអក្សរពីមុន គេចាប់ផ្ដើមធ្វើការវិភាគទៅលើភាសាដើម្បីកំណត់ឲ្យឃើញនូវផ្នែកដែលតម្រូវឲ្យមានអក្សរនិងនិម្មិតសញ្ញាជាតំណាង។ ក៏ប៉ុន្តែជួនកាលនៅពេលខ្លះ សមាជិកសហគមន៍ចង់ចាប់ផ្ដើមធ្វើកម្មវិធីអប់រំពហុភាសានេះឲ្យបានរហ័ស ហើយមានអារម្មណ៍ថា ខ្លួនមិនមានពេលវេលាសម្រាប់ធ្វើការវិភាគលើភាសាឲ្យបានទូលំទូលាយឡើយ។ ធ្វើការងាររួមគ្នាដោយមានការជួយគាំទ្រពីអ្នកជំនាញខាងភាសា អ្នកនិយាយភាសាកំណើតអាចនឹងអភិវឌ្ឍបាននូវអក្ខរាវិរុទ្ធដំបូងសម្រាប់ភាសារបស់ខ្លួន។

ប៉ុន្តែវាជាប្រការដ៏សំខាន់ដែលត្រូវសម្គាល់ថា ការអភិវឌ្ឍន៍អក្ខរាវិរុទ្ធឲ្យបានកាន់តែរហ័សនោះ ក៏ត្រូវពិនិត្យសាកល្បងវាឲ្យកាន់តែប្រុងប្រយ័ត្នថែមទៀត។ វាក៏ជាប្រការដ៏ល្អជាទីបំផុតផងដែរ ដោយកុំបង្កើតឯកសារអានដែលមានតម្លៃខ្ពស់។

## ឧទាហរណ៍ពីប្រទេសប៉ាពួញូហ្គីណេ

## ការអភិវឌ្ឍអក្ខរាវិរុទ្ធសម្រាប់ភាសាជាច្រើន[១០]

សិក្ខាសាលាស្ដីអំពីការតាក់តែងអក្ខរក្រម[១១] បង្កលទ្ធភាពឲ្យសមាជិកសហគមន៍ភាសាភាគតិចអាចចាប់ផ្ដើមអភិវឌ្ឍអក្ខរាវិរទ្ធ (អក្ខរក្រម) សម្រាប់ភាសារបស់ខ្លួន។ សិក្ខាសាលាត្រូវបានធ្វើឡើងផ្អែកទៅលើការទទួលស្គាល់ថា អ្នកនិយាយភាសាកំណើតជាអ្នកដែលដឹងអំពីវិធីដែលខ្លួនគួរនិយាយ និងសរសេរភាសារបស់ខ្លួន។

សិក្ខាសាលាស្ដីពីការតាក់តែងអក្ខរក្រមសម្រាប់ក្រុមភាសាណាមួយ ជាធម្មតាមានរយៈពេលប្រហែលជា ១០ ថ្ងៃ។ នៅក្នុងសិក្ខាសាលានោះ អ្នកនិយាយភាសាកំណើតដែលត្រូវបានជួយលើកទឹកចិត្ត និងគាំទ្រដោយអ្នកឯកទេសរៀបចំផ្នែកអក្ខរក្រមក៏បានសរសេរនិងរៀបរៀងចងក្រងរឿងផ្សេងៗ ស្រាវជ្រាវរកគំរូសម្លេងនៃភាសារបស់ខ្លួន បង្កើតជាក្បួនប្រកបតួអក្សរជាការសាកល្បងមួយដែលរាប់បញ្ចូលនូវអក្ខរក្រមថ្មីក្បួនប្រកប និងវចនានុក្រមខ្លីមួយ។ រឿងដែលគេសរសេរក្នុងពេលសិក្ខាសាលានោះ ត្រូវបានចងក្រងជាសៀវភៅមួយក្បាលដោយឡែក ដើម្បីទុកប្រើប្រាស់ពេលក្រោយសម្រាប់សាកល្បងអក្ខរក្រមថ្មី នៅក្នុងសហគមន៍ភាសា។ តាមរយៈសកម្មភាពទាំងនេះ ក្រុមសិក្ខាកាមបានអភិវឌ្ឍចំណេះដឹងកាន់តែច្រើនឡើងអំពីវចនាសម្ព័ន្ធនៃភាសារបស់ខ្លួន និងបញ្ហាដែលគួរពិចារណាក្នុងការអភិវឌ្ឍអក្ខរក្រមសាកល្បង។

10 Easton, C.2003 (7-9 November). *Alphabet Design Workshop in Papna New Guinea: A Community-based Approach to Orthography Development.* International Conference on Language Development, Language Revitalization and Multilinguage Education. Bangkok, http://www.sil.org/asia/ldcparallel_papers/catherine_easton.pdf (Accessed on 17 November 2006).

11 Alphabet Design Workshop were developed by SIL International in Papua New Guinea. See Easton C.2003 . http//www-sil-org/asia/ldc/parallel papers/Catherine-easton.pdf (Accessed on 17 November 2006)

សិក្ខាសាលាស្តីពីការតាក់តែងអក្ខរក្រមបានគោរពទៅតាមវិធីសាស្ត្រដូចខាងក្រោមនេះ :

១. សិក្ខាកាមសរសេរ បន្ទាប់មកអានរឿងជាភាសារបស់ខ្លួន។

២. ពួកគេកំណត់បាននូវបញ្ហាទាក់ទងនឹងអក្ខរក្រម នៅពេលដែលខ្លួនឆ្លងកាត់ដំណើរការសរសេរ និងអាន។

៣. ពួកគេពិភាក្សាអំពីជម្រើសសម្រាប់ដោះស្រាយបញ្ហាទាំងនេះ។

៤. ពួកគេត្រូវធ្វើការសម្រេចចិត្តថា តើត្រូវប្រើប្រាស់អក្សរ ឬនិមិត្តសញ្ញាមួយណា។

៥. ពួកគេធ្វើការសាកល្បងនូវជម្រើសដែលគេបានសម្រេចចិត្តយក។

ដំហានទាំង ៥ ខាងលើនេះ ត្រូវធ្វើម្តងហើយម្តងទៀតឲ្យបានញឹកញាប់តាមការចាំបាច់នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ កត្តានេះជំរុញទឹកចិត្តដល់សិក្ខាកាមឲ្យបន្តការវាយតម្លៃទៅលើអក្ខរក្រមថ្មីរបស់ខ្លួន និងធ្វើការផ្លាស់ប្តូរដែលចាំបាច់។ ដំណើរការសម្រេចចិត្តនេះ លើកទឹកចិត្តឲ្យពួកគេបានយល់ថាប្រព័ន្ធសំណេររបស់ខ្លួនពុំមែនជាអ្វីមួយដែលមិនអាចកែប្រែនោះបានឡើយ។ ប៉ុន្តែវាជាឧបករណ៍ដើម្បីប្រើប្រាស់ និងធ្វើការផ្លាស់ប្តូរដោយក្រុមសហគមន៍ភាសាទៅតាមតម្រូវការ។

នៅក្នុងប្រទេសប៉ាពួញូហ្គីណេដែលមានប្រជាជន ៥លាននាក់និយាយភាសាច្រើនជាង ៨០០ ភាសានោះ សិក្ខាសាលាស្តីពីការតាក់តែងអក្ខរក្រមនេះបានបំពេញនូវតម្រូវការដ៏ចាំបាច់មួយ។ នៅពេលដែលនាយកដ្ឋានជាតិអប់រំចាប់ផ្តើមធ្វើកម្មវិធីអប់រំពហុភាសានៅពាក់កណ្តាលទសវត្សរ៍ទី ៩០ នោះ សហគមន៍ភាសាជាច្រើនត្រូវការឲ្យមានការអភិវឌ្ឍប្រព័ន្ធសំណេរដើម្បីពួកគេអាចចូលក្នុងកម្មវិធីនេះ។ ក្នុងរវាងឆ្នាំ ១៩៩៨ និងឆ្នាំ ២០០២ មានសិក្ខាសាលាស្តីពីការតាក់តែងអក្ខរក្រមចំនួន ៤៧ លើកត្រូវបានធ្វើឡើងក្នុងនោះមានប្រជាជននិយាយភាសាខុសៗគ្នាជាង ១០០ នាក់បានបង្កើតឡើងនូវអក្ខរក្រមជាការសាកល្បង។

***៤. ការកសាងកម្មវិធីមួយដ៏ជាក់លាក់សម្រាប់ការអប់រំពហុភាសា*** : សិស្សដែលរៀនក្នុងកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតដ៏ល្អ (មានន័យថា កម្មវិធីដែលប្រើប្រាស់ភាសាកំណើតជាភាសាមួយសម្រាប់ការបង្រៀនអស់រយៈពេលយ៉ាងហោចណាស់ ៦ឆ្នាំ) គប្បីទទួលបានលទ្ធផលសិក្សាជាទូទៅចំនួនបី :

១. ពួកគេនឹងយល់ ហើយអាចអនុវត្តនូវគំនិតនៃការសិក្សាតាមកម្រិតថ្នាក់នៅក្នុងមុខវិជ្ជាស្នូល។

២. ពួកគេនឹងបានចាប់ផ្តើមកសាងសមត្ថភាព និងភាពជឿជាក់ក្នុងការប្រើប្រាស់ភាសាតាមសាលាជាផ្លូវការ។

៣. ពួកគេនឹងបានអភិវឌ្ឍន៍សមត្ថភាព និងភាពជឿជាក់ក្នុងការប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់ទាំងផ្នែកនិយាយ និងទម្រង់សរសេរ ដើម្បីសម្រេចគោលបំណងផ្សេងៗរួមទាំងការប្រើប្រាស់វាសម្រាប់ការរៀនសូត្រផង។

កម្មវិធីសិក្សាអប់រំពហុភាសាគួរមានខ្លឹមសារដូចគ្នាទៅនឹងកម្មវិធីអប់រំចំណេះទូទៅដើម្បីឲ្យសិស្សអាចប្តូរទៅរៀននៅថ្នាក់ក្នុងកម្មវិធីចំណេះទូទៅបានយ៉ាងងាយស្រួលនៅពេលបញ្ចប់សាលាបឋមសិក្សា ឬនៅពេលដែលពួកគេរៀនចប់ភាសាទីមួយ។ កម្មវិធីសិក្សាអប់រំពហុភាសាគួរគប្បីបញ្ចូលនូវការផ្តោតអារម្មណ៍ដ៏ជាក់លាក់មួយ "នៃការអភិវឌ្ឍន៍ភាសា" (សូមមើលចំណុច ២ និង ៣ ខាងលើ)។ លោកគ្រូអ្នកគ្រូត្រូវសិក្សាស្វែងយល់ពីយុទ្ធសាស្ត្រសមស្របដើម្បីជួយដល់សិស្សឲ្យកសាងសមត្ថភាព និងជំនឿទុកចិត្តក្នុងការស្តាប់ និយាយ អាន និងសរសេរជាភាសាកំណើតរបស់ខ្លួនផងនិងជាភាសាផ្លូវការផង។



ខាងក្រោមនេះគឺជាយោបល់មួយចំនួនសម្រាប់ការអភិវឌ្ឍន៍កម្មវិធីអប់រំពហុភាសាដ៏ជាក់លាក់មួយ ៖

១. ជាដំបូងសូមធ្វើតារាងសមត្ថភាពសិក្សាសម្រាប់មុខវិជ្ជានីមួយៗនៅក្នុងកម្មវិធីសិក្សាទូទៅ។ ត្រូវចងចាំថា សមត្ថភាពទាំងនេះត្រូវបានសរសេរឡើងសម្រាប់សិស្សដែលនិយាយភាសាតាមសាលាជាភាសាកំណើតរបស់ខ្លួន។

២. យកចិត្តទុកដាក់ពិនិត្យមើលសមត្ថភាពសម្រាប់មុខវិជ្ជានីមួយៗ ហើយត្រូវរកឱ្យឃើញនូវខ្លឹមសារសំខាន់ដែលសិស្សត្រូវរៀនសូត្រ។ ចូរកត់សម្គាល់ថា ខ្លឹមសារសំខាន់ៗក្នុងមុខវិជ្ជាមួយចំនួនដូចជាគណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម សុខភាព និងខ្លឹមសារដទៃទៀតដែលមិនមែនជាភាសាណាមួយជាក់លាក់ (ឧទាហរណ៍ ភាសាក្មេង ឬគួយ...) អាចនឹងរៀនជាភាសាណាមួយក៏បាន។ ចូរអភិវឌ្ឍសមត្ថភាពអប់រំពហុភាសាដែលផ្តោតការយកចិត្តទុកដាក់ទៅលើគំនិតសំខាន់ៗទាំងនេះ ហើយសម-ស្របទៅនឹងសិស្សដែលមានប្រភពចេញពីភាសា និងវប្បធម៌ ដែលមិនមានលក្ខណៈជាទូទៅ។

៣. បន្ទាប់មក អភិវឌ្ឍសមត្ថភាពអប់រំផ្នែកភាសាដ៏ជាក់លាក់នៃការអប់រំពហុភាសា សម្រាប់ភាសាកំណើតរបស់កុមារ និងភាសាជាផ្លូវការ (សូមមើលជំហាននៃការអភិវឌ្ឍន៍ផ្នែកភាសាខាងលើ)។ ធានាឱ្យបានថាសមត្ថភាពទាំងនេះផ្តោតការយកចិត្តទុកដាក់ទៅលើការប្រើប្រាស់ភាសាទាំងពីរនេះ សម្រាប់ទំនាក់ទំនងប្រចាំថ្ងៃផង និងជាមុខវិជ្ជាសិក្សាផង។

- សមត្ថភាពដែលទាក់ទងនឹងការប្រើប្រាស់ភាសាដើម្បីទំនាក់ទំនង មានការឆ្លុះបញ្ចាំងពីរយ៉ាងគឺ ៖ សិស្សប្រើប្រាស់ភាសាថ្មីនេះប្រកបដោយអត្ថន័យ ហើយពួកគេរៀននិយាយ អាន និងសរសេរវាឱ្យបានត្រឹមត្រូវ។
- សមត្ថភាពដែលទាក់ទងនឹងការប្រើប្រាស់ភាសា សម្រាប់មុខវិជ្ជាសិក្សាគឺផ្តោតលើការយកចិត្តទុកដាក់ចំពោះការបង្កើតវាក្យស័ព្ទសម្រាប់សិក្សាក្នុងភាសាថ្មីនោះ។ (ឧទាហរណ៍ខ្លះៗដូចជាពាក្យក្នុងគណិតវិទ្យាសម្រាប់ធ្វើប្រមាណវិធីគុណឬចែកហើយនិងពាក្យវិទ្យាសាស្ត្រដូចជាចំហាយទឹកឬរស្មីសំយោគ)។ ពាក្យទាំងនេះដែលមានលក្ខណៈអរូបីដែលបង្កការលំបាកដល់អ្នករៀន ក្នុងការរៀនសូត្រ ចងចាំ និងប្រើប្រាស់វា ហេតុនេះទាមទារឱ្យមានវិធីសាស្ត្រជាពិសេសសម្រាប់ការបង្រៀន។

៤. ផ្តល់ជាយោបល់ក្នុងការធ្វើសកម្មភាពរៀនសូត្រ ដែលគ្រូបង្រៀនផ្នែកអប់រំភាសាអាចប្រើប្រាស់ដើម្បីជួយអ្នកសិក្សាឱ្យសម្រេចបាននូវសមត្ថភាពនីមួយៗ។ លោកអ្នកអាចប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតឬធនធានដទៃទៀតសម្រាប់បង្រៀនភាសាដែលមាននៅក្នុងកម្មវិធីសិក្សានេះ។

៥. កសាងឯកសារណែនាំគ្រូ ដោយរួមបញ្ចូលទាំងលំនាំការបង្រៀនជាគំរូ ដែលគ្រូរាយជាគំនិតផ្សេងៗរួមទាំងខ្លឹមសារនៅតាមមូលដ្ឋានក្នុងមេរៀននីមួយៗ។ (ឧទាហរណ៍មួយសម្រាប់មេរៀនសុខភាពគឺត្រូវសរសេរចំណាងជើងនៃរឿងដែលទាក់ទងនឹងសុខភាពជាភាសាកំណើតរបស់ប្រជាជននៅតាមមូលដ្ឋាន)។ សូម្បីនៅពេលសិស្សមានលទ្ធភាពប្រើប្រាស់សៀវភៅសិក្សាទូទៅក៏ដោយ ក៏គ្រូបង្រៀនគួរតែបន្ថែមខ្លឹមសារនៅមូលដ្ឋានក្នុងមេរៀន ដើម្បីធានាថា សិស្សទាំងឡាយបន្តពង្រឹងចំណេះដឹងភាសារបស់ខ្លួនទាំងពីរផ្នែក ដោយពឹងផ្អែកទៅលើបទពិសោធន៍របស់ខ្លួនផ្ទាល់។

## ឧទាហរណ៍ពីប្រទេសថៃ
## ការកសាងឯកសារបង្រៀនការជាពហុភាសាសម្រាប់កម្មវិធីពង្រឹងផ្នែកភាសានៅតាមសាលាបឋមសិក្សា[១២]

សមាជិកនៃសហគមន៍ភាសាចុង (Chong)នៅខេត្តចាន់តាបូរី ប្រទេសថៃ មានការបារម្ភថា កូនចៅរបស់ខ្លួនកំពុងតែបាត់បង់នូវភាសានិងវប្បធម៌របស់ខ្លួនហើយ។ ពួកគេចង់បញ្ចូលម៉ោងភាសាចុងនៅក្នុងកម្មវិធីតាមសាលាបឋមសិក្សាដែលរៀនភាសាថៃជាទៀងទាត់ហើយនោះ។ អ្នកដឹកនាំសហគមន៍បានស្នើសុំនិងទទួលការអនុញ្ញាតពីមន្ត្រីអប់រំឱ្យប្រើប្រាស់ថ្នាក់ "សិក្សាពីមូលដ្ឋាន" (ជាផ្នែកនៃកម្មវិធីសិក្សាទៀងទាត់នៅតាមសាលា) ដើម្បីបង្រៀនអំពីភាសានិងវប្បធម៌របស់ខ្លួន។

សមាជិកសហគមន៍បានចូលរួមនៅក្នុងការបង្កើតកម្មវិធីសិក្សាមួយសម្រាប់ភាសាចុងនិងថ្នាក់រៀនអំពីវប្បធម៌។ ពួកគេបានបង្កើតខ្លឹមសារមេរៀនភាសាផ្ទាល់មាត់ រៀបចំគ្រប់ឯកសារបង្រៀននិងឯកសារអានទាំងអស់ ព្រមទាំងបានស្ម័គ្រចិត្តធ្វើជាគ្រូបង្រៀនសម្រាប់ថ្នាក់រៀននោះទៀតផង។[១៣] កម្មវិធីសិក្សាសម្រាប់ភាសាចុងមានគោលបំណងពីរ : ជួយក្រុមកុមារជនជាតិចុងឱ្យរៀនយល់ រៀននិយាយ រៀនអាននិងសរសេរភាសារបស់ខ្លួនក្នុងបរិយាកាសមួយដ៏រីករាយ ហើយជួយពួកគេឱ្យទទួលស្គាល់ភាសារបស់ខ្លួននិងមានមោទនភាពក្នុងការរួមចំណែកពង្រឹងកេរដំណែលវប្បធម៌ឱ្យកាន់តែខ្លាំងក្លាថែមទៀត។

អ្នកនិយាយភាសាចុងមួយក្រុមដែលមានអាយុច្រើនបានផ្តល់នូវលំដាប់លំដោយនៃពាក្យសំខាន់ៗសម្រាប់គ្រូប្រើប្រាស់នៅក្នុងសកម្មភាពរៀនភាសាចុង។ មនុស្សពេញវ័យមួយក្រុមផ្សេងទៀតសរសេររឿងដោយផ្អែកទៅតាមវប្បធម៌របស់ជនជាតិចុង និងប្រវត្តិសាស្ត្រតាមរយៈការប្រាប់ផ្ទាល់មាត់។ ការងារទាំងនេះត្រូវបានធ្វើឡើងបញ្ចូលទៅក្នុងសៀវភៅអានភាសាចុងជាហូរហែ។

12 Malone, D. and Suwilai P. 2005. Language Development and Language Revitalization in Asia. *Mon Khmer Studies,* Vol. 35, pp. 101-120.

13 This programme did not include use of the children's first language for other subjects.

ក្រុមមាតាបិតាសិស្សបានសរសេរ "សៀវភៅរឿងខ្នាតធំ" ចំនួន ២៧ ក្បាល ដែលគ្រូបង្រៀនអាចអានបានជាមួយសិស្សក្នុងថ្នាក់រៀនទាំងមូល។ ដំណើរការអានមួយនេះ ត្រូវបានគេហៅថា "ការអានរួមគ្នា"។ សិស្សជនជាតិចុងរៀននៅវិទ្យាល័យបានចូលរួមចំណែកដោយការរៀបចំរូបភាពពន្យល់សម្រាប់សៀវភៅធំនោះ។ អ្នកនិយាយភាសាចុងដែលជាជនពេញវ័យក៏បានផ្តល់នូវចម្រៀងប្រពៃណីដល់កុមារដើម្បីឲ្យបានរៀនសូត្រនៅក្នុងពេលសិក្សា។ សៀវភៅសិក្សាកម្រិតដំបូង ត្រូវបានកសាងឡើងដើម្បីជួយកុមារជនជាតិចុងដែលបានដឹងពីរបៀបអាន និងសរសេរភាសាថៃរួចហើយនោះឲ្យសាងស្ពានឆ្លងទៅរកការអាន ការសរសេរជាភាសា និងវប្បធម៌របស់ខ្លួន។

បទពិសោធន៍នេះឆ្លុះបញ្ចាំងឲ្យឃើញថា សមាជិកក្រុមភាសាភាគតិចគឺជាធនធានមនុស្សដ៏មានសារៈសំខាន់បំផុត ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា។

***៥. ការកសាងឯកសារអានទៅតាមកម្រិតថ្នាក់ :*** ការអានប្រៀបបីដូចជាការជិះកង់ដែរ យើងគ្រាន់តែរៀនម្តងប៉ុណ្ណោះ។ សិស្សដែលបានរៀនអានជាភាសារបស់ខ្លួនហើយនោះ គឺអាចផ្លាស់ប្តូរនូវអ្វីដែលខ្លួនបានរៀននោះឲ្យទៅជាការអានមួយនៅក្នុងភាសាថ្មីមួយទៀត ទោះបីជាភាសាថ្មីនោះមានអក្សរខុសគ្នាក៏ដោយ។ កត្តាដែលសំខាន់បំផុតនៅក្នុងការជួយសិស្សឲ្យក្លាយជាអ្នកអានប្រកបដោយភាពស្ទាត់ជំនាញផ្នែកភាសាកំណើតរបស់ខ្លួននិងភាសាដែលប្រើជាផ្លូវការនោះ គឺត្រូវមានឯកសារសម្រាប់អាននានាដែលប្រើភាសាទាំងពីរនេះតែម្តង។

បទពិសោធន៍នៅក្នុងកម្មវិធីអប់រំពហុភាសាជាច្រើនបានបង្ហាញថា សិស្សមិនត្រូវការឯកសារអានដែលមានតម្លៃខ្ពស់ឡើយ។ ជាធម្មតាសៀវភៅស្តើងបោះពុម្ពមកដោយមានរបៀប មានគម្របក្រដាសមានរូបភាពពណ៌ស_ខ្មៅគឺអាចទទួលយកបាន ជាពិសេសគឺនៅដំណាក់កាលដំបូងនៃកម្មវិធីនេះ។ លក្ខណៈដ៏សំខាន់បំផុតនៃឯកសារគឺ ៖

១)_ខ្លឹមសារគួរឲ្យចាប់អារម្មណ៍ ជាពិសេសទាក់ទងនឹងជីវភាព ប្រពៃណី ទំនៀមទម្លាប់របស់គេ។

២)_ភាសាមានភាពច្បាស់លាស់ និងងាយយល់។

៣)_រូបភាពសម្រាប់ពន្យល់មានភាពទាក់ទងទៅនឹងអត្ថបទ ហើយសមស្របទៅតាមបរិបទមូលដ្ឋាន។



ក្រៅពីអត្ថប្រយោជន៍ដែលឯកសារទាំងនេះផ្តល់ឲ្យកម្មវិធីអប់រំពហុភាសានៅតាមមូលដ្ឋាន លទ្ធផលនៃដំណើរការអនុវត្តកម្មវិធីនេះ ពោលគឺការអភិវឌ្ឍន៍អក្សរសាស្ត្រនៅក្នុងភាសារបស់ជាតិជាច្រើនដែលកត់ត្រាពីប្រវត្តិសាស្ត្រនិងរឿងរ៉ាវរបស់ប្រជាជន បានបន្ថែមនូវភាពសម្បូរបែបនៃកេរដំណែលជាតិឲ្យកាន់តែកើនឡើង។

### ឧទាហរណ៍ពីប្រទេសចិន

### ការកសាងឯកសារអានតាមកម្រិតចំណេះដឹង(១៤)

ប្រជាជនភាគច្រើនក្នុងចំណោមប្រជាជនចំនួន ១,៦ លាននាក់ ដែលនិយាយភាសាកាម (Kam)(១៥) រស់នៅទីជនបទដែលជាតំបន់ភ្នំនៃខេត្តគួយចូវ (Guizhou) ក្នុងប្រទេសចិន។ នៅឆ្នាំ ២០០០ មេដឹកនាំសហគមន៍ភាសាកាមបានចាប់ប្រតិបត្តិគម្រោងសាកល្បងការងារអប់រំពីរភាសាជាភាសារបស់ខ្លួន។ នៅក្នុងគម្រោងនោះ លោកគ្រូអ្នកគ្រូប្រើប្រាស់ភាសាកាមនៅក្នុងថ្នាក់រៀនរយៈពេលពីរឆ្នាំនៅមត្តេយ្យសិក្សា (ជាមួយនិងកុមារមានអាយុ ៥-៦ ឆ្នាំ) មុនពេលណែនាំឲ្យស្គាល់ភាសាចិនផ្នែកនិយាយផ្ទាល់មាត់នៅថ្នាក់ទី ១។

គោលការណ៍មួយក្នុងចំណោមគោលការណ៍អប់រំផ្នែកអំណានគឺ ដើម្បីឲ្យអានបានល្អតម្រូវឲ្យកុមារអានឲ្យបានញឹកញាប់ និងអានអត្ថបទដែលគួរចាប់អារម្មណ៍ឲ្យបានច្រើនមុខ។ នេះជាការលំបាកមួយនៅក្នុងសហគមន៍ភាសាភាគតិចដែលមានអក្សរសរសេរតិចតួច ឬគ្មានតែម្តង។ មេដឹកនាំកម្មវិធីភាសាកាមបានដឹងថា គេត្រូវចាប់ផ្តើមភ្លាម និងខំប្រឹងប្រែងធ្វើការងារ ដើម្បីកសាងឯកសារអានដែលជាឯកសារចាំបាច់សម្រាប់គម្រោងរបស់ខ្លួន។

14 Geary, N. and Pan, Y. 2001 (19-21 September) *Eight Hundred Stories for Dong Development: A Bilinguage Education Pilot Project in Guizhou Province, China.* 6th Oxford International Conference on Education and Development. Oxford, United Kingdom.

15 “Kam” (pronounced like “gum” in English) is the name the people call themselves. Other people in China often refer to this group as the “Dong”.

ការកសាងឯកសារអានបានចាប់ផ្ដើមឡើងជាមួយនឹងសិក្ខាសាលា ដែលធ្វើឡើងសម្រាប់អ្នកសរសេរសៀវភៅ។ ដោយយោងទៅតាមប្រតិទិននៃវប្បធម៌ជនជាតិកាម និងកម្រងអត្ថបទខ្លីៗស្ដីពីវប្បធម៌អ្នកសរសេរសៀវភៅ អ្នកនិយាយភាសាកំណើតក៏ចាប់ផ្ដើមសរសេរបន្តិចម្ដងៗនូវរឿងដែលងាយអានសរុបចំនួន ១៦០ រឿង ជាភាសាកាមសម្រាប់ឆ្នាំទី ១ នៃមត្តេយ្យសិក្សាព្រមទាំង ១៦០ រឿងផ្សេងទៀតសម្រាប់ឆ្នាំទី ២។

អ្នកអប់រំភាសាកាមបានយល់ថា កុមារនឹងត្រូវការរឿងនិងអត្ថបទបន្ថែមទៀតនៅពេលរៀនបន្តទៅមុខចាប់ពីថ្នាក់ទី ១ ដល់ទី ៦។ សៀវភៅទាំងនេះនឹងជួយដល់កុមារឲ្យមានភាពស្ទាត់ជំនាញក្នុងភាសាកាមរបស់ខ្លួននៅពេលដែលពួកគេកំពុងតែរៀនអាននិងសរសេរភាសាចិន។ អាស្រ័យហេតុនេះអ្នកសរសេរសៀវភៅភាសាកាមបានសរសេររឿងប្រហែលជា ៤០ រឿង សម្រាប់ឆ្នាំសិក្សានីមួយៗនៅបឋមសិក្សា។ រឿងទាំងនោះនិយាយអំពីប្រធានបទដែលធ្វើឲ្យកុមារជនជាតិកាមមានការចាប់អារម្មណ៍។ ក្រៅពីរឿងទាំងនោះ អ្នកនិយាយភាសាកាម ក៏បានសរសេររឿងបន្ថែមចំនួន ១២០ រឿងផ្សេងទៀតសម្រាប់ឲ្យកុមារហាត់អានដោយខ្លួនឯង។

ការផ្ដល់ឯកសារអានឲ្យបានគ្រប់គ្រាន់ជូនដល់សិស្សជនជាតិកាមបានជួយឲ្យកុមារទាំងឡាយពង្រឹងសមត្ថភាពឲ្យបានខ្ពស់ផ្នែកភាសារបស់ខ្លួន ហើយផ្ដល់នូវជំនឿទុកចិត្តដល់ពួកគេឲ្យប្រែក្លាយអ្វីដែលពួកគេដឹងឲ្យទៅជាការអាន និងការសរសេរភាសាចិន។

ការអង្កេតជាលើកដំបូងបង្ហាញឲ្យឃើញថា កុមារជនជាតិកាមនៅកម្រិតដំបូងនៃបឋមសិក្សាកំពុងតែអាននិងសរសេរភាសាចិនបានល្អប្រសើរជាងពេលមុន។

## ៦. *ការជ្រើសរើសនិងការបណ្ដុះបណ្ដាលបុគ្គលិកសម្រាប់កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត:*

កម្មវិធីអប់រំពហុភាសាដែលជោគជ័យបំផុត គឺជាកម្មវិធីដែលជ្រើសរើសបុគ្គលិកដែលមានឆន្ទៈនិងគួរឲ្យគោរព ហើយជួយពួកគេឲ្យពង្រឹងចំណេះដឹង ជំនាញ ការច្នៃប្រឌិតនិងការតាំងចិត្តចំពោះតួនាទីដែលគេប្រគល់ឲ្យបំពេញ។ គេត្រូវការបុគ្គលិកជាចាំបាច់សម្រាប់អនុវត្តសកម្មភាពទាំងពីរប្រភេទដូចខាងក្រោម :

| សម្រាប់ពហុភាសា | សម្រាប់ភាសាតែមួយ |
|---|---|
| _ធ្វើផែនការនិងសម្របសម្រួលកម្មវិធី<br>_អភិវឌ្ឍកម្មវិធីសិក្សា<br>_បណ្ដុះបណ្ដាលបុគ្គលិក (រួមបញ្ចូលទាំងការបណ្ដុះបណ្ដាលគ្រូឧទ្ទេស)<br>_ត្រួតពិនិត្យការកសាងនិងផលិតឯកសារ (ជាពហុភាសា)<br>_ត្រួតពិនិត្យថ្នាក់ | _ធ្វើផែនការនិងសម្របសម្រួលកម្មវិធី<br>_បង្រៀនសិស្សតាមថ្នាក់<br>_បង្កើតឯកសារសម្រាប់អាន<br>_គូររូបភាពពន្យល់ឯកសារ<br>_ផ្ទៀងផ្ទាត់ឯកសារ<br>_គាំទ្រដល់កម្មវិធី (បង្កើតគណៈកម្មាការទ្រទ្រង់ការងារអប់រំពហុភាសា) |

បញ្ហាមួយដែលកម្មវិធីអប់រំពហុភាសាត្រូវប្រឈមមុខនោះ គឺកង្វះខាតអ្នកនិយាយភាសាកំណើតនៅតាមសហគមន៍ដែលអាចបង្រៀនបាន។ ប៉ុន្តែបញ្ហានេះអាចនឹងត្រូវដោះស្រាយបានប្រសិនបើគេអនុវត្តនិងថែរក្សាឱ្យមាននិរន្តរភាពនៃកម្មវិធីអប់រំពហុភាសា។ រហូតមកទល់ពេលនេះមានដំណោះស្រាយមួយគឺកំណត់ឱ្យឃើញនូវបុគ្គលិកណាដែលមានភាពស្ទាត់ជំនាញក្នុងភាសាតាមមូលដ្ឋានដែលយល់និងទទួលស្គាល់វប្បធម៌ក្នុងស្រុកហើយត្រូវទទួលការគោរពពីអ្នកដទៃនៅក្នុងសហគមន៍នោះព្រមទាំងបំពាក់បំប៉នឱ្យពួកគេបំពេញការងារបង្រៀន។ បទពិសោធន៍តាមបណ្ដាប្រទេសនានានៅជុំវិញពិភពលោកបានបង្ហាញថា គ្រូបង្រៀនដែលមិនមានវិជ្ជាជីវៈក៏អាចបង្រៀនបានល្អដែរប្រសិនបើពួកគេមានឯកសារបង្រៀនងាយប្រើប្រាស់ មានការបណ្ដុះបណ្ដាលប្រកបដោយគុណភាពខ្ពស់ មុនពេលនិងកំពុងបម្រើការងារព្រមទាំងមានការត្រួតពិនិត្យដែលមានលក្ខណៈគាំទ្រ។ ប្រសិនបើគ្រូនៅតាមមូលដ្ឋានគ្មានជំនាញនៅក្នុងផ្នែកភាសាផ្លូវការទេ នោះសមាសភាគរៀនសូត្រផ្នែកភាសាចាំបាច់ត្រូវបញ្ចូលទៅក្នុងវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀន។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនោះគឺត្រូវប្រើប្រាស់ "ការបង្រៀនជាក្រុម" ពោលគឺជំនួយការគ្រូបង្រៀនម្នាក់ដែលមកពីសហគមន៍ធ្វើការជាប្រចាំជាមួយគ្រូបង្រៀននៅសាលាបឋមសិក្សាដែលមានប្រភពមកពីខាងក្រៅសហគមន៍ហើយពួកគេម្នាក់ៗត្រូវទទួលបន្ទុកលើការងារថ្នាក់រៀនជាភាសារបស់ខ្លួនផ្ទាល់។

**ឧទាហរណ៍**

**ការជ្រើសរើសនិងការបណ្ដុះបណ្ដាលគ្រូនៅប្រទេសកម្ពុជា**[១៦]

គោលបំណងនៃគម្រោងអប់រំកុមារនៅតំបន់ខ្ពង់រាបក្នុងខេត្តរតនគីរីនៃប្រទេសកម្ពុជាគឺត្រូវកសាងសាលារៀននៅតាមភូមិក្នុងសហគមន៍នៃភាសាជនជាតិភាគតិច ដែលសហគមន៍ទាំងនោះទទួលការអប់រំ ឬសេវាកម្មអប់រំជាមូលដ្ឋានរបស់រដ្ឋាភិបាលនៅមានកម្រិត ឬឥតបានទទួលសោះតែម្ដង។ ការងារផ្ដល់ការអប់រំនេះតម្រូវឱ្យមានកិច្ចប្រឹងប្រែងតស៊ូការលំបាក ជាពិសេសនៅក្នុងតំបន់ខ្ពង់រាបដាច់ស្រយាល ដោយសារកង្វះខាតគ្រូបង្រៀនឥតឈប់ឈរនិងការចូលរៀនមិនទៀងទាត់ ព្រមទាំងកង្វះខាតឯកសារបង្រៀននិងរៀនដែលមានលក្ខណៈសមស្របទៅតាមវប្បធម៌។

ក្រុមប្រឹក្សាភិបាលកម្រងសាលាតាមភូមិ-ឃុំជាអ្នកទទួលខុសត្រូវលើការងារគ្រប់គ្រងសាលារៀនរបស់ខ្លួននិងជ្រើសរើសគ្រូបង្រៀន។ គ្រូបង្រៀននិយាយភាសានៅក្នុងមូលដ្ឋានបានល្អដូចភាសាខ្មែរដែលជាភាសាជាតិ។ ដោយហេតុថា លោកគ្រូអ្នកគ្រូមានប្រភពមកពីសហគមន៍មូលដ្ឋានរបស់កុមារនោះ ពួកគាត់ក៏មានចំណេះដឹង និងបទពិសោធន៍ដូចសិស្សរបស់គាត់ដែរ។ ការលំបាកដែលគេបានកត់សម្គាល់ដូចខាងលើ គឺដោយសារតែទទួលបានការរៀនសូត្រកាលពីមុននៅមានកម្រិត ទើបបានជាគ្មានមនុស្សណាម្នាក់ត្រូវបានគេជ្រើសរើសឱ្យបង្រៀននៅតាមសាលាប្រចាំភូមិដោយសារគេរៀនពុំបានចប់កម្រិតបឋមសិក្សា។

16 Middleborg, J.2005. Highland Children's Education Project: Good Lessons Learned in Basic Education. Bangkok, UNESCO.

វគ្គបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់គម្រោងអប់រំកុមារតំបន់ខ្ពង់រាបត្រូវបានគ្រោងឡើង ដើម្បីរៀបចំបុគ្គលិកទាំងនេះឲ្យក្លាយជាគ្រូបង្រៀននៅតាមតំបន់ដាច់ស្រយាលដែលប្រើភាសាពីរ និងមានវប្បធម៌ពីរបែប។ វគ្គនេះមានគោលបំណងបណ្តុះបណ្តាលសិក្ខាកាមដែលមកពីក្រុមជនជាតិភាគតិចជាម្ចាស់ស្រុកឲ្យក្លាយជាគ្រូបង្រៀនស្របតាមវប្បធម៌ និងតាមរយៈការធ្វើកិច្ចការដូចខាងក្រោម ៖

- បង្កលទ្ធភាពឲ្យសិក្ខាកាមអាចអភិវឌ្ឍនិងពង្រីកនូវចំណេះដឹងរបស់ខ្លួនបាន។
- បំពាក់បំប៉នឲ្យពួកគេទទួលបានចំណេះដឹងនិងជំនាញផ្នែកវិធីសាស្រ្តបង្រៀន។
- រៀបចំឲ្យពួកគេក្លាយជាគ្រូបង្រៀន ដែលមានវិជ្ជាជីវៈប្រកបដោយគំនិតជ្រៅជ្រះនិងជាអ្នកព្យាយាមអភិវឌ្ឍខ្លួនឲ្យប្រសើរឡើងឥតឈប់ឈរ។
- បំពាក់បំប៉នឲ្យពួកគេចូលរួមក្នុងការអភិវឌ្ឍន៍សហគមន៍ តាមរយៈវេទិកាដែលមានការចូលរួមពីអ្នកពាក់ព័ន្ធព្រមទាំងតាមរយៈដំណើរការសិក្សានិងអប់រំ។
- ចូលរួមក្នុងការជំរុញនូវជំហរផ្នែកសង្គមរបស់ខ្លួនឲ្យបានប្រសើរឡើងនៅក្នុងសហគមន៍។
- គាំទ្រដល់ការអភិវឌ្ឍន៍ទស្សនៈម្ចាស់ស្រុកស្តីពីការងារអប់រំ។

ការបណ្តុះបណ្តាលគ្រូបង្រៀនកើតឡើងជា "ការសិក្សាវិលជុំ" ក្នុងនោះសិក្ខាកាមចូលរួមផ្តល់ជាទស្សនៈ យោបល់យ៉ាងស្វិតស្វាញហើយត្រូវអនុវត្តជាបន្តបន្ទាប់និងមានការវាយតម្លៃលើសកម្មភាពអនុវត្តនេះ។ នេះជា "វិធីស្រាវជ្រាវសកម្មភាព" មួយដែលត្រូវបានគេទទួលស្គាល់ទូទាំងសកលលោក ជាពិសេសត្រូវបានអ្នកអប់រំទទួលស្គាល់ថា ជាយុទ្ធសាស្រ្តមួយសម្រាប់ការលើកកម្ពស់អភិវឌ្ឍការងាររៀនសូត្រប្រកបដោយប្រសិទ្ធភាពនិងប្រតិបត្តិដ៏ត្រឹមត្រូវ។

៧. ***ការចងក្រងឯកសារទុកនិងការវាយតម្លៃកម្មវិធី :*** នៅក្នុងកម្មវិធីអប់រំពហុភាសាដែលមានប្រសិទ្ធភាព និងនិរន្តរភាព ការវាយតម្លៃនិងការកត់ត្រាត្រូវចាប់ផ្តើមឡើងនៅដំណាក់កាលធ្វើផែនការ ហើយបន្តរហូតមួយចប់កម្មវិធី។ ខាងក្រោមនេះគឺជាសមាសធាតុនៃកម្មវិធីដែលគួរនឹងធ្វើការកត់ត្រាជាឯកសារ និងវាយតម្លៃជាប្រចាំ ហើយក៏ជាសំណួរមួយចំនួនដែលអាចជួយណែនាំក្នុងដំណើរការកត់ត្រាឯកសារ និងវាយតម្លៃ ៖

- *កម្មវិធីសិក្សា និងវិធីសាស្រ្តបង្រៀន :* តើលទ្ធផលសិក្សាមានភាពច្បាស់លាស់ឬទេ? តើលោកគ្រូអ្នកគ្រូមានការងាយស្រួលនឹងវិធីសាស្រ្តបង្រៀននេះឬទេ? តើខ្លឹមសារមេរៀនសមស្របទៅនឹងវប្បធម៌ក្នុងមូលដ្ឋាននោះឬទេ? តើគេអាចកែលំអកម្មវិធីសិក្សានេះបានយ៉ាងដូចម្តេច?
- *បុគ្គលិក :* តើលោកគ្រូអ្នកគ្រូគោរពតាមផែនការបង្រៀនឬទេ? តើអ្នកមើលការខុសត្រូវ និងគ្រូឧទ្ទេសផ្តល់ការលើកទឹកចិត្តនិងគាំទ្រដល់បុគ្គលិកនៅតាមមូលដ្ឋានឬទេ? តើគេអាចធ្វើអ្វីបានខ្លះដើម្បីជួយដល់បុគ្គលិកគ្រប់លំដាប់ថ្នាក់ក្នុងការកសាងនូវសមត្ថភាព ជំនឿទុកចិត្ត និងការច្នៃប្រឌិតថ្មីនៅក្នុងការប្រតិបត្តិកិច្ចការរបស់ខ្លួននេះ?

■ *ការបណ្តុះបណ្តាល* : តើលោកគ្រូអ្នកគ្រូដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលរួចហើយនោះ បានបង្ហាញឲ្យឃើញថា ខ្លួនយល់ពីវិធីសាស្ត្របង្រៀនដែរឬទេ? តើអ្នកសរសេរឯកសារដែលបានបញ្ចប់សិក្ខាសាលារួចហើយ បានបង្ហាញនូវសមត្ថភាពច្នៃប្រឌិត ប្រើរូបភាពពន្យល់ ពិនិត្យផ្ទៀងផ្ទាត់ និងសាកល្បងឯកសារភាសាកំណើតរបស់ខ្លួនឬទេ? តើគេអាចកែលម្អការបណ្តុះបណ្តាលនេះឲ្យប្រសើរឡើងយ៉ាងដូចម្តេច?

■ *ឯកសារ* : តើឯកសារបង្រៀនសម្រាប់គ្រូមិនមែនអាជីពមានលក្ខណៈច្បាស់លាស់និងងាយប្រើប្រាស់ឬទេ? តើអ្នកនិយាយភាសាកំណើតចាត់ទុកថា ឯកសារសម្រាប់អានមានភាពសមស្របដែរឬទេ? តើសិស្សទាំងឡាយអាចអានឯកសារទាំងនេះបានដែរឬទេ? តើពួកគេពេញចិត្តវាឬទេ? តើប្រព័ន្ធសម្រាប់ផលិតឯកសារអាននេះមានប្រសិទ្ធភាពដូចដែលគេត្រូវការឬទេ? តើប្រព័ន្ធចែកផ្សាយមានប្រសិទ្ធភាពនិងអាចជឿជាក់បានឬទេ?តើផ្នែកណាខ្លះដែលអាចកែលម្អឲ្យប្រសើរឡើងបាន?

■ *ការរីកចម្រើនរបស់សិស្ស* : តើសិស្សបានបង្ហាញឲ្យឃើញថា ពួកគេទទួលលទ្ធផលរៀនសូត្រស្របតាមកម្រិតថ្នាក់រៀនរបស់ខ្លួនដែរឬទេ? តើពួកគេរីកចម្រើនទៅមុខប្រកបដោយជោគជ័យពីកម្រិតមួយទៅកម្រិតមួយទៀតដែរឬទេ? តើសិស្សទាំងនេះ និងឪពុកម្តាយរបស់ពួកគេពេញចិត្តនឹងការរីកចម្រើននេះដែរឬទេ? តើគេអាចធ្វើអ្វីខ្លះដើម្បីជួយឲ្យសិស្សទាំងនេះកាន់តែទទួលបានជោគ-ជ័យថែមទៀត?

■ *កំណើននិងគុណភាពនៃកម្មវិធី* : តើកម្មវិធីនេះរីកលូតលាស់ទៅមុខស្របតាមការគ្រោងទុកដែរឬទេ? តើអ្នកទទួលខុសត្រូវលើកម្មវិធីនេះ (រួមបញ្ចូលទាំងសមាជិកសហគមន៍ប្រើភាសាជនជាតិភាគតិច)មានការពេញចិត្តនឹងការរីកចំរើនរបស់កម្មវិធីដែរឬទេ? តើគេអាចធ្វើអ្វីបានខ្លះដើម្បីធានាឲ្យបានថា គុណភាពនៃកម្មវិធីត្រូវបានថែរក្សាឲ្យបានគង់វង្សក្នុងពេលដែលវាកាន់តែរីកចម្រើនថែមទៀត?។

■ *ប្រសិទ្ធភាពនៃការចំណាយ* : តើបុគ្គលិកពាក់ព័ន្ធយល់ថា ការចំណាយទៅលើកម្មវិធីសមរម្យដែរឬទេ? ប្រសិនបើកម្មវិធីនេះជាកម្មវិធីថ្មីនិងដោយមិនធ្វើឲ្យមានការបាត់បង់នូវគុណភាពនៃកម្មវិធីតើមានវិធីណាដែលធ្វើឲ្យការចំណាយកាន់តែមានប្រសិទ្ធភាពនោះ?

■ *ឥទ្ធិពលយូរអង្វែងនៃកម្មវិធី* : តើកម្មវិធីបានធ្វើឲ្យមានការផ្លាស់ប្តូរអ្វីខ្លះសម្រាប់សហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចនិងសម្រាប់សង្គមទាំងមូល?

ការកសាងឧបករណ៍វាយតម្លៃដ៏សមហេតុសមផល ការកត់ត្រាលទ្ធផលឯកសារ បន្ទាប់មកប្រើប្រាស់ព័ត៌មាននេះដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរដែលចាំបាច់គឺជួយធានាថា កម្មវិធីនេះនឹងឆ្លើយតបទៅនឹងការរំពឹងទុករបស់អ្នកទទួលខុសត្រូវ ព្រមទាំងអ្នកផ្តល់ថវិកាសម្រាប់កម្មវិធីនេះ។ សំខាន់បំផុតនោះ វាជួយធានាឲ្យកម្មវិធីនេះបានសម្រេចគោលដៅឆ្លើយតបទៅនឹងការរំពឹងទុករបស់សហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិច។ ក្រៅពីនេះ ការកត់ត្រាឯកសារអំពីភាពខ្លាំងនិងភាពខ្សោយនៃកម្មវិធីដែលមានស្រាប់ អាចផ្តល់ព័ត៌មានដ៏មានតម្លៃសម្រាប់អ្នកធ្វើផែនការកម្មវិធីថ្មីៗ។

## ឧទាហរណ៍នៃការកត់ត្រាឯកសារនិងការវាយតម្លៃកម្មវិធីអប់រំពហុភាសា គម្រោងស្រាវជ្រាវរយៈពេលយូរ

ការសិក្សាស្រាវជ្រាវស្តីពីកម្មវិធីអប់រំពហុភាសានៅអឺរ៉ុប និងអាមេរិកខាងជើងបានរកឃើញថា អត្ថប្រយោជន៍នៃការងារអប់រំពហុភាសាត្រូវបានគេយល់កាន់តែច្បាស់ បន្ទាប់ពីមានការអនុវត្តជាច្រើនឆ្នាំកន្លងមក។ អាស្រ័យហេតុនេះ ការវាយតម្លៃកម្មវិធីអប់រំពហុភាសាដ៏ត្រឹមត្រូវនិងប្រាកដនោះ ត្រូវតាមអង្កេតមើលក្រុមសិស្សដែលប្រើភាសាភាគតិចនៅក្នុងកម្មវិធីអប់រំពហុភាសារហូតដល់ពួកគេបញ្ចប់ការសិក្សា ដើម្បីប្រៀបធៀបសមត្ថភាពរបស់ពួកគេនៅសាលារដ្ឋជាមួយនឹងសិស្សដែលមិនបានទទួលការអប់រំជាភាសាកំណើត។

រហូតមកទល់ពេលថ្មីៗនេះ ការស្រាវជ្រាវប្រភេទនេះមានតិចតួចណាស់នៅទ្វីបអាស៊ី-ប៉ាស៊ីហ្វិក ឬអាហ្វ្រិក។ ដើម្បីផ្តល់ព័ត៌មានអំពីការអប់រំពហុភាសាដល់អ្នកកសាងគោលនយោបាយនិងអ្នកអប់រំដែលមកពីតំបន់ទាំងនេះ គម្រោងស្រាវជ្រាវរយៈពេលយូរមួយ ក៏ត្រូវបានអង្គការអន្តរជាតិ SIL ផ្តួចផ្តើមធ្វើឡើងនៅឆ្នាំ ២០០៣ ដើម្បីប្រមូលនិងវិភាគទិន្នន័យដែលបានមកពីកម្មវិធីអប់រំពហុភាសាក្នុងរយៈពេល ១០ ឆ្នាំមកនេះ។

គម្រោងនេះនឹងតាមដានពិនិត្យសិក្ខាកាមដែលជាសិស្សក្នុងថ្នាក់រៀនប្រើភាសាកំណើត និងសិស្សក្នុងថ្នាក់ដែលមិនប្រើភាសាកំណើតតាំងពីសាលាបឋមសិក្សារហូតដល់ពួកគេចូលមធ្យមសិក្សា។ គេនឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះវត្តមានរបស់សិស្ស ទិន្នន័យនៃការចូលរៀនបន្តរបស់សិស្ស លទ្ធផលនៃការសិក្សារបស់សិស្សដែលបានមកពីការប្រឡងតាមមូលដ្ឋាននៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ ព្រមទាំងការវាយតម្លៃលើឯកសារនិងវិធីសាស្ត្របង្រៀន ឥរិយាបថរបស់គ្រូបង្រៀន ការបណ្តុះបណ្តាលនិងការត្រួតពិនិត្យ។

៨. ***កិច្ចសហប្រតិបត្តិការ រៅាងទីភ្នាក់ងារគាំទ្រទាំងអស់ :*** រដ្ឋាភិបាលតែឯងមិនអាចធ្វើផែនការ និងអនុវត្តកម្មវិធីឲ្យមាននិរន្តរភាពនិងរឹងមាំដោយគ្មានការចូលរួមរបស់សហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចឡើយ។ ដូចគ្នានេះដែរចំពោះសហគមន៍ ទោះបីជាមានជំនួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលហើយក៏ដោយ ក៏មិនអាចរក្សានិរន្តរភាពនៃកម្មវិធីរបស់ខ្លួនដោយគ្មានការគាំទ្ររបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់នោះដែរ។ កម្មវិធីអប់រំពហុភាសាដែលរឹងមាំនិងមាននិរន្តរភាពគឺជាកម្មវិធីតម្រូវឲ្យមានកិច្ចសហការរួមគ្នានិងការគាំទ្រពីទីភ្នាក់ងារបម្រុះដូចជា រដ្ឋាភិបាល សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការដទៃទៀត ដែលធ្វើការជាមួយសហគមន៍ ។ ការកសាងកិច្ចសហប្រតិបត្តិ ការរវាងទីភ្នាក់ងារគាំទ្រទាំងនោះ គឺបានប្រើប្រាស់ធនធានឲ្យមានប្រយោជន៍ដោយរាប់បញ្ចូលទាំង បទពិសោធន៍ និងជំនាញរបស់ដៃគូនីមួយៗផង។

## *សំណួរទី ៥ : តើយើងមានលទ្ធភាពអនុវត្តកម្មវិធីអប់រំពហុភាសានេះជាភាសាចម្រុះបានដែរឬទេ? តើការប្រឹងប្រែងនេះមានតម្លៃឬទេ?*

សំណួរមួយដែលប្រសើរជាងនេះគឺ “តើយើងអាចទទួលយកនូវលទ្ធផលចុងក្រោយដែរឬទេ ប្រសិនបើយើងមិនផ្តល់ការអប់រំដ៏សមស្របដល់អ្នកនិយាយភាសាជនជាតិភាគតិច?”

*“យើងមានភស្តុតាងដែលមានរយៈពេលពីរឬបីរយឆ្នាំមកហើយដែលថា ការមិនប្រើភាសាទីពីរក្នុងការបង្រៀនអាចបង្កឲ្យមានការបាត់បង់ប្រសិទ្ធភាពក្នុងកម្រិតខ្ពស់ “ព្រោះថា ប្រព័ន្ធអប់រំបែបនេះនាំឲ្យមានអត្រាត្រួតថ្នាក់និងការបោះបង់ការសិក្សាខ្ពស់ព្រមទាំងអត្រាបញ្ចប់ការសិក្សាមានកម្រិតទាប។ ការខាតបង់របស់បុគ្គលិកដែលធ្វើពលិកម្ម ពេលវេលាសម្រាប់ធ្វើការងារកសិកម្ម និងសម្រាប់គ្រួសារដើម្បីទៅរៀនមានកម្រិតខ្ពស់ហើយលទ្ធផលពួកគេបានត្រឹមតែទទួលបរាជ័យ និងការបដិសេធតែប៉ុណ្ណោះ។ ដូច្នេះការខាតបង់របស់សង្គមមានទំហំធំធេង ដែលមួយផ្នែកបណ្តាលមកពីកង្វះខាតនៃការចូលរួមគ្រប់គ្រង។”[១៧]*

ក្រៅពីគុណប្រយោជន៍នៃការអប់រំនិងផ្នែកហិរញ្ញវត្ថុ កម្មវិធីអប់រំពហុភាសាបម្រើនូវគោលបំណងមួយទៀត ពោលគឺការគាំទ្ររបស់រដ្ឋាភិបាលចំពោះកម្មវិធីអប់រំពហុភាសាបានចង្អុលប្រាប់ដល់ប្រជាពលរដ្ឋគ្រប់រូបថា ភាសាជនជាតិភាគតិចនិងមនុស្សដែលនិយាយភាសាទាំងនេះ គឺត្រូវបានគេឲ្យតម្លៃ។

17 Benson, C. 2001 (20 April). Real and Potential Benefits of Bilingual Programmes in Developing Countries. Third International Symposium on Bilinggualism. Bristol, England.

កម្មវិធីអប់រំពហុភាសាជួយអ្នករៀនឲ្យ "កសាងស្ពាន"មួយដ៏ល្អរវាងភាសាកំណើតនិងភាសាផ្លូវការ និងជួយពង្រឹងសាមគ្គីភាពជាតិដោយមិនបង្ខំឲ្យប្រជាជនបោះបង់កេរដំណែលវប្បធម៌ និងភាសាតែមួយរបស់ខ្លួនឡើយ។ បទពិសោធន៍ទូទាំងពិភពលោកបានចង្អុលបង្ហាញថា ការមិនព្រមទទួលឬការគាបសង្កត់ដល់កេរដំណែលនៃវប្បធម៌ និងភាសារបស់ប្រជាជនគឺជាបុព្វហេតុនៃការទាស់ទែងគ្នា។ ការងារអប់រំពហុភាសាគាំទ្រដល់ការសាមគ្គីដោយឲ្យតម្លៃទៅលើភាពសម្បូរបែប។ មនុស្សដែលសាកសមបំផុតក្នុងការឆ្លើយសំណួរ "តើការប្រើងប្រែងនេះមានតម្លៃឬទេ?" គឺជាសមាជិកនៃសហគមន៍ជនជាតិភាគតិចខ្លួនឯងនេះតែម្តង។ ខាងក្រោមនេះគឺជាទស្សនៈរបស់មាតាបិតាសិស្សម្នាក់មកពីប្រទេសប៉ាពួញូហ្គីណេ ៖

*"នៅពេលដែលកុមារទៅរៀន ពួកគេមានអារម្មណ៍ថា ទៅកន្លែងមួយដែលប្លែក។ ពួកគេចាកចោលឪពុកម្តាយ ចាកចោលស្រែចម្ការ ពួកគេចាកចេញពីអ្វីៗគ្រប់យ៉ាងដែលជារបៀបរស់នៅរបស់ខ្លួន។ ក្មេងទាំងនេះអង្គុយក្នុងថ្នាក់ និងរៀនអំពីរឿងដែលមិនទាក់ទងទៅនឹងកន្លែងរស់នៅរបស់ខ្លួនសោះ។ ក្រោយមកទៀតដោយសារតែពួកគេបានរៀនសូត្រតែពីរឿងខាងក្រៅសហគមន៍ ពួកគេក៏ប្រានចោលនូវអ្វីៗដែលជារបស់ខ្លួនផ្ទាល់។*

*ពួកគេមិនចង់ជីកដីដើម្បីដាំដំឡូងទេ ដោយនិយាយថា ធ្វើបែបនេះជារឿងកខ្វក់។ ពួកគេមិនចង់ជួយដងទឹកម្តាយទេ។ ពួកគេមើលស្រាលការងារទាំងនោះ។ មានការផ្លាស់ប្តូរជាច្រើនចំពោះក្មេងៗទាំងនេះនាពេលបច្ចុប្បន្ន។ ពួកគេមិនគោរពឪពុកម្តាយហើយក្លាយទៅជាមនុស្សខូច។ រឿងហេតុទាំងនេះកើតឡើងដោយសារតែពួកគេបានរៀនអ្វីដែលថ្មី ហើយទុកចោលនូវអ្វីៗទាំងឡាយដែលជារបស់ពួកយើង។*

*"ឥឡូវនេះកូនរបស់ខ្ញុំកំពុងនៅក្នុងសាលាប៉ុន្តែវាមិនមានអារម្មណ៍ថា វានៅក្រៅសហគមន៍ទេ។ វាកំពុងរៀននៅឯសាលាអំពីទំនៀមទម្លាប់និងរបៀបរស់នៅរបស់វា។ បច្ចុប្បន្ននេះវាអាចសរសេរអ្វីដែលវាចង់សរសេរ ទាំងអ្វីដែលវាមើលឃើញ និងអ្វីៗដែលវាអាចគិតដល់។ វាសរសេរអំពីរឿងជួយរែកទឹកម្តាយ រឿងធ្វើស្រែ និងរឿងទៅថែទាំដំណាំ។*

*នៅពេលដែលវាសរសេរអំពីរឿងទាំងនេះ រឿងដែលវាសរសេរក៏ក្លាយទៅជារបស់យ៉ាងសំខាន់ចំពោះរូបវា។ វាមិនត្រឹមតែអាននិងសរសេរអំពីរឿងរ៉ាវនៅខាងក្រៅប៉ុណ្ណោះទេ គឺថែមទាំងរៀនសូត្រតាមរយៈការអាននិងសរសេរដើម្បីសម្តែងមោទនភាពចំពោះរបៀបរស់នៅរបស់យើងទៀតផង។ នៅពេលវាធំឡើង វានឹងមិនបោះបង់យើងចោលឡើយ។ ការបង្រៀនកូនចៅរបស់យើងឲ្យចេះអាននិងសរសេរគឺមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែវារឹតតែសំខាន់ទៅទៀតក្នុងការបង្រៀនពួកគេឲ្យមានមោទនភាពចំពោះខ្លួនឯងនិងចំពោះពួកយើងផង។"*[១៨]

18 Delpit, L.D. and Kemelfield, G. 1985. An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province. ERU Report No. 51. Waigani, Papua New Guinea, University of Papua Guinea. pp. 29-30.

## គណៈកម្មការរៀបចំ

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| លោក ភុង ហនស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អ្នកស្រី ស៊ិន ឡេ | អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការយូណេស្កូ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក ឡុង សុជាត | មន្ត្រីការិយាល័យក្រោយអក្ខរកម្ម |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| អ្នកស្រី លី ខេង | មន្ត្រីការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នកផ្ទៀងផ្ទាត់ និងកែសម្រួល**

| | |
|---|---|
| លោក មោគ គឿន | អនុប្រធានការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| លោក តាន់ ដន | ជំនួយការកម្មវិធីអប់រំនៃអង្គការយូណេស្កូ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នករចនាអត្ថបទ**

| | |
|---|---|
| លោក ឈិន វ៉ុត | ប្រធានការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| អ្នកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |

បានទទួលការអនុញ្ញាតឲ្យបោះពុម្ព និង ប្រើប្រាស់ពីក្រសួងអប់រំ យុវជន និង កីឡា
តាមរយៈប្រកាសលេខ ៥១ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

Japanese
Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្តីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

## សៀវភៅសម្រាប់សមាជិកសហគមន៍



ឯកសារជំនួយស្តីពីការលើកកម្ពស់ការអប់រំពហុភាសារួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន

បាងកក : យូណេស្កូបាងកក ២០០៧
សៀវភៅ ៥ ក្បាល
1_ ទស្សនៈទូទៅនៃឯកសារជំនួយ 2_ភាសាប្រើប្រាស់ក្នុងគោលនយោបាយអប់រំ និងការអនុវត្តក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក 3_សៀវភៅសម្រាប់អ្នកកសាងគោលនយោបាយ 4_សៀវភៅសម្រាប់អ្នកអនុវត្តកម្មវិធី 5_សៀវភៅសម្រាប់សមាជិកសហគមន៍

ISBN 92-9223-110-3

© UNESCO 2007

បានបោះពុម្ពផ្សាយដោយ
ការិយាល័យអប់រំអង្គការ UNESCO ប្រចាំតំបន់អាស៊ី_ប៉ាស៊ីហ្វិក
អាសយដ្ឋាន: 920 Sukhumvit Road, Prakanong
ទីក្រុងបាងកក ១០១១០.ប្រទេសថៃ

បានបកប្រែនិងកែសម្រួលពីច្បាប់ដើម *(ភាសាអង់គ្លេស)*

ឯកសារនិងរូបភាពទាំងអស់ដែលយកមកប្រើក្នុងការបោះពុម្ពផ្សាយនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុងឬតំបន់ណាមួយ ឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងការកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌

# ឯកសារជំនួយស្ដីពី

# ការលើកកម្ពស់ការអប់រំពហុភាសា

## *រួមបញ្ចូលទាំងអ្នកដែលនៅក្រៅសាលារៀន*

## សៀវភៅសម្រាប់សមាជិកសហគមន៍

# សៀវភៅសម្រាប់សមាជិកសហគមន៍

## សេចក្តីផ្តើម

ចំពោះកុមារក្នុងសហគមន៍ជនជាតិភាគតិច សាលារៀនជាទីកន្លែងដែលគេមិនស្គាល់ បង្រៀនអំពីទស្សនៈឬខ្លឹមសារដែលគេមិនដែលជួបប្រទះ និងប្រើភាសាដែលគេមិនចេះស្តាប់។ ចំណេះដឹង និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេគឺគ្មានទេនៅក្នុងប្រព័ន្ធសាលាចំណេះទូទៅ។ ពួកគេហាក់ដូចជាត្រូវបានផាត់ចោលពីការសិក្សាអប់រំ បើឪពុកម្តាយរបស់គេមិននិយាយភាសាផ្លូវការទេនោះ។ ឪពុកម្នាក់បាននិយាយរៀបរាប់ពីបទពិសោធន៍នៅសហគមន៍គាត់អំពីសាលារៀនដែលប្រើប្រាស់ភាសាដែលមានឥទ្ធិពលនៅប្រទេសប៉ាពួញូហ្គីណេ។

"នៅពេលកុមារតូចៗទៅសាលារៀន ពួកគេហាក់ដូចជាទៅទីកន្លែងចម្លែកមួយ។ ពួកគេចាកចោលឪពុកម្តាយ ស្រែចំការ និងអ្វីៗគ្រប់យ៉ាងដែលគេមានក្នុងជីវិតប្រចាំថ្ងៃរបស់គេ។ ពួគគេអង្គុយនៅក្នុងថ្នាក់រៀន ហើយរៀនអ្វីដែលពុំមាននៅទីកន្លែងរស់នៅផ្ទាល់របស់គេ។ ក្រោយមកដោយពួកគេបានរៀនអ្វីៗផ្សេងដែលមិនទាក់ទងទៅនឹងការរស់នៅរបស់ខ្លួន ពួកគេក៏ប្រានចោលទំនៀមទម្លាប់ និងវប្បធម៌ក្នុងសហគមន៍"។[1]

សៀវភៅនេះរៀបរាប់ពីកម្មវិធីសិក្សាបែបសិស្សមជ្ឈមណ្ឌល និងបែបសហគមន៍មជ្ឈមណ្ឌលដែលកុមារចាប់ផ្តើមការសិក្សារបស់ខ្លួនដោយប្រើភាសានិយាយនៅផ្ទះ ហើយក៏បានរៀនភាសាផ្លូវការ (និងភាសាផ្សេងៗទៀតតាមការចាំបាច់) នៅសាលារៀនផងដែរ។ នៅក្នុងកម្មវិធីនេះ ចំណេះដឹងនិងបទពិសោធន៍ ដែលកុមារបានរៀនពីឪពុកម្តាយនិងសហគមន៍ ត្រូវបានគេគោរពនិងប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការសិក្សាតទៅមុខទៀត។ កម្មវិធីនេះដែលគេស្គាល់ថាជាកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតត្រូវបានគេធ្វើឡើងជាពិសេសសម្រាប់សហគមន៍ ដែលអ្នកសិក្សាភាគច្រើនមិនចេះនិយាយភាសាផ្លូវការរបស់សាលារៀនចំណេះទូទៅ។ គោលបំណងរបស់កម្មវិធីគឺជួយដល់អ្នកសិក្សាឲ្យបានសម្រេចគោលដៅសិក្សារបស់គេដោយមិនបង្ខំពួកគេឲ្យលះបង់ភាសាកំណើតនិងវប្បធម៌របស់គេឡើយ។

សៀវភៅនេះត្រូវបានរៀបចំឡើងជាកម្រងសំណួរ ដែលត្រូវបានសួរដោយឪពុកម្តាយ លោកគ្រូអ្នកគ្រូ អ្នកគ្រប់គ្រង និងសមាជិកសហគមន៍ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត។ ឧទាហរណ៍នៃសំណួរមួយចំនួនរួមមាន ៖ តើហេតុអ្វីបានជាត្រូវការវា? តើត្រូវធ្វើយ៉ាងដូចម្តេច? តើវាផ្តល់ប្រយោជន៍អ្វីខ្លះដល់អ្នកសិក្សា ហើយត្រូវការអ្វីខ្លះដើម្បីអនុវត្តកម្មវិធីនេះ?

1. Delpit, L.D. and Kemenfield, G. 1985. *An Evaluation of the Viles Tok Ples Skul Scheme in the North Solomons Province. ERU Report No. 51.* Waipani Papua New Guinea, University of Papua New Guinea. pp 29-30

**សំនួរនិងចម្លើយ :**

**ភាសានិងការអប់រំនៅក្នុងសហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិច**

សំណួរទី១ : តើស្ថានភាពអប់រំកុមារសហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចមានលក្ខណៈយ៉ាងដូចម្តេចដែរ?

នៅពេលកុមារចាប់ផ្តើមចូលរៀននៅសាលា គេត្រូវរៀនអ្វីៗថ្មីជាច្រើនដូចជា ៖

- រៀនអំពីចរិយាថ្លៃថ្នូរ
- រៀនអាននិងសរសេរ
- រៀនអំពីព័ត៌មាននិងទស្សនៈដែលថ្មីផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងប្រធានបទដទៃទៀត
- បង្ហាញថា គេយល់និងចេះប្រើប្រាស់ព័ត៌មាននិងទស្សនៈថ្មីៗទាំងនោះ

កុមារដែលមិនចេះនិយាយភាសាផ្លូវការរបស់សាលារៀន នៅពេលពួកគេចាប់ផ្តើមចូលរៀននៅសាលា ពួកគេនឹងប្រឈមមុខចំពោះបញ្ហាជាច្រើនដូចជា ៖

-ពួកគេត្រូវរៀនភាសាផ្លូវការរបស់សាលា ស្របពេលជាមួយគ្នានោះដែរ ពួកគេត្រូវប្រឹងប្រែងស្វែងយល់មេរៀនថ្មីៗជាច្រើនដែលគ្រូកំពុងបង្រៀនពួកគេដោយប្រើភាសាផ្លូវការនោះ។

-ពួកគេត្រូវតែខិតខំរៀនមេរៀនដែលមានក្នុងអត្ថបទដែលសរសេរជាភាសាផ្លូវការ។ បើសិនជាសិស្សមិនយល់ពីភាសាផ្លូវការបានល្អគ្រប់គ្រាន់ដើម្បីក្តាប់ឲ្យបានខ្លឹមសារមេរៀនទេនោះ ពួកគេត្រូវបង្ខំចិត្តទន្ទេញពាក្យ ឃ្លា ព្រមទាំងប្រយោគទាំងមូលដូចដែលគ្រូបានអានឲ្យស្តាប់។ ទោះជាយ៉ាងណា ការទន្ទេញមិនដូចការយល់ទេ ដូច្នេះហើយពួកគេរៀនក៏មិនទាន់សិស្សដទៃទៀតដែរ។

-ពួកគេត្រូវតែចេះសរសេរភាសាថ្មី ពោលគឺភាសាផ្លូវការ។ បើសិនជាពួកគេមិនយល់ភាសាផ្លូវការទេ ពួកគេត្រូវបង្ខំចិត្តចម្លងអក្សរ ពាក្យ ព្រមទាំងប្រយោគពីក្តារខៀនឬពីសៀវភៅ ប៉ុន្តែធ្វើបែបនេះពុំបានជួយពួកគេឲ្យរៀនសម្តែងគំនិតយោបល់ដោយការសរសេរបានទេ។

មន្ត្រីអប់រំម្នាក់នៅប្រទេសឥណ្ឌាបានពិពណ៌នាពីបញ្ហានេះនៅថ្នាក់រៀនមួយដែលគាត់បានទៅពិនិត្យ។ គាត់ថា ៖ *"កុមារហាក់ដូចជាមិនចាប់អារម្មណ៍ចំពោះការនិទានរឿងរបស់គ្រូទេ។ ពួកគេសម្លឹងមើលគ្រូភ្លឹះៗ ហើយជួនកាលសម្លឹងមើលក្តារខៀនដែលមានសរសេរអក្សរខ្លះៗ។ ដោយដឹងយ៉ាងច្បាស់ថា កុមារមិនយល់អ្វីៗដែលគ្រូកំពុងនិយាយ គ្រូបន្តពន្យល់ខ្លឹមសាររឿងដោយបន្លឺសម្លេងកាន់តែឮ។*

ក្រោយមកទៀតគ្រូផុញទ្រាន់និងការនិយាយដដែលៗហើយដឹងច្បាស់ថា កុមារស្តាប់គ្រូនិយាយមិនយល់ គ្រូបានឱ្យកុមារចម្លងអក្សរនៅលើក្តារខៀន។ គ្រូនិយាយថា កុមារចម្លងអក្សរនៅលើក្តារខៀនបានល្អ។ នៅពេលគេរៀនដល់ថ្នាក់ទី ៥ ពួកគេអាចចម្លងនិងទន្ទេញចម្លើយបានទាំងអស់។ ប៉ុន្តែមានតែសិស្សថ្នាក់ទី ៥ ចំនួន ២ នាក់ប៉ុណ្ណោះដែលចេះនិយាយភាសាផ្លូវការរបស់សាលារៀន។”[២]




គ្រូម្នាក់ក្នុងប្រទេសប៉ាពួញូហ្គីណេបានពិពណ៌នាអំពីការយល់ច្រឡំ និងការភ័យខ្លាចដែលសិស្សមាននៅពេលដែលពួកគេមិនយល់ពីភាសាផ្លូវការដែលគេប្រើនៅសាលា។ “ក្នុងម៉ោងបង្រៀនគ្រូបានឃើញថាក្មេងៗជាច្រើនហាក់ដូចជាច្រឡំ។ ពួកគេបានចាកចេញពីភូមិដែលឪពុកម្តាយរបស់គេនិយាយទៅកាន់ខ្លួនគេជាភាសានៅផ្ទះ។ ឥឡូវនេះខ្ញុំបែរជាឈរមុខក្មេងៗ និយាយភាសាដែលគេមិនចេះ។ ខ្ញុំគិតថា ខ្ញុំកំពុងតែបំភ័យពួកគេជាជាងលើកទឹកចិត្តពួកគេឱ្យរៀន....។”[៣]

ជាការពិតណាស់ក្មេងខ្លះដែលមកពីសហគមន៍ប្រើភាសាជនជាតិភាគតិច ពិតជារៀនភាសាផ្លូវការបានល្អមែន។ សិស្សខ្លះទៀតពិតជារៀនចប់ហើយបានសម្របសម្រួលខ្លួនក្នុងសង្គមដោយជោគជ័យ។ ប៉ុន្តែទំនាក់ទំនងរបស់ពួកគេជាមួយសហគមន៍នឹងទៅជាយ៉ាងណា? ជាអកុសល នៅពេលដែលភាសាផ្លូវការជាភាសាតែមួយដែលគេប្រើប្រាស់ក្នុងថ្នាក់រៀន ហើយពេលដែលខ្លឹមសារមេរៀនទាំងឡាយផ្តោតទៅលើភាសាដែលមានឥទ្ធិពលនោះ ក្មេងៗជនជាតិភាគតិចទាំងនោះអាចនឹងបំភ្លេចភាសារបស់ខ្លួន និងបាត់បង់ចំណេះដឹង សេចក្តីស្រឡាញ់ ការគោរពចំពោះវប្បធម៌ និងសហគមន៍ផ្ទាល់របស់គេ។

---

2. Jhingran, D. 2005. *Language Disadvantage. The Learning Challenge in Primary Education.* New Delhi, A. P. H. Publishing. p.1.
3. Malone, D.2004. *The in between People.* Dallas, Tex., SIL International. p.17.

ជាសង្ខេប  ជនជាតិភាគតិចដែលត្រូវចូលរៀនហើយរៀនជាភាសាដែលពួកគេមិនចេះគឺប្រឈមមុខនឹងបញ្ហាអប់រំ បញ្ហាសង្គម និងបញ្ហាផ្សេងៗទៀតដូចជា ៖

- អត្រាបោះបង់ចោលសាលានិងអត្រាត្រួតថ្នាក់ខ្ពស់ ពីព្រោះពួកគេមិនអាចរៀនជាភាសា ដែលពួកគេមិនយល់នោះទេ ។
- បាត់បង់ទំនុកចិត្តលើខ្លួនឯង ពីព្រោះពួកគេមិនអាចសម្រេចបានតាមការរំពឹងទុករបស់ឪពុកម្តាយនិងគ្រូ។
- បាត់បង់ភាសានិងសេចក្តីស្រឡាញ់ចំពោះកេរដំណែល និងសេចក្តីគោរពចំពោះសហគមន៍របស់ពួកគេ ពីព្រោះខ្លឹមសារដែលពួកគេរៀននៅសាលាធ្វើឲ្យពួកគេយល់ថា មានតែភាសា វប្បធម៌ និងសង្គមរបស់ភាសាផ្លូវការទេដែលសំខាន់។
- មិនអាចទទួលបានចំណេះដឹងនិងជំនាញផ្សេងៗដែលពួកគេត្រូវការដើម្បីរកបានការងារល្អៗធ្វើ។
- មិនអាចទទួលបានចំណេះដឹងដើម្បីចូលរួមឲ្យបានសកម្មក្នុងការអភិវឌ្ឍសហគមន៍និងប្រទេសជាតិ ដូចដែលនាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៅប្រទេសប៉ាពួញូហ្គីណេបានកត់សម្គាល់ឃើញថា ៖ *"ការអប់រំក្មេងដែលនៅក្រៅវិស័យការងារផ្លូវការ...មិនបានបំពាក់ចំណេះដឹង ជំនាញ និងអត្តចរិតឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យពួកគេចូលរួមអភិវឌ្ឍសហគមន៍និងប្រទេសជាតិរបស់ពួកគេទេ។"* [៤]



4 . Department of Education,1991. *Education Sector Review.* Waipani, Papua New Guinea, p.7.

## សំណួរទី២ : តើកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត ជួយកុមារឲ្យរៀនបានប្រសើរក្នុងសាលាយ៉ាងដូចម្តេច?

ការអប់រំល្អនៅក្នុងភាសាណាមួយក៏ដោយ ត្រូវមានគោលការណ៍សំខាន់ពីរគឺ ៖

១. ការសិក្សាជាប់ទាក់ទងទៅនឹងអត្ថន័យ : យើងអាចទន្ទេញ ប៉ុន្តែយើងមិនអាចរៀនពីអ្វីដែលយើងមិនយល់ឬមិនមានន័យចំពោះយើងឡើយ។

២. ការសិក្សាជាដំណើរការឆ្លងពីអ្វីដែលយើងដឹងទៅនឹងអ្វីដែលយើងមិនដឹង។ យើងរៀនបានល្អពេលដែលយើងប្រើអ្វីដែលយើងដឹងដើម្បីជួយឲ្យយើងយល់ហើយអាចប្រើគំនិត និងព័ត៌មានថ្មី។

កុមារតូចៗមានការសិក្សាដ៏មានអត្ថន័យខ្លះរួចទៅហើយមុនពេលដែលគេចាប់ផ្តើមចូលសាលា។ ពួកគេរៀនអំពីទំនាក់ទំនងនៅពេលដែលពួកគេប្រាស្រ័យទាក់ទងជាមួយគ្រួសារនិងអ្នកដទៃទៀតនៅក្នុងសហគមន៍។ ពួកគេរៀនអំពីធម្មជាតិនិងបរិស្ថាននៅជុំវិញខ្លួនគេ។ ពួកគេរៀនបែងចែកវត្ថុផ្សេងៗ និងប្រៀបធៀបពីទម្ងន់និងចម្ងាយនៅពេលដែលគេធ្វើសកម្មភាពប្រចាំថ្ងៃ។ ពួគគេពិចារណាលើរឿងផ្សេងៗដែលគេនិយាយនិងធ្វើតាមការយល់ដឹងរបស់ពួកគេថា អ្វីល្អ អ្វីអាក្រក់ អ្វីមានប្រយោជន៍ អ្វីដែលមានគ្រោះថ្នាក់ អ្វីសមរម្យនិងអ្វីមិនសមរម្យ។ ចំណេះដឹងនិងបទពិសោធន៍ទាំងនេះជាមូលដ្ឋានសម្រាប់ការរៀនសូត្រពេញមួយជីវិត។



ភាសាក៏ដូចគ្នានេះដែរ ក្មេងៗប្រើភាសាកំណើតរបស់ពួកគេធ្វើជាឧបករណ៍សម្រាប់ទំនាក់ទំនង និងរៀនសូត្រមុនពេលពួកគេចាប់ផ្តើមចូលសាលា ៖

- ពួកគេស្តាប់ឪពុកម្តាយនិងចាស់ព្រឹទ្ធាចារ្យ។
- ពួកគេសួរសំណួរអំពីរឿងរ៉ាវដែលខ្លួនមិនយល់ ហើយស្តាប់ការឆ្លើយតបរបស់គ្រូ។
- ពួកគេធ្វើតាមការណែនាំ។
- ពួកគេនិយាយអំពីគំនិតរបស់ពួកគេ។
- ពួកគេពណ៌នាអំពីអ្វីដែលគេដឹង ហើយពន្យល់អំពីអ្វីដែលគេគិត។
- ពួកគេអាចរាប់វត្ថុនានានិងធ្វើការគិតលេខងាយៗ។
- ពួកគេប្រកែកជាមួយមិត្តភក្តិរបស់គេ (ហើយពេលខ្លះជាមួយឪពុកម្តាយរបស់គេផងដែរ)។

តាមរយៈទំនាក់ទំនងទាំងនេះ ក្មេងៗបង្កើតភាពស្ទាត់ជំនាញនិងទំនុកចិត្តក្នុងការប្រើប្រាស់ភាសាកំណើតរបស់ខ្លួនយ៉ាងពេញលេញសម្រាប់គោលបំណងនានា។ ពួកគេនឹងមានចំណេះដឹងភាសារបស់ខ្លួនរួចជាស្រេចនៅពេលគេចាប់ផ្តើមចូលសាលារៀន។



## ការប្រើប្រាស់អ្វីដែលសិស្សស្គាល់រួចហើយ....

សាលាល្អនិងគ្រូល្អទទួលស្គាល់ថា ភាសាកំណើត ចំណេះដឹងនិងបទពិសោធន៍របស់ក្មេងៗ គឺជាធនធានដ៏មានតម្លៃសម្រាប់ការរៀនសូត្រ។ គ្រូប្រើភាសារបស់ក្មេងៗសម្រាប់ការបង្រៀនជាពិសេសនៅថ្នាក់ដំបូងដើម្បីឲ្យក្មេងៗចាប់អារម្មណ៍លើមេរៀន។ ពួកគាត់ប្រើឧទាហរណ៍ដែលសិស្សធ្លាប់ស្គាល់តាមតំបន់ក្នុងការបង្រៀនទស្សនៈថ្មីៗ ដូច្នេះក្មេងៗអាចប្រើចំណេះដឹងនិងបទពិសោធន៍ដើម្បីឲ្យខ្លួនងាយយល់ពីទស្សនៈថ្មីៗទាំងអស់នោះ។ ពួកគាត់ត្រូវផ្តល់សម្ភារៈអានជាភាសារបស់ក្មេងៗដែលស្តីអំពីមនុស្ស ទីកន្លែងនិងសកម្មភាពដែលសិស្សស្គាល់ ដើម្បីឲ្យក្មេងៗយល់ថា ការអានគឺមានអត្ថន័យនិងគួរឲ្យចាប់អារម្មណ៍។ ពួកគាត់លើកទឹកចិត្តក្មេងៗឲ្យសរសេរដោយមានគំនិតច្នៃប្រឌិតជាភាសាផ្ទាល់របស់ខ្លួនអំពីអ្វីដែលខ្លួនស្គាល់ និងគិតពីអ្វីដែលជួយពង្រឹងទំនុកចិត្ត និងសមត្ថភាពក្នុងការបញ្ចេញទស្សនៈនិងគំនិតក្នុងទម្រង់សរសេរ។ សកម្មភាពទាំងអស់នេះជួយក្មេងៗឲ្យសាងគ្រឹះអប់រំរឹងមាំ ដែលនាំពួកគេទៅរកការសិក្សាពេញមួយជីវិតប្រកបដោយជោគជ័យ។

ខាងក្រោមនេះគឺជាសម្តីរបស់អ្នកស្រាវជ្រាវផ្នែកអប់រំម្នាក់ស្តីអំពីគុណប្រយោជន៍នៃការកសាងគ្រឹះភាសាកំណើតដ៏រឹងមាំ ៖ *"កម្រិតនៃការអភិវឌ្ឍន៍ភាសាកំណើតរបស់ក្មេងៗ គឺជាការទស្សទាយដ៏ល្អមួយអំពីការអភិវឌ្ឍន៍ភាសាទីពីរ....កុមារដែលមានមូលដ្ឋានគ្រឹះរឹងមាំក្នុងភាសាកំណើតអាចបង្កើនសមត្ថភាពអាននិងសរសេរភាសាប្រើនៅសាលាបានកាន់តែល្អ។"* [៥]

នេះបញ្ជាក់ថា ការចាប់ផ្តើមរៀនដោយប្រើជាភាសាកំណើតគឺមិនខ្ជះខ្ជាយពេលវេលាទេ។ វាមិនប៉ះពាល់ដល់សមត្ថភាពសិស្សក្នុងការរៀនភាសាថ្មីទេ។ ផ្ទុយទៅវិញ វាគឺជាធនធានសំខាន់បំផុតសម្រាប់រៀនភាសាថ្មី។

## *ការប្រើប្រាស់អ្វីដែលសិស្សស្គាល់រួចហើយដើម្បីរៀនអ្វីដែលថ្មី*

នៅពេលដែលក្មេងៗបង្កើនភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ភាសាកំណើតរបស់ខ្លួនក្នុងថ្នាក់រៀន ពួកគេចាប់ផ្តើមរៀនភាសាសាលាជាផ្លូវការផងដែរ ជាដំបូងរៀនស្តាប់និងនិយាយ បន្ទាប់មករៀនអាននិងសរសេរ។ ដំណើរការនេះគឺស្របតាមគោលការណ៍អប់រំមួយគឺ" សិស្សរៀនអាននិងរៀនសរសេរក្នុងពេលតែមួយ"។ នៅពេលក្មេងៗបានរៀនអាននិងសរសេរជាភាសាកំណើតរបស់ពួកគេរួចហើយ ពួកគេបានចាប់ផ្តើមបង្កើនភាពស្ទាត់ជំនាញក្នុងការស្តាប់ និងការនិយាយភាសាផ្លូវការ។ ក្នុងសាលា ពួកគេអាចរៀនអាន និងសរសេរភាសាផ្លូវការបានយ៉ាងងាយស្រួលនិងពោរពេញដោយទំនុកចិត្ត។

នៅក្នុងកម្មវិធីអប់រំពហុភាសាដែលល្អ ក្មេងៗបន្តប្រើភាសាទាំងពីរក្នុងការស្តាប់និងការនិយាយ ការអាននិងការសរសេរ (សម្រាប់ទំនាក់ទំនង និងសម្រាប់ការសិក្សា) យ៉ាងហោចណាស់រហូតដល់ពួកគេរៀនចប់សាលាបឋមសិក្សា។

*"នៅពេលកុមារបន្តអភិវឌ្ឍសមត្ថភាពរបស់ខ្លួនដោយប្រើភាសាពីរ (ឬច្រើនជាងនេះ) ក្នុងឆ្នាំដែលខ្លួនរៀននៅបឋមសិក្សានោះ ពួកគេទទួលបានការយល់ដឹងអំពីភាសាកាន់តែជ្រាលជ្រៅថែមទៀត និងដឹងពីរបៀបប្រើប្រាស់វាឲ្យមានប្រសិទ្ធភាព។ ពួកគេមានការហ្វឹកហាត់កាន់តែច្រើនក្នុងការប្រើប្រាស់ភាសាជាពិសេសគឺនៅពេលដែលខ្លួនអភិវឌ្ឍចំណេះអក្ខរកម្មទាំងពីរភាសាហើយអាចធ្វើការប្រៀបធៀបនិងរកចំណុចខុសគ្នានៃភាសាទាំងពីរ។"*[៦]

---

5 Cummins, J. 2000. Blingual Children's Mother Tongue: Why is it important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed on 17 November 2006)

6 Cummins, J. 2000. Blingual Children's Mother Tongue: Why is it important for Education? http://www.iteachilearn.com/cummins/mother.htm (Accessed on 17 November 2006)

*សំណួរទី៣: តើមាតាបិតាសិស្សនិងគ្រូមានទស្សនៈយ៉ាងណាចំពោះការប្រើប្រាស់ភាសាកំណើតក្នុងថ្នាក់រៀន?*

កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតត្រូវបានបង្កើតឡើងក្នុងសហគមន៍ជនជាតិភាគតិច នៅតាមតំបន់ជាច្រើនជុំវិញពិភពលោក។ គ្រូ នាយកសាលា និងមាតាបិតាសិស្សនៅក្នុងកម្មវិធីនេះបាន ស្វែងយល់ថា សិស្សដែលចាប់ផ្តើមរៀនជាភាសាកំណើតរបស់ពួកគេគឺ :

- មានទំនុកចិត្តលើខ្លួនគេផ្ទាល់។
- ចូលរួមពិភាក្សាក្នុងថ្នាក់យ៉ាងសកម្ម។
- សួរសំណួរច្រើន។
- បង្ហាញនូវការយល់ដឹងយ៉ាងច្បាស់លាស់អំពីមុខវិជ្ជានីមួយៗ។
- រៀនអានដោយងាយស្រួល និងយល់អំពីអ្វីដែលពួកគេបានអាន។
- រៀនសរសេរដោយងាយស្រួល និងបញ្ចេញទស្សនៈពួកគេក្នុងទម្រង់សរសេរបានល្អប្រសើរ
- រៀនភាសាសាលាដោយផ្ទាល់មាត់ ដោយសរសេរបានយ៉ាងងាយស្រួល និងមានការយល់ដឹង ដ៏ជ្រាលជ្រៅ។

មន្ត្រីអប់រំស្រុកមួយរូបបានពណ៌នាពីភាពខុសគ្នាដែលគាត់បានសង្កេតឃើញពេលគាត់ទៅពិនិត្យថ្នាក់ រៀនមួយថា ៖



*ពីមុនក្មេងៗគ្រាន់តែអង្គុយក្នុងថ្នាក់ ពួកគេមិននិយាយអ្វីទាំងអស់។ ពួកគេថែមទាំងមិនដឹងអំពីរបៀបឆ្លើយសំណួរគ្រូ។ ឥឡូវពួកគេតែងតែលើកដៃឆ្លើយជានិច្ច។ ពួកគេមានមតិជាច្រើនដើម្បីនិយាយ។ ពួកគេក្លាយជាក្រុមក្មេងសកម្មនិងមានចំណាប់អារម្មណ៍ក្នុងការសិក្សា។"*[៧]

មាតាបិតាក៏រីករាយផងដែរ ពីព្រោះកម្មវិធីអប់រំពហុភាសាបានពង្រឹងសេចក្ដីស្រឡាញ់របស់ក្មេងៗ សេចក្ដីគោរពចំពោះវប្បធម៌ និងភាសាកេរដំណែលរបស់ពួកគេ។ ឪពុកសិស្សម្នាក់បាននិយាយថា ៖

*"ឥឡូវនេះកូនរបស់ខ្ញុំកំពុងនៅក្នុងសាលា ប៉ុន្តែវាមិនមានអារម្មណ៍ថា វានៅក្រៅសហគមន៍ទេ។ វាកំពុងរៀននៅឯសាលាអំពីទំនៀមទម្លាប់និងរបៀបរស់នៅរបស់វា។ បច្ចុប្បន្ននេះវាអាចសរសេរអ្វីដែលវាចង់សរសេរទាំងអ្វីដែលវាមើលឃើញនិងអ្វីៗដែលវាអាចគិតដល់។ វាសរសេរអំពីរឿងជួយរែកទឹកម្ដាយ រឿងធ្វើស្រែ និងរឿងទៅថែទាំដំណាំ។*

*នៅពេលដែលវាសរសេរអំពីរឿងទាំងនេះ រឿងដែលវាសរសេរក៏ក្លាយទៅជារបស់យ៉ាងសំខាន់ចំពោះរូបវា។ វាមិនត្រឹមតែអាននិងសរសេរអំពីរឿងរ៉ាវនៅខាងក្រៅប៉ុណ្ណោះទេ គឺថែមទាំងរៀនសូត្រតាមរយៈការអាននិងសរសេរដើម្បីសម្ដែងមោទនភាពចំពោះរបៀបរស់នៅរបស់យើងទៀតផង។ នៅពេលវាធំឡើង វានឹងមិនបោះបង់យើងចោលឡើយ។ ការបង្រៀនកូនចៅរបស់យើងឲ្យចេះអាននិងសរសេរគឺមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែវារឹតតែសំខាន់ទៅទៀតក្នុងការបង្រៀនពួកគេឲ្យមានមោទនភាពចំពោះខ្លួនឯងនិងចំពោះពួកយើងផង។"*[៨]

7 Personal communication from a teacher in the Regional Lingua Franca Programme in the Philippines to Susan Malone, SIL International, in 2001.

8 Delpit, L. D. and Kemelfield, G. 1985. An Evaluation of Viles Tok Ples Skul Scheme in the North Solomons province. ERU Report $N_0$. 51. Waigani, Papua New Guinea, University of Papua New Guinea.

### សំណួរទី៤ : តើយើងត្រូវធ្វើអ្វីខ្លះដើម្បីបង្កើតកម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតនៅក្នុងសហគមន៍យើង?

កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើតដែលទទួលបានជោគជ័យ ត្រូវការកិច្ចសហប្រតិបត្តិការ និង ការគាំទ្រពីមនុស្សជាច្រើន។ សំខាន់បំផុតគឺសមាជិកសហគមន៍មានតម្រូវការកម្មវិធី និងត្រៀមខ្លួនរួចជាស្រេចក្នុងការក្លាយខ្លួនជាម្ចាស់កម្មវិធី។ ការគាំទ្រពីនាយកសាលា គ្រូបង្រៀន និងមន្ត្រីអប់រំផ្សេងទៀតគឺជាការចំបាច់ដើម្បីឲ្យកម្មវិធីរីកចម្រើននិងគង់វង្ស។

ផ្នែកខាងក្រោមនេះ ផ្តល់នូវគំនិតខ្លះៗសម្រាប់សហគមន៍ដែលចង់ចាប់ផ្តើមអនុវត្តកម្មវិធីអប់រំពហុភាសាឲ្យបានល្អ។[៩] សកម្មភាពមួយចំនួនដែលបានពណ៌នាខាងក្រោមត្រូវបន្តធ្វើរហូតដល់ចប់កម្មវិធី ចំណែកឯសកម្មភាពខ្លះទៀតត្រូវធ្វើក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ នៅឯកន្លែងខ្លះសកម្មភាពមួយចំនួនប្រហែលជាត្រូវបានគេធ្វើរួចហើយ (ឧទាហរណ៍ ភាសាមួយប្រហែលជាមានប្រព័ន្ធសំណេរមួយរួចស្រេច)។ ដោយឡែកនៅកន្លែងផ្សេងទៀតដែលមិនទាន់មានសកម្មភាពនៅឡើយ សហគមន៍ត្រូវចាប់ផ្តើមសកម្មភាពជាមួយដៃគូរបស់ខ្លួនតាំងពីដំបូង។




**១_ត្រូវបង្កើតបរិយាកាសនយោបាយគាំទ្រមួយ :** អ្នកបង្កើតគោលនយោបាយនិងអាជ្ញាធរត្រូវតែប្រមូលធនធានដើម្បីទាក់ទាញការគាំទ្រខាងនយោបាយនិងថវិកាសម្រាប់កម្មវិធីអប់រំពហុភាសាផ្អែកលើភាសាកំណើត។ មុនធ្វើរឿងនោះ ពួកគេត្រូវការយល់អំពីគោលបំណងនិងអត្ថប្រយោជន៍នៃកម្មវិធី។ សហគមន៍ប្រើ_ប្រាស់ភាសា និងបណ្តាញគាំទ្ររបស់ខ្លួនជាជំហានដំបូងត្រូវបង្កើតបរិយាកាសនយោបាយគាំទ្រដោយចាប់ផ្តើមពីកម្មវិធីខ្នាតតូចនៅក្រៅប្រព័ន្ធអប់រំចំណេះទូទៅដូចជា ថ្នាក់មត្តេយ្យនិងថ្នាក់ក្រៅម៉ោងសាលារដ្ឋជាដើម។

9 Malone, S. 2004. Planning community-based education programmes in minority language communities. Resource manual for mother tongue speakers of minority languages. Unpublished manual.

ពួកគេអាចធ្វើដូចនេះដោយមិនបាច់រង់ចាំឲ្យគោលនយោបាយផ្លូវការចូលជាធរមានឡើយ។ ជោគ-ជ័យនៃកម្មវិធីទាំងនេះនឹងបញ្ជាក់ឲ្យឃើញពីតម្លៃរបស់កម្មវិធី និងលើកទឹកចិត្តឲ្យមានការគាំទ្រផ្នែកនយោបាយកាន់តែខ្លាំងឡើង។

ទោះបីសមាជិកសហគមន៍ជនជាតិភាគតិចមិនមានតំណាងនៅរដ្ឋាភិបាលថ្នាក់ខ្ពស់ មិនមានសម្លេងក្នុងការកសាងគោលនយោបាយក៏ដោយ ក៏ពួកគេអាចបង្កើតការទំនាក់ទំនង និងសហប្រតិបត្តិការជាមួយក្រុមភាសាដទៃទៀត ថ្នាក់ងាររដ្ឋាភិបាល និងជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា។ ការធ្វើការងាររួមគ្នានេះនឹងធ្វើឲ្យពួកគេមានសម្លេងនិងឥទ្ធិពលច្រើនជាងពេលដែលពួកគេធ្វើការដោយឡែកៗពីគ្នា។



**២_ការប្រមូលព័ត៌មានដើម្បីធ្វើផែនការ :** កម្មវិធីអប់រំពហុភាសាដែលល្អឆ្លើយតបទៅនឹងតម្រូវការនិងគោលបំណងរបស់ប្រជាជនសហគមន៍ ជាពិសេសអ្នកសិក្សានិងគ្រួសាររបស់ពួកគេ។ អាទិភាពសម្រាប់អ្នកធ្វើផែនការ គឺរៀនសូត្រពីក្រុមគ្រួសារនិងពីប្រជាជនដទៃទៀតក្នុងសហគមន៍អំពីស្ថានភាពអប់រំដោយឲ្យពួកគេពណ៌នាអំពីគោលបំណងសិក្សាសម្រាប់កូនៗរបស់ពួកគេ និងបញ្ជាក់អំពីភាពខ្លាំងនិងភាពខ្សោយនៃប្រព័ន្ធអប់រំបច្ចុប្បន្ន។ អ្នកធ្វើផែនការដែលប្រកបដោយភាពវាងវៃត្រូវប្រមូលព័ត៌មានអំពីធនធានផ្សេងៗក្នុងសហគមន៍ដែលអាចប្រើបានសម្រាប់កម្មវិធីអប់រំពហុភាសានេះ (ឧទាហរណ៍ មានអគារសមរម្យ ធនធាន-មនុស្ស ឯកសារ...) ដំណើរការនៃការប្រមូលព័ត៌មានផ្តល់ឲ្យអ្នកដឹកនាំកម្មវិធីនូវឱកាសដ៏ល្អបំផុតដើម្បីលើកកម្ពស់ការយល់ដឹងអំពីកម្មវិធី (មើលសកម្មភាពបន្ទាប់)។ ការស្រាវជ្រាវក៏ដូចជាការលើកកម្ពស់ការយល់ដឹងនិងការប្រមូលធនធានគួរតែបន្តធ្វើ នៅពេលដែលកម្មវិធីពង្រីកទៅសហគមន៍ផ្សេងទៀត។

**៣_ការលើកកម្ពស់ការយល់ដឹងនិងការប្រមូលផ្តុំដៃគូ:** គ្រួសារជាច្រើនគិតថា ដើម្បីឲ្យកូនៗរបស់ពួកគេមានភាពស្ទាត់ជំនាញក្នុងភាសាផ្លូវការ កូនៗរបស់ខ្លួនត្រូវការរៀនភាសាថ្មីឲ្យបានឆាប់តាមដែលអាចធ្វើបាន និងប្រើវាឲ្យបានច្រើនឲ្យអស់លទ្ធភាព។ ពួកគេភ័យខ្លាចថា ពេលដែលកូនរបស់ខ្លួនចំណាយពេលច្រើនក្នុងការប្រើប្រាស់ភាសាកំណើតនៅសាលា ពួកគេនឹងមានឱកាសតិចតួចដើម្បីរៀនភាសាផ្លូវការ។ ប៉ុន្តែការស្រាវជ្រាវផ្នែកអប់រំបានបង្ហាញថា វាមិនដូច្នេះទេ។ ការកសាងគ្រឹះអប់រំដែលល្អមួយជាភាសាទីមួយពិតជាអាចជួយក្មេងៗឲ្យរៀនភាសាទីពីរយ៉ាងងាយស្រួល។

មាតាបិតាសិស្សត្រូវយល់ដឹងអំពីផលប្រយោជន៍នៃការប្រើប្រាស់ភាសាទីមួយរបស់ក្មេងៗក្នុងសាលា ដូច្នេះគេនឹងមានទំនុកចិត្តក្នុងការចុះឈ្មោះកូនរបស់ពួកគេក្នុងកម្មវិធីអប់រំពហុភាសានេះ។ សមាជិកសហគមន៍ដទៃទៀតត្រូវការព័ត៌មាន និងការលើកទឹកចិត្ត ដូច្នេះពួកគេនឹងទទួលយកតួនាទីសកម្មក្នុងការគាំទ្រកម្មវិធី (ឧទាហរណ៍ ថែរក្សាថ្នាក់រៀន ជួយបង្រៀនសិស្ស កសាងសម្ភារៈអាន)។ ការគាំទ្រពីមន្ត្រីអប់រំស្រុកឬតាមមូលដ្ឋានគឺជាការចាំបាច់ផងដែរដើម្បីឲ្យកម្មវិធីទទួលបានជោគជ័យនិងមាននិរន្តរភាព។ ការលើកកម្ពស់ការយល់ដឹង និងសកម្មភាពប្រមូលធនធានផ្តល់ឲ្យមាតាបិតាសិស្សនិងដៃគូដែលពាក់ព័ន្ធនៅក្នុងនិងនៅក្រៅសហគមន៍នូវព័ត៌មានអំពីកម្មវិធី និងលើកទឹកចិត្តពួកគេឲ្យចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនការអនុវត្តនិងការរក្សានិរន្តរភាពកម្មវិធី។

**៤_បង្កើតប្រព័ន្ធសំណេរ :** ប្រសិនបើភាសាតាមតំបន់មិនមានអក្សរសរសេរនៅឡើយ សហគមន៍ត្រូវតែជ្រើសរើសនិមិត្តសញ្ញាឬអក្សរសម្រាប់ប្រព័ន្ធសំណេររបស់ខ្លួន។ អ្នកភាសាសាស្ត្រដែលធ្លាប់ស្គាល់ភាសាតាមតំបន់អាចជួយអ្នកនិយាយភាសាកំណើតក្នុងតំបន់នោះឲ្យធ្វើការសម្រេចចិត្តបង្កើតសញ្ញាឬអក្សរដើម្បីប្រើ។ ខណៈពេលដែលសហគមន៍បានបង្កើតប្រព័ន្ធសំណេរសាកល្បងរួចហើយ ពួកគេត្រូវធ្វើតេស្តទៅលើជម្រើសរបស់ពួកគេនិងធ្វើការកែលំអរតាមការចាំបាច់។

ការអភិវឌ្ឍន៍ប្រព័ន្ធសំណេរសម្រាប់ភាសាដែលមិនមានអក្សរពីមុនមក អាចជាការងារមួយលំបាក ប៉ុន្តែសហគមន៍ប្រើប្រាស់ភាសាជនជាតិភាគតិចជាច្រើននៅអតីតកាលបានធ្វើប្រព័ន្ធសំណេរដោយជោគជ័យគួរឲ្យកត់សម្គាល់។ នៅពេលដែលប្រព័ន្ធសំណេរត្រូវបានបង្កើតឡើង សហគមន៍អាចចាប់ផ្តើមបង្កើតអក្សរសាស្ត្រសំណេរនិងរៀបចំឯកសារនានាសម្រាប់កម្មវិធីអប់រំពហុភាសា ។



**៥_បង្កើតសម្ភារៈរៀននិងបង្រៀន :** សម្ភារៈរៀននិងបង្រៀនសម្រាប់កម្មវិធីអប់រំពហុភាសាគួរតែ ៖
១)_ផ្តល់ឲ្យអ្នកសិក្សានូវចំណេះដឹង ជំនាញនិងទំនុកចិត្តដើម្បីសម្រេចបានតាមគោលបំណងអប់រំរបស់ពួកគេ។
២)_បន្តពង្រឹងសេចក្តីស្រឡាញ់ និងសេចក្តីគោរពចំពោះវប្បធម៌ និងភាសាកេរដំណែលរបស់ពួកគេ។

មន្ត្រីអប់រំថ្នាក់ស្រុកឬថ្នាក់ខេត្តរួមទាំងគ្រូៗនិងនាយកសាលា ធ្វើការរួមគ្នាដើម្បីបង្កើតសម្ភារៈរៀន និងបង្រៀនសម្រាប់ការអប់រំនៅក្នុងកម្មវិធីអប់រំពហុភាសា។ ពួកគេត្រូវដឹងពីការរំពឹងទុករបស់សិស្សនៅកម្រិតនីមួយៗនៃសាលាបឋមសិក្សា ហើយអាចកំណត់សមត្ថភាពសំខាន់ៗដែលក្មេងៗត្រូវមាន នៅពេលពួកគេចូលទៅក្នុងប្រព័ន្ធអប់រំផ្លូវការ។ តួនាទីរបស់សហគមន៍គឺធានាថា សម្ភារៈបង្រៀននិងរៀនត្រូវផ្តោតការចាប់_អារម្មណ៍លើមូលដ្ឋានភាសា ចំណេះដឹង និងបទពិសោធន៍ដែលក្មេងៗមានរួចមកហើយ នៅពេលដែលគេចាប់ផ្តើមកម្មវិធី។ សមាជិកសហគមន៍ត្រូវជួយធ្វើឲ្យប្រាកដជាងដែរថា កម្មវិធីនឹងថែរក្សាវប្បធម៌និងភាសាកេរដំណែលរបស់សហគមន៍គេផ្ទាល់។

**៦_បង្កើតសម្ភារៈអានជាភាសាជនជាតិភាគតិច :** ក្មេងៗនៅក្នុងកម្មវិធីអប់រំពហុភាសាត្រូវការសម្ភារៈអានច្រើនជាភាសារបស់ពួកគេផ្ទាល់ ហើយបន្ទាប់មកជាភាសាថ្មី *(ភាសាផ្លូវការ)*។ សម្ភារៈអានដំបូងគួរជាភាសាកំណើតរបស់ក្មេងៗ ដែលត្រូវបានសរសេរដោយអ្នកនិយាយភាសាកំណើតអំពីមនុស្ស ទីកន្លែង និងសកម្មភាពនានាដែលសិស្សធ្លាប់ស្គាល់។ ពេលក្មេងៗចាប់ផ្តើមអានជាភាសាថ្មី *(ភាសាផ្លូវការ)* ពួកគេត្រូវការសម្ភារៈអានជាភាសានោះដោយដំបូងចាប់អានពីអត្ថបទខ្លីងាយៗទៅអត្ថបទវែងហើយកាន់តែស្មុគស្មាញ។

បទពិសោធន៍ក្នុងសហគមន៍ភាសាទូទាំងទ្វីបអាស៊ី_ប៉ាស៊ីហ្វិកបានបង្ហាញថា អ្នកនិយាយភាសាកំណើតស្ទាត់ជំនាញអាចផលិតសម្ភារៈអានបានយ៉ាងច្រើនជាភាសារបស់ពួកគេ។ នេះជាឧទាហរណ៍ខ្លះនៃប្រភេទសម្ភារៈអានដែលពួកគេបានកសាងឡើង :

| | | |
|---|---|---|
| _រឿងផ្សេងៗ | _ការបង្រៀន និងការណែនាំ | _ការផ្សព្វផ្សាយ |
| _ចម្រៀង និងកំណាព្យ | _ការបង្រៀនសីលធម៌ និងសាសនា | _ប្រតិទិន |
| _ជីវប្រវត្តិ និងប្រវត្តិសាស្រ្តនានា | _រឿងល្ខោន និងចាកកំប្លែង | _សៀវភៅផែនការ |
| _រឿងនិទាន និងរឿងព្រេង | _សៀវភៅព្យញ្ជនៈ | _សំបុត្រនានា |
| _រឿងកំប្លែង ពាក្យបណ្តៅ | _វចនានុក្រមងាយៗ | _ស្លាកសញ្ញា |
| _សៀវភៅស្តីពីសកម្មភាព | _ក្រដាសព័ត៌មាននិងប័ណ្ណព័ត៌មាន | _ការធ្វើដំណើរ និង |
| _ល្បែងនានា | | _ពត៌មានភូមិសាស្រ្ត |
| | | _ព័ត៌មានសុខភាព |
| | | និងព័ត៌មានដទៃទៀត |



បទពិសោធន៍ក្នុងសហគមន៍ជាច្រើនបានបង្ហាញផងដែរថា គេមិនត្រូវការឯកសារអានដែលថ្លៃ និងមានពណ៌ ចើតចាយនោះទេ ជាពិសេសសម្រាប់អ្នកទើបចេះអានតិចៗ។ ក្នុងករណីជាច្រើន ឯកសារអានដែលកសាងឡើងដោយមានរបៀបរៀបរយ និងមានរូបភាពស-ខ្មៅ គឺអាចទទួលយកបាន (បើសិនជាធនធានមានកម្រិត) ជាពិសេសនៅពេលខ្លឹមសារមានការចាប់អារម្មណ៍ចំពោះអ្នកអាននិងសមស្របតាមសមត្ថភាពរបស់សិស្ស។

ចំណុចសំខាន់បំផុតដែលគួរចងចាំក្នុងការកសាងសម្ភារៈអានសម្រាប់អ្នកទើបចេះអានគឺ :

១)_ខ្លឹមសារគួរជាទីចាប់អារម្មណ៍របស់ពួកគេ។

២)_ភាសាគួរតែច្បាស់ និងងាយយល់។

៣)_មានរូបភាពដែលជួយឲ្យងាយយល់អត្ថបទ។

**៧_ជ្រើសរើសនិងបណ្តុះបណ្តាលប្រជាជនដើម្បីធ្វើការក្នុងកម្មវិធី :** តារាងនៅទំព័របន្ទាប់គឺជាបញ្ជីរាយឈ្មោះបុគ្គលិកព្រមទាំងភារកិច្ចនិងលក្ខណៈសម្បត្តិដែលត្រូវការសម្រាប់កម្មវិធីអប់រំពហុភាសា។

ទោះបីគ្រូបង្រៀននិងបុគ្គលផ្សេងៗទៀតដែលជាអ្នកស្ម័គ្រចិត្តឬដែលជាអ្នកទទួលប្រាក់ខែក៏ដោយក៏ពួកគេត្រូវការការលើកទឹកចិត្តនិងការគាំទ្រពីសហគមន៍ទាំងមូលរួមទាំងមាតាបិតាសិស្សផង។ សកម្មភាពដំបូងដែលសំខាន់គឺបង្កើតគណៈកម្មការមួយសម្រាប់ដឹកនាំតាមតំបន់ ដែលនឹងជួយជ្រើសរើសបុគ្គលិកនិងតាមមើលថា តើសមាជិកគណៈកម្មការទទួលបានការគាំទ្រដែលពួកគេត្រូវការដើម្បីបំពេញការងារឲ្យបានល្អឬទេ។

| បុគ្គលិក | ភារកិច្ច | លក្ខណៈសម្បត្តិទូទៅ |
|---|---|---|
| គ្រូបង្រៀនប្រហែលត្រូវការពីរនាក់(ម្នាក់សម្រាប់ភាសាតាមតំបន់ ហើយម្នាក់ទៀតសម្រាប់ភាសាផ្លូវការ) | -បង្រៀនសិស្សដោយប្រើភាសាផ្លូវការ និងភាសាតាមតំបន់<br>-វាយតម្លៃពីភាពរីកចម្រើនរបស់សិស្ស<br>-រក្សាបញ្ជីវត្តមានសិស្ស<br>-ទំនាក់ទំនងជាមួយមាតាបិតាសិស្ស និងសមាជិកសហគមន៍ដទៃទៀត។ | -សមត្ថភាពនិយាយ អាន និងសរសេរភាសាទាំងពីរ<br>-យល់និងឲ្យតម្លៃវប្បធម៌តាមតំបន់<br>-មានអក្សរសរសេរដែលច្បាស់និងងាយអាន<br>-ត្រូវបានជ្រើសរើសនិងយល់ព្រមពីសហគមន៍ |
| អ្នកនិពន្ធ វិចិត្រករ អ្នកផ្ទៀងផ្ទាត់ កែសម្រួល និង អ្នកវាយតម្លៃ | -អ្នកនិពន្ធ : សរសេរ កែសម្រួល បកប្រែសម្ភារៈអានជាភាសាកំណើត និងភាសាផ្លូវការ<br>-វិចិត្រករ : គូររូបភាពនៅក្នុងសៀវភៅអាន<br>-អ្នកផ្ទៀងផ្ទាត់កែសម្រួល (និងអ្នកនិពន្ធ) : ពិនិត្យសម្ភារៈអានទៅលើអត្ថន័យភាសា ការប្រើវណ្ណយុត្តិ និង អក្ខរាវិរុទ្ធ<br>-ក្រុមវាយតម្លៃ : ត្រួតពិនិត្យសម្ភារៈអាន និងកែសម្រួលបន្ថែមក្នុងករណីចាំបាច់។ | -សមត្ថភាពនិយាយ អាន និងសរសេរភាសាកំណើត និងភាសាផ្លូវការ<br>-មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ និងវប្បធម៌របស់ក្រុមប្រើប្រាស់ភាសាជនជាតិភាគតិច<br>-អាចទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល នាយកសាលា និងអ្នកដឹកនាំអង្គការមិនមែនរដ្ឋាភិបាល<br>-មានគំនិតច្នៃប្រឌិតនិងវិធីសាស្ត្របង្រៀនល្អ (គ្រូឧទ្ទេស)<br>-មានបទពិសោធន៍ក្នុងការបង្រៀនភាសាកំណើត (គ្រូឧទ្ទេស និងអ្នកត្រួតពិនិត្យ)<br>-ត្រូវបានជ្រើសរើសនិងយល់ព្រមពីសហគមន៍ |

| បុគ្គលិក | ការទទួលខុសត្រូវសំខាន់ៗ | លក្ខណៈសម្បត្តិទូទៅ |
|---|---|---|
| អ្នកត្រួតពិនិត្យនិងគ្រូឧទ្ទេស | -ត្រួតពិនិត្យថ្នាក់រៀនឲ្យបានទៀងទាត់ រកឲ្យឃើញភាពខ្លាំង និងភាពខ្សោយរបស់គ្រូ ជួយគ្រូពេលដែលពួកគេមានបញ្ហា<br>-វាយតម្លៃភាពរីកចម្រើនរបស់សិស្ស<br>-ធ្វើឲ្យប្រាកដថា របាយការណ៍ត្រូវបានទុកដាក់ត្រឹមត្រូវ<br>-ដឹកនាំការបណ្តុះបណ្តាលគ្រូ<br>-ធ្វើឲ្យប្រាកដថា មានសម្ភារៈរៀនគ្រប់គ្រាន់<br>-សាកសួរមតិយោបល់ពីសហគមន៍អំពីការគ្រប់គ្រងនិងវាយតម្លៃកម្មវិធី | -សមត្ថភាពនិយាយ អាន និងសរសេរភាសាកំណើត និងភាសាផ្លូវការ<br>-មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ និងវប្បធម៌របស់ក្រុមប្រើប្រាស់ភាសាជនជាតិភាគតិច<br>-អាចទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល នាយកសាលា និងអ្នកដឹកនាំអង្គការមិនមែនរដ្ឋាភិបាល<br>-មានគំនិតច្នៃប្រឌិតនិងវិធីសាស្ត្របង្រៀនល្អ (គ្រូឧទ្ទេស)<br>-មានបទពិសោធន៍ក្នុងការបង្រៀនភាសាកំណើត (គ្រូឧទ្ទេស និងអ្នកត្រួតពិនិត្យ)<br>-ត្រូវបានជ្រើសរើសនិងយល់ព្រមពីសហគមន៍ |
| គណៈកម្មការប្រឹក្សាយោបល់ | -ជាទីប្រឹក្សារបស់អ្នកដឹកនាំកម្មវិធី<br>-ជួយរៀបចំការជ្រើសរើសបុគ្គលិក<br>-ពង្រឹងទំនាក់ទំនងរវាងបុគ្គលិកនិងសហគមន៍<br>-និយាយពីគោលបំណង កម្មវត្ថុនិងសកម្មភាពរបស់កម្មវិធីប្រាប់ទៅដល់សហគមន៍<br>-លើកទឹកចិត្តសហគមន៍ដើម្បីជួយថែរក្សាថ្នាក់រៀននិងសម្ភារៈថ្នាក់រៀន<br>-ប្រសិនបើមានលទ្ធភាពត្រូវស្វែងរកថវិកាដើម្បីជួយគាំទ្រកម្មវិធី<br>-ធានាឲ្យមានការទទួលខុសត្រូវក្នុងការប្រើប្រាស់ថវិកា និងធនធានដទៃទៀត | -យល់ពីផលប្រយោជន៍និងគោលបំណងរបស់កម្មវិធី<br>-មានការតាំងចិត្តអនុវត្តកម្មវិធីនិងស្ម័គ្រចិត្តធ្វើការជាមួយគ្នាដើម្បីភាពជោគជ័យរបស់កម្មវិធី<br>-ត្រូវបានជ្រើសរើសនិងយល់ព្រមពីសហគមន៍ |

**៨_ការវាយតម្លៃនិងចងក្រងជាឯកសារពីការរីកចម្រើន :** បើសិនកម្មវិធីអប់រំពហុភាសាត្រូវបានបង្កើតក្នុងប្រព័ន្ធអប់រំចំណោះទូទៅ មន្ត្រីអប់រំនានាត្រូវទទួលខុសត្រូវក្នុងការវាយតម្លៃពីការរីកចម្រើននៃសមត្ថភាពរបស់សិស្ស។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃកម្មវិធីអប់រំពហុភាសាគួរពិចារណាទៅលើសេចក្តីពេញចិត្តរបស់សមាជិកសហគមន៍ចំពោះកម្មវិធីក្នុងការឆ្លើយតបទៅនឹងគោលបំណងអប់រំ និងគោលបំណងវប្បធម៌របស់ពួកគេ។ នៅពេលដែលសមាជិកសហគមន៍តាមមូលដ្ឋានចូលរួមក្នុងការចងក្រងឯកសារនិងការវាយតម្លៃកម្មវិធី របាយការណ៍ទាំងនោះនឹងឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃរបស់កម្មវិធីចំពោះសហគមន៍របស់គេផ្ទាល់។

**៩_ការគាំទ្រពីភ្នាក់ងារខាងក្រៅនិងអង្គការនានា :** កម្មវិធីអប់រំពហុភាសាដែលទទួលបានជោគជ័យតម្រូវឱ្យមានកិច្ចសហការ គាំទ្រ និងមានការផ្តល់ថវិកាពីខាងក្នុងនិងខាងក្រៅសហគមន៍។ មានតែអ្នកនិយាយភាសាកំណើតទេដែលអាចកសាងសម្ភារៈអាន បង្រៀនសិស្ស និងវិនិច្ឆ័យលទ្ធផលជោគជ័យរបស់កម្មវិធី ដែលឆ្លើយតបទៅនឹងគោលបំណងរបស់សហគមន៍។ អ្នកនៅខាងក្រៅសហគមន៍អាចជួយក្នុងសកម្មភាពដទៃទៀតរបស់កម្មវិធីដូចជា : ការបង្កើតប្រព័ន្ធសំណេរ ការអភិវឌ្ឍន៍កម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន ការវាយតម្លៃកម្មវិធី និងការស្វែងរកប្រភពជំនួយសម្រាប់កម្មវិធី។ ការកសាងទំនាក់ទំនងល្អជាមួយភ្នាក់ងារខាងក្រៅឱ្យបានច្រើនគឺជាកិច្ចការសំខាន់មួយទៀតរបស់អ្នកដឹកនាំកម្មវិធី។



## គណៈកម្មការរៀបចំ

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| លោក កុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| អ្នកស្រី ស៊ុន ឡេ | អ្នកឯកទេសកម្មវិធីអប់រំនៃអង្គការយូណេស្កូ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក ឡុង សុជាត | មន្ត្រីការិយាល័យក្រោយអក្ខរកម្ម |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| អ្នកស្រី លី ខេង | មន្ត្រីការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នកផ្ទៀងផ្ទាត់ និងកែសម្រួល**

| | |
|---|---|
| លោក មោគ គឿន | អនុប្រធានការិយាល័យអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ |
| លោក ឯក កេង | មន្ត្រីការិយាល័យអក្ខរកម្ម |
| លោក តាន់ ដន | ជំនួយការកម្មវិធីអប់រំនៃអង្គការយូណេស្កូ |
| លោក ហេង ភក្តី | និស្សិតបំពេញកម្មសិក្សាការងារផ្នែកអប់រំនៃអង្គការយូណេស្កូ |

**អ្នករចនាអត្ថបទ**

| | |
|---|---|
| លោក ឈិន វិត | ប្រធានការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |
| អ្នកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ និងគ្រប់គ្រងទិន្នន័យព័ត៌មាន |

បានទទួលការអនុញ្ញាតឲ្យបោះពុម្ព និង ប្រើប្រាស់ពីក្រសួងអប់រំ យុវជន និង កីឡា
តាមរយៈប្រកាសលេខ ៥១ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ។

Japanese Funds-in-Trust

UNESCO

អង្គការសហប្រជាជាតិស្តីពី
ការអប់រំ វិទ្យាសាស្ត្រ
និងវប្បធម៌